NUM
2024

តាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអតិថាលកិច្ចនៃអាជ្ញាធរ
មូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង

សិដ្ឋ ឡៃស៊ីន

តាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអតិថាលកិច្ចនៃអាជ្ញាធរ
មូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង

សិដ្ឋ ឡៃស៊ីន

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យជាតិគ្រប់គ្រង
សាលាក្រោយបរិញ្ញាបត្រ

នីតិសាស្ត្រសាធារណៈ ស្តីពី ការគ្រប់គ្រងដីធ្លីរដ្ឋ

និក្ខេបបទ ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ រដ្ឋបាលសាធារណៈ

ភ្នំពេញ
ឆ្នាំ ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យជាតិគ្រប់គ្រង
សាលាក្រោយបរិញ្ញាបត្រ

តាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអតិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង

សិដ្ឋ ឡៃស៊ីន

និក្ខេបបទដើម្បីបំពេញលក្ខខណ្ឌបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

សាស្ត្រាចារ្យដឹកនាំ

បណ្ឌិត តាន់ សារឿន

ភ្នំពេញ
ឆ្នាំ ២០២៤

អំណរអំណាច

នាងខ្ញុំឈ្មោះ សិដ្ឋ ឡៃស៊ីន អក្សរឡាតាំង SETH LAISIN បានកើតនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ មានទីកន្លែងកំណើតស្ថិតនៅ ភូមិបវេល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ នាពេលបច្ចុប្បន្ននេះជានិស្សិតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ នៃជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី២៥ ក្រុម ០៦ ឆ្នាំសិក្សា ២០២២-២០២៤។

នាងខ្ញុំសូមជានា អះអាងទាំងស្រុងចំពោះខ្លឹមសារនៅក្នុងរបាយការណ៍នេះ គឺពិតប្រាកដជាស្នាដៃស្រាវជ្រាវរបស់នាងខ្ញុំផ្ទាល់។ សូមបញ្ជាក់ផងដែរថានៅក្នុងអត្ថបទស្រាវជ្រាវនេះ មានអត្ថន័យខ្លឹមសារ យោងតាមទ្រឹស្តី ផ្អែកទៅតាមលំនាំដែលមានការសិក្សាពីមុន និងមានចំណុចដកស្រង់មួយចំនួន ដែលខ្លឹមសារដើមមានសារៈសំខាន់ពាក់ព័ន្ធនឹងការសិក្សានេះ ដោយមានប្រភពចេញពីអត្ថបទ ឯកសារច្បាប់នានាធ្លាប់មានស្រាប់ពីមុនមកដែលបានដាក់ឱ្យទស្សនា ឬប្រើប្រាស់ជាសាធារណៈ ឯកសារនៅលើប្រព័ន្ធអ៊ីនធឺណេត និងរួមចេញពីឯកសារដែលជាសមិទ្ធផលនៃការស្រាវជ្រាវរបស់អ្នកសិក្សាមួយចំនួនដែលបានចងក្រងឡើងកន្លងមក។ ចំពោះទិន្នន័យ និងលទ្ធផលដែលទទួលបានអំពីការសិក្សាដែលមាននៅក្នុងអត្ថបទនេះ គឺជាទិន្នន័យថ្មី ទទួលបានពីទីតាំងសិក្សាផ្ទាល់ ដើម្បីបំពេញលក្ខខណ្ឌនៃកិច្ចការស្រាវជ្រាវបញ្ចប់ការសិក្សានេះ។

សិដ្ឋ ឡៃស៊ីន

សាកលវិទ្យាល័យជាតិគ្រប់គ្រង

រាជធានីភ្នំពេញ, ប្រទេសកម្ពុជា

សេចក្តីសង្ខេប

អភិបាលកិច្ចល្អ គឺជាគោលគំនិតចម្រុះដែលរួមបញ្ចូលនូវ នីតិរដ្ឋ គណនេយ្យភាព តម្លាភាព ការឆ្លើយតប ការចូលរួម សមធម៌ និងបរិយាប័ន្ននៅក្នុងដំណើរការរដ្ឋបាលសាធារណៈ និងដំណើរការនៃសេចក្តីសម្រេចចិត្ត។ ប្រសិទ្ធភាព និងការឆ្លើយតបមានឥទ្ធិពលដល់ការយល់ឃើញរបស់សាធារណជនចំពោះការអនុវត្តរបស់អាជ្ញាធរ ដែលមានសារៈសំខាន់ណាស់ក្នុងការធានាថាសកម្មភាពរបស់អាជ្ញាធរ គឺដើម្បីផលប្រយោជន៍ និងតម្រូវការរបស់ប្រជាពលរដ្ឋត្រូវបានបំពេញ។ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចល្អ គឺជាសូចនាករសំខាន់នៃប្រសិទ្ធភាពដែលឆ្លុះបញ្ចាំងពីរបៀបដែលគោលនយោបាយ និងការអនុវត្តរបស់រដ្ឋាភិបាលស្របតាមការរំពឹងទុករបស់សាធារណៈជន និងលើកកម្ពស់ការជឿទុកចិត្ត។

និក្ខេបបទនេះ ស្វែងយល់ពីរបៀបដែលប្រជាពលរដ្ឋវាយតម្លៃការអនុវត្តរបស់អាជ្ញាធរមូលដ្ឋាន ដោយផ្អែកលើបទពិសោធន៍របស់ពួកគេជាមួយនឹងសេវាសាធារណៈ ភាពយុត្តិធម៌នៃដំណើរការច្បាប់ និងស្ថាប័ន លទ្ធភាពទទួលបានព័ត៌មាន និងប្រសិទ្ធភាពរួមនៃប្រតិបត្តិការរបស់អាជ្ញាធរ។ ផ្ទុយទៅវិញភាពមិនពេញចិត្តជារឿយៗកើតឡើងក្នុងបរិបទដែលអំពើពុករលួយ ភាពគ្មានប្រសិទ្ធភាព ឬកង្វះការឆ្លើយតបពីអាជ្ញាធរ ល្បឿននៃការផ្លាស់ប្តូរសង្គម និងបច្ចេកវិទ្យាអាចបង្កើតគម្លាតរវាងការរំពឹងទុករបស់ប្រជាពលរដ្ឋ និងសមត្ថភាពរបស់អាជ្ញាធរដែលនាំឱ្យមានការមិនពេញចិត្ត។ ក្នុងការសិក្សានេះកត្តាមួយចំនួនជាអថេរជះឥទ្ធិពល ដល់ភាពពេញចិត្តរបស់ប្រជាពលរដ្ឋរួមមាន៖ នីតិរដ្ឋ គណនេយ្យភាព តម្លាភាព ការឆ្លើយតប និងការចូលរួម នៃគោលការណ៍អភិបាលកិច្ចល្អ ដោយកត់សម្គាល់ថា នៅពេលដែលប្រជាពលរដ្ឋចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ពួកគេមានទំនោរក្នុងអារម្មណ៍ថាមានភាពជាម្ចាស់ និងពេញចិត្តចំពោះលទ្ធផល។ ជាលទ្ធផលនៃការសិក្សាបង្ហាញថាភាពវិជ្ជមាន និងសារៈសំខាន់ពាក់ព័ន្ធនឹងសមត្ថភាពរបស់អាជ្ញាធរក្នុងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពរួមចំណែកដល់ការវាយតម្លៃជាវិជ្ជមានរបស់ប្រជាពលរដ្ឋ អំពីអភិបាលកិច្ចនៅក្នុងមូលដ្ឋានឃុំបវេល។ របកគំហើញនេះអាចចូលរួមជួយដោះស្រាយ ដល់ដំណើរការអភិវឌ្ឍន៍ស្វែងរក និងលុបបំបាត់នៃអំពើពុករលួយ ឬការគ្រប់គ្រងមិនត្រឹមត្រូវ ដែលជះឥទ្ធិពលអវិជ្ជមានដល់កម្រិតនៃការពេញចិត្តរបស់ប្រជាពលរដ្ឋ និងរារាំងភាពស្របច្បាប់របស់រដ្ឋាភិបាល រាំងស្ទះការរីកចម្រើននៃមូលដ្ឋាន ឬសង្គម ដោយផ្តល់មកវិញនូវការពង្រឹងមុខងារ និងបំពេញតួនាទីអនុវត្តកិច្ចរបស់អាជ្ញាធរឱ្យកាន់រឹងមាំ លើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋឱ្យប្រសើរឡើង ស្របពេលទំនើបកម្មកាន់តែលូតលាស់ជឿនលឿននាអនាគត។

សរុបសេចក្តីមក ភាពញចិត្តរបស់ពលរដ្ឋ ជារង្វាស់ដ៏សំខាន់នៃសុខភាពនៃអភិបាលកិច្ច។ នៅពេលប្រជាពលរដ្ឋពេញចិត្តនឹងអភិបាលកិច្ចដែលខ្លួនជួបប្រទះ វាពង្រឹងភាពស្អិតរមួតក្នុងសង្គម និងការជឿទុកចិត្តលើស្ថាប័ន ថែមទាំងពង្រឹងស្ថិរភាពប្រជាធិបតេយ្យ និងលើកទឹកចិត្តឱ្យមានការចូលរួមជាវិជ្ជមានបន្ថែមពីប្រជាពលរដ្ឋ។ ជាចុងក្រោយ ដើម្បីជំរុញភាពពេញចិត្តរបស់ប្រជាពលរដ្ឋទាមទារឱ្យអាជ្ញាធរគប្បីត្រូវបន្តស្វែងរក ឆ្លើយតបទៅនឹងតម្រូវការ ឬកង្វល់របស់ប្រជាពលរដ្ឋ ដោយធានាថា គោលការណ៍អភិបាលកិច្ចល្អត្រូវបានប្រកាន់ខ្ជាប់ជាប់លាប់ក្នុងដំណើរការអនុវត្តន៍។

សេចក្តីថ្លែងអំណរគុណ



នាងខ្ញុំ **សិដ្ឋ ឡៃស៊ីន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី២៥ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ក្នុងឱកាសនេះ នាងខ្ញុំសូមគោរពដឹងគុណ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាអនេកបំផុតជូនដល់៖

សូមថ្លែងអំណរគុណចំពោះលោកអ្នកមានគុណ គឺ**លោកឪពុក អួកម្លាយ** រួមទាំងជីដូន និងជីតាផងដែលរូបលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សារូបនាងខ្ញុំតាំងពីតូចរហូតដល់ពេញវ័យ ជាពិសេសលោកបានចំណាយពេលវេលា ឧបត្ថម្ភកម្លាំងកាយចិត្ត ទំនុកបម្រុង ទាំងផ្នែកស្មារតី និងផ្នែកសម្ភារៈដើម្បីបានផ្តត់ផ្តង់ឱ្យនាងខ្ញុំបានសិក្សារៀនសូត្រតាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សានេះ និងតែងតែបង្ហាត់បង្រៀន អប់រំ ទូន្មាន ប្រៀនប្រដៅតម្រង់ទិស ដល់រូបនាងខ្ញុំឱ្យក្លាយជាពលរដ្ឋល្អ មានចំណេះដឹងរស់នៅក្នុងសង្គមមានលទ្ធផលល្អនាបច្ចុប្បន្ន និងសូមអរគុណដល់សមាជិកក្រុមគ្រួសារនាងខ្ញុំទាំងអស់ រួមទាំងមិត្តៗនិស្សិតទាំងអស់គ្នា ដែលតែងរមែងផ្តល់ក្តីស្រឡាញ់ លើកទឹកចិត្ត ជួយគាំទ្រដល់រូបនាងខ្ញុំក្នុងដំណើរនៃការសិក្សាដោយក្តីរីករាយកន្លងមក។

សូមថ្លែងអំណរគុណចំពោះ**ឯកឧត្តម ហោ ប៉ែច** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង រួមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ដែលជាគណៈដឹកនាំសាលាគ្រប់លំដាប់ជាន់ថ្នាក់ សាស្ត្រាចារ្យ និងមន្ត្រីបម្រើការងារនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងទាំងអស់ ដែលតែងយកចិត្តទុកដាក់ទាំងកម្លាំងកាយចិត្តរៀបចំគ្រប់គ្រង និងផ្តល់នូវកម្មវិធីសិក្សា អប់រំ ណែនាំ បង្ហាត់បង្រៀន ផ្តល់ចំណេះដឹង ដ៏មានតម្លៃដល់សិស្សនិស្សិតទាំងអស់គ្នា សម្រាប់ជាស្ពានឈានក្នុងការកសាងអនាគតនាពេលខាងមុខ។

ជាពិសេសសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត តាន់ សារឿន** ដែលលោកតែងតែលះបង់ចំណាយពេលវេលាមានតម្លៃជ្រោមជ្រែងយ៉ាងយកចិត្តទុកដាក់បំផុត ក្នុងការចែករំលែកផ្តល់នូវចំណេះដឹង ត្រួសត្រាយបង្ហាញផ្លូវប្រកបដោយបទពិសោធន៍ល្អៗ និងតែងតែជួយត្រួតពិនិត្យ និងកែលម្អផ្តល់ជាមតិយោបល់រាល់លើចំណុចខ្វះខាត ស្វះស្វែងផ្តត់ផ្តង់ទំនប់បម្រុងធនធានស្មារតីជានិច្ចនៅក្នុងដំណើរនៃការសិក្សាស្រាវជ្រាវនេះជាកំហិតតាំងពីពេលចាប់ផ្តើម រហូតដល់សិស្សទទួលបានសមិទ្ធផលជោគជ័យសម្រេចកិច្ចការដោយក្តីរីករាយ។

ជាទីបញ្ចប់នេះនាងខ្ញុំ សូមគោរពបួងសួងដល់គុណព្រះរតនត្រៃយ៍ និងវត្ថុស័ក្តិសិទ្ធទាំងអស់ក្នុងលោក សូមប្រសិទ្ធពរជ័យសិរីសួស្តី ជូនចំពោះក្រុមគ្រួសារ មិត្តនិស្សិត ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ជាថ្នាក់ដឹកនាំសាលា សាស្ត្រាចារ្យ និងមន្ត្រីបម្រើការនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងទាំងអស់ សូមមានជន្មាយុយឺនយូរ ទទួលបាននូវសុខភាពមាំមួន ប្រាជ្ញាឈ្លាសវៃ និង សម្រេចគ្រប់ភារកិច្ចការងារ ជាពិសេសសូមជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបី ឃ្លៀងឃ្លាតឡើយ។

មាតិកា

ទំព័រ

អំណៈអំណាង i

សេចក្តីសង្ខេប ii

សេចក្តីថ្លែងអំណរគុណ iii

ជំពូកទី១ ..... ១

សេចក្តីផ្តើម ១

១.១. សាវតានៃការសិក្សា ១

១.២. ការថ្លែងបញ្ហា ២

១.៣. សំណួរស្រាវជ្រាវ ៦

១.៤. កម្មវត្ថុនៃការសិក្សា ៦

១.៥. ការតាងសម្មតិកម្ម ៧

១.៦. វិសាលភាព និងដែនកំណត់នៃការសិក្សា ៧

១.៧. គោលបំណង និងសារៈសំខាន់នៃការសិក្សា ៨

១.៨. គម្រោងនៃការស្រាវជ្រាវ ៩

ជំពូកទី ២ ..... ១០

ការរំលឹកទ្រឹស្តី ១០

សេចក្តីផ្តើម ១០

២.១. ពាក្យគន្លឹះ ឬនិយមន័យ ១០

២.១.១. អភិបាលកិច្ច ១០

២.១.២. នីតិរដ្ឋ ១២

២.១.៣. តម្លាភាព ១៣

២.១.៤. គណនេយ្យភាព ១៤

២.១.៥. ការឆ្លើយតប ១៤

២.១.៦. ការចូលរួម ១៦

២.២.១. នីតិរដ្ឋ និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ១៨

២.២.២. តម្លាភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ២០

២.២.៣. គណនេយ្យភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ២៣

២.២.៤. ការឆ្លើយតប និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ២៦

២.២.៥. ការចូលរួមរបស់ប្រជាពលរដ្ឋ និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ២៨

២.៣. ការរំលឹកទ្រឹស្តីនៃវិធីសាស្ត្រស្រាវជ្រាវ ៣២

២.៤. ការពិភាក្សា និងគម្លាតទ្រឹស្តី ស្តីអំពីអភិបាលកិច្ចល្អ និងការពេញចិត្តរបស់ប្រជាពលរដ្ឋ
នៅឃុំបវេល ខេត្តបាត់ដំបង ប្រទេសកម្ពុជា ៣៤

២.៤. គោលគំនិតនៃការសិក្សា ៣៦

២.៥. សេចក្តីសន្និដ្ឋាន ៣៦

ជំពូកទី៣ ..... ៣៨

វិធីសាស្ត្រនៃការស្រាវជ្រាវ ៣៨

សេចក្តីផ្តើម ៣៨

៣.១. ប្រភេទនៃការវិភាគទិន្នន័យ ៣៨

៣.២. ទំហំ និងបច្ចេកទេសជ្រើសរើសសំណាក ៣៩

៣.៣. ប្រភពទិន្នន័យ ៤០

៣.៤. ឧបករណ៍វិភាគទិន្នន័យ ៤១

៣.៥. វិធីសាស្ត្រនៃការវិភាគទិន្នន័យ ៤២

៣.៦. សេចក្តីសន្និដ្ឋាន ៤៥

ជំពូកទី៤ ..... ៤៧

**អំពីគោលការណ៍អភិបាលកិច្ចល្អ និងទស្សនៈទានកំណែទម្រង់វិជ្ជាការ និងសហមជ្ឈការនៅ
កម្ពុជា** ៤៧

៤.១. គោលការណ៍អភិបាលកិច្ចល្អ ៤៧

៤.១.១. ទិដ្ឋភាពទូទៅនៃអភិបាលកិច្ចល្អ ៤៧

ក. និយមន័យ ៤៧

ខ. គោលបំណងនៃអភិបាលកិច្ច ៤៨

គ. តួអង្គសំខាន់ៗ ក្នុងអភិបាលកិច្ចល្អ ៤៨

៤.១.២. គោលការណ៍អភិបាលកិច្ចល្អ ៤៩

៤.១.៣. អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ៥៣

៤.១.៣. អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ៥៤

៤.២. ទស្សនៈទានកំណែទម្រង់វិជ្ជាការ និងសហមជ្ឈការនៅកម្ពុជា ៥៤

៤.២.១. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ៥៦

៤.២.២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ..... ៥៦

៤.២.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់រិមជ្ឈការ និងវិសហមជ្ឈការ ៥៧

៤.២.៤. ច្បាប់រៀបចំអង្គការ ៥៧

៤.២.៥.ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៥៧

៤.២.៥.១. គោលការណ៍ ៥៧

៤.២.៥.២. ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ៦០

៤.៣. សន្និដ្ឋាន ៦៥

ជំពូកទី៥ ..... ៦៦

ការវិភាគភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ៦៦

សេចក្តីផ្តើម ៦៦

៥.១. ភាពជឿជាក់នៃឧបករណ៍វិភាគទិន្នន័យ ៦៦

៥.២. ការវិភាគទិន្នន័យ ៦៧

៥.២.១. ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍ ៦៧

៥.២.១.៤. មុខរបររបស់អ្នកតបសម្ភាសន៍ ៦៩

៥.២.១.៥. អាស័យដ្ឋានរបស់អ្នកផ្តល់សម្ភាសន៍ ៧០

៥.៣. លទ្ធផលនៃការវិភាគកត្តារុករក និងតេស្តរកភាពទុកចិត្ត ៧១

៥.៤. វាយតម្លៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ
ឃុំបវេល ៧៣

៥.៥. វិភាគទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចល្អ ៧៤

៥.៥.១. ការបកស្រាយសេចក្តីសង្ខេបម៉ូដែល (Summary of Model).....៧៥

៥..២.២. ការបកស្រាយ ANOVA.....៧៥

៥.៥.៣. លទ្ធផលនៃ Coefficient Regression.....៧៥

៥.៤.៤. ការតេស្ត Assumptions.....៧៨

ជំពូកទី៦ ..... ៨២

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៨២

សេចក្តីផ្តើម..... ៨២

៦.១. សេចក្តីសង្ខេបលទ្ធផល..... ៨២

៦.២. សេចក្តីសន្និដ្ឋាន..... ៨៥

៦.៣. លទ្ធផល និងអនុសាសន៍..... ៨៦

៦.៤. ដែនកំណត់និងការសិក្សានាអនាគត ៨៨

ឯកសារយោង ៨៩

ឧបសម្ព័ន្ធ..... ៩៨

ជំពូកទី១
សេចក្តីផ្តើម

១.១. សាថតានៃការសិក្សា

ដូចដែលយើងបានដឹងសព្វថ្ងៃនេះប្រទេសកម្ពុជា គឺជាប្រទេសដែលស្ថិតក្នុងស្ថានភាពកំពុងអភិវឌ្ឍន៍ ដែលត្រូវការពង្រឹងអភិបាលកិច្ចឱ្យកាន់រឹងមាំ និងមានប្រសិទ្ធភាពខ្ពស់ដើម្បីធានាការរីកចម្រើនដែលធ្វើឱ្យមានភាពប្រសើរឡើងនៅថ្ងៃអនាគត។ រដ្ឋាភិបាលក្នុងតំបន់ទទួលខុសត្រូវចំពោះសេវាកម្មសំខាន់ៗជាច្រើនសម្រាប់មនុស្ស និងអាជីវកម្មនៅក្នុងតំបន់ដែលបានកំណត់។ ក្នុងចំណោមមុខងារទាំងនោះ មានមុខងារដែលគេស្គាល់ច្រើនដូចជាការថែទាំសង្គម សាលារៀន លំនៅឋាន និងការធ្វើផែនការ និងការប្រមូលសំរាម ប៉ុន្តែក៏មានមុខងារដែលគេស្គាល់តិចផងដែរដូចជាអាជ្ញាប័ណ្ណ ជំនួយអាជីវកម្ម សេវាចុះបញ្ជី និងការគ្រប់គ្រងសត្វល្អិត។ អាជ្ញាធរមូលដ្ឋានទទួលបានមូលនិធិពីប្រភពជាច្រើន រួមទាំងជំនួយរបស់រដ្ឋាភិបាល ពន្ធក្រុមប្រឹក្សា និងថ្លៃសេវា និងការគិតថ្លៃ (Local Government Association)។ អភិបាលកិច្ចល្អត្រូវបានបង្កើតឡើងនៅលើសសរស្តម្ភដូចជា តម្លាភាព គណនេយ្យភាព នីតិរដ្ឋ ការចូលរួម និងការឆ្លើយតប។ ក្នុងចំណោមទាំងនេះ ការឆ្លើយតបឆ្លុះបញ្ចាំងពីសមត្ថភាពរបស់រដ្ឋាភិបាលក្នុងប្រតិកម្មទៅនឹងតម្រូវការសង្គម ផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព និងធានាថាធាតុចូលរបស់ពលរដ្ឋបកប្រែទៅជាគោលនយោបាយដែលអាចធ្វើសកម្មភាពបាន។ សមត្ថភាពសម្រាប់ការឆ្លើយតបគឺចាំបាច់សម្រាប់ការរក្សាការជឿទុកចិត្តសាធារណៈ ភាពស្របច្បាប់តាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព (World Bank2020)។ អភិបាលកិច្ចល្អ ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការ នៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍមួយប្រកបដោយ និរន្តរភាព ។ អភិបាលកិច្ចដែលប្រកបដោយសុកវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អ ដោយការ ចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈ ប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល (ក្រសួងមហាផ្ទៃ2010)។ អភិបាលកិច្ចដែលបានកែលម្អតម្រូវឱ្យមានយុទ្ធសាស្ត្ររួមនិងរយៈពេលវែងដែលត្រូវបានបង្កើតឡើងលើកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលនិងប្រជាពលរដ្ឋ។ វាមានទាំងការចូលរួមនិងស្ថាប័ន។ នីតិរដ្ឋ គណនេយ្យភាព និងតម្លាភាព គឺជាបញ្ហាបច្ចេកទេស និងច្បាប់ក្នុងកម្រិតមួយចំនួន ប៉ុន្តែក៏មានអន្តរកម្មដើម្បីបង្កើតរដ្ឋាភិបាលដែលស្របច្បាប់ ប្រសិទ្ធភាព និងការគាំទ្រយ៉ាងទូលំទូលាយពីប្រជាពលរដ្ឋ ក៏ដូចជាសង្គមស៊ីវិលដែលរឹងមាំ បើកចំហ និងមានសមត្ថភាព។ ដើរតួនាទីជាវិជ្ជមានក្នុងនយោបាយ និងរដ្ឋាភិបាល (Good Governance: Rule of Law,Transparency, and Accountability)។ គោលគំនិតនៃអភិបាលកិច្ច អភិបាលកិច្ចល្អ និងអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ត្រូវបានគេកំណត់យ៉ាងច្បាស់លាស់ក្នុងកំឡុងទសវត្សរ៍ឆ្នាំ 1990 អាស្រ័យលើអ្នកដែលធ្វើការបកស្រាយ និងតាមបរិបទ។ កាលពីប៉ុន្មានឆ្នាំមុន គំនិតទូទៅនៃអភិបាលកិច្ចគឺស្មើនឹងអភិបាលកិច្ចល្អ ហើយអភិបាលកិច្ចល្អមិនត្រូវបានច្រលំជាញឹកញាប់ជាមួយអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនោះទេ។ ទោះបីជាការភ័ន្តច្រឡំជាក់លាក់មួយនៅតែអាចត្រូវបានរកឃើញក៏ដោយ វាជាការកត់សម្គាល់ក្នុងចំណោមភ្នាក់ងារ

ផ្តល់ជំនួយ អភិបាលកិច្ចត្រូវបានកំណត់ជាទូទៅដោយអព្យាក្រឹត ហើយទាក់ទងនឹងសង្គមគ្រប់ប្រភេទ ដោយគ្មានផលប៉ះពាល់វិជ្ជមាន។ ជារួមអភិបាលកិច្ចល្អបង្កប់នយវិស័យសាធារណៈប្រកបដោយប្រសិទ្ធភាព និងអាចព្យាករណ៍បាន ដោយរួមបញ្ចូលការចូលរួម និងនីតិរដ្ឋ ពោលគឺជាមួយនឹងលក្ខណៈនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ នៅក្នុងគោលគំនិតនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ ការសង្កត់ធ្ងន់កាន់តែខ្លាំងទៅលើស្ថាប័នប្រជាធិបតេយ្យកណ្តាល ដូចជារដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ សភា ការបោះឆ្នោតទូទៅ ការចូលរួម និងសង្គមស៊ីវិលសកម្ម ក៏ដូចជាសិទ្ធិមនុស្ស (sida-good-governance.pdf)។ អភិបាលកិច្ចល្អ មានគោលបំណងជានូវសិទ្ធិស៊ីវិល វប្បធម៌ សេដ្ឋកិច្ច សង្គម និងនយោបាយរបស់សាធារណជនទូទៅ ខណៈពេលដែលលើកកម្ពស់អ្នកគ្រប់គ្រង និងអ្នកបង្កើតគោលនយោបាយមានការទទួលខុសត្រូវ។ វាការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ និងសង្កត់ធ្ងន់លើការគ្រប់គ្រងវិស័យសាធារណៈ ក្របខ័ណ្ឌអភិវឌ្ឍន៍ផ្លូវច្បាប់ គណនេយ្យភាព និងតម្លាភាព។ អភិបាលកិច្ចល្អ គឺជាព្រលឹងនៃប្រព័ន្ធចែកចាយសាធារណៈរបស់រដ្ឋាភិបាលមានប៉ារ៉ាម៉ែត្រដែលអាចវាស់វែងបាន តាមរយៈការវាយតម្លៃការអនុវត្តនៅទូទាំងផ្នែក/អង្គភាពផ្សេងៗនៃការរៀបចំរដ្ឋបាលក្នុងរយៈពេលមួយ។ គំនិតផ្តួចផ្តើមអភិបាលកិច្ចល្អត្រូវបានឆ្លុះបញ្ចាំងក្នុងរយៈពេលមួយនៅក្នុងការចូលរួមរបស់ប្រជាជន នីតិរដ្ឋ តម្លាភាព ការឆ្លើយតប មតិឯកភាព ទិសដៅសមធម៌ និងបរិយាប័ន្ន ឥទ្ធិពល និងប្រសិទ្ធភាព គណនេយ្យភាព។ល។ (Manoj Sinha, Dr. Arun Kumar Mehta, Dr. Raghav Langer, Satvir Kour Sudan 2021)។ អភិបាលកិច្ចល្អ៖ រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាបន្តថែរក្សាសន្តិភាព និងស្ថេរភាពនយោបាយ និងមានវិធាន ការសម្រាប់ ការងារអភិបាលកិច្ចល្អ រួមទាំងពង្រឹងការអនុវត្តការងារវិមជ្ឈការនិងវិសហមជ្ឈការ លើកកម្ពស់អភិបាលកិច្ច ការងារសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន និងភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន (ផ.យ.អ.ជ. ២០១៩-២០២៣,ឧសភា ឆ្នាំ២០១៨)។ សម្តេចធិបតី ហ៊ុន ម៉ាណែត បានថ្លែងថា អភិបាលកិច្ចគឺជាការធានា ដល់ការប្រតិបត្តិរួមគ្នា សង្គតិភាព ប្រសិទ្ធភាព និងជាប្រទីបមួយសម្រាប់បញ្ជាក់អំពីការទួលខុសត្រូវ។ ដូច្នេះ អភិបាលកិច្ចល្អគឺជាការធ្វើទំនើបកម្ម ស្ថាប័នឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើបប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋ ជាពិសេសការធានានិរន្តភាព និងដំណើរការរបស់រដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់លើផលប្រយោជន៍របស់ប្រជាជននិងការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន ភាពធន់ និងចីរភាព។ សម្តេចធិបតី បានបន្ថែមថាភាពជោគជ័យក្នុងការសម្រេចបាននូវអភិបាលកិច្ចល្អអាស្រ័យលើកត្តាសំខាន់ចំនួន២ គឺ៖ ១-យន្តការ ២-មនុស្ស (សម្តេចធិបតី ហ៊ុន ម៉ាណែត៖ ឆ្នាំ 2024)។

១.២. ការផ្លាស់បញ្ហា

អភិបាលកិច្ចល្អ សំដៅលើគោលការណ៍ និងដំណើរការដែលធានាថា សកម្មភាពរបស់រដ្ឋាភិបាលមានតម្លាភាព គណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ វារួមបញ្ចូលទាំងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃធនធាន ការបង្កើតនីតិរដ្ឋ និងការលើកកម្ពស់ការធ្វើសេចក្តីសម្រេចដែលរួមបញ្ចូល និងសមធម៌។ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចល្អ គឺជារង្វាស់សំខាន់នៃភាពស្របច្បាប់ ភាពជោគជ័យនៃការគ្រប់គ្រងសាធារណៈ។

នៅពេលដែលអភិបាលកិច្ចត្រូវបានយល់ឃើញថាមានភាពយុត្តិធម៌ និងការឆ្លើយតប វានាំទៅដល់កម្រិតខ្ពស់នៃការជឿទុកចិត្ត និងការពេញចិត្តរបស់ប្រជាពលរដ្ឋ។ ផ្ទុយទៅវិញ ការអនុវត្តអភិបាលកិច្ចមិនល្អ ដូចជាអំពើពុករលួយ ឬកង្វះតម្លាភាព អាចនាំឱ្យមានការមិនពេញចិត្តជាសាធារណៈ និងលុបបំបាត់ការជឿទុកចិត្តលើស្ថាប័ន។

អភិបាលកិច្ចដែលប្រកបដោយសុកវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អ ដោយការ ចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈ ប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល ។ ភាពត្រឹមត្រូវតាមគោលនយោបាយ គឺជាលំក្ខខ័ណ្ឌចាំបាច់ដំបូងគេបំផុត នៃអភិបាលកិច្ចល្អ។ ផ្អែកលើសារៈសំខាន់នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលបាននឹងកំពុងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ ដោយបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ចូលគោលការណ៍នៃអភិបាលកិច្ចល្អទៅក្នុងក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល និងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍ ប្រទេសប្រកបដោយជោគជ័យ (ក្រសួងមហាផ្ទៃ, ២០១០)។

កំណែទម្រង់វិមជ្ឈការ បានចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០០២ ក្នុងរូបភាពផ្តល់ស្វ័យភាពដល់ថ្នាក់មូលដ្ឋាន (ឃុំ/សង្កាត់) ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងច្បាប់ស្តីពីការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ អនុម័តក្នុងឆ្នាំ២០០១។ មកទល់បច្ចុប្បន្ន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ បានធ្វើឡើងចំនួន២លើក ប្រកបដោយជោគជ័យក្នុងឆ្នាំ ២០០២ និង ២០០៧។ កំណែទម្រង់នេះ ត្រូវបានពង្រីកវិសាលភាព កាន់តែធំដល់ថ្នាក់ក្រោមជាតិ តាមក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលអនុម័តក្នុង ឆ្នាំ ២០០៥។ ស្របតាមក្របខ័ណ្ឌនេះ ច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ហៅថា ច្បាប់រៀបចំអង្គការ) ត្រូវបានអនុម័តក្នុងខែមេសា ២០០៨។ ច្បាប់រៀបចំ អង្គការនេះ បានបង្កើតឲ្យមានរដ្ឋបាលថ្នាក់ក្រោមជាតិ ២ថ្នាក់ បន្ថែមទៀត គឺក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាក្រុង/ស្រុក។ ក្រុមប្រឹក្សាទាំងនេះ ទទួលបានតំណែងតាមការបោះឆ្នោតដោយ ប្រយោលពីក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលបានធ្វើឡើងជាលើកដំបូង ក្នុងខែឧសភា ២០០៩។ នៅក្នុងកំណែទម្រង់ដ៏ស៊ីជម្រៅនេះ ធនធាន សិទ្ធិអំណាច និងមុខងារសំខាន់ៗត្រូវបានធ្វើប្រតិភូកម្មពីថ្នាក់កណ្តាលទៅឲ្យថ្នាក់ខេត្ត និងថ្នាក់ក្រុង/ស្រុក ក្នុងគោល បំណងលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងការផ្តល់សេវាក្រោមក្របខ័ណ្ឌរដ្ឋបាលឯកភាព។ លើសពីនេះទៀត យន្តការសម្រាប់គណនេយ្យភាព ការចូលរួមពីសាធារណជន ភាពជាតំណាង ប្រសិទ្ធភាពការងារ ប្រជាធិបតេយ្យ និងការអភិវឌ្ឍមូលដ្ឋាន ក៏ត្រូវបានអនុម័ត និងដាក់ឲ្យអនុវត្តផងដែរ (RGC 2005)(ហេង សីហា គឹម សេតារា និង សូ សុខប៊ុនធឿន, ២០១១)។ ការធ្វើកំណែទម្រង់អភិបាលកិច្ចល្អ ជាកិច្ចការចម្បងមួយ ដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន និងឆ្លើយតបតាម តម្រូវការរបស់ប្រជាពលរដ្ឋ ស្របទៅនឹងកំណើនសេដ្ឋកិច្ចជាតិ ដែល កំពុងតែមានការវិវត្តន៍ទៅមុខ ឥតឈប់ឈរ ក្នុងល្បឿនយ៉ាងលឿន ឆាប់រហ័ស។ រដ្ឋបា

លសាធារណៈ ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតែពង្រឹងសមត្ថភាពរបស់ខ្លួនឲ្យបានខ្ពស់ជាងមុន មានមុខងារជាក់លាក់ និងធនធានសមស្របសម្រាប់អនុវត្តមុខងារដែលបានផ្ទេរប្រកបដោយ ការទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។ ក្នុងនោះកំណែទម្រង់នៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ គឺជា ផ្នែកមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាពិសេសការផ្ទេរ មុខងារ និងធនធានពីក្រសួង ស្ថាប័ននៅថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនៅកៀកជិតប្រជាពលរដ្ឋ គឺក្នុងគោលបំណង លើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹង សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌សង្គម។ ការបង្កើតយន្តការ ច្រកចេញចូលតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជារូបភាពមួយនៃការ ធ្វើកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ និងលើកកម្ពស់អភិបាលកិច្ចល្អ ក្នុងការផ្តល់សេវាតាមរយៈការប្រមូលផ្តុំសេវា ដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋឱ្យមកផ្តុំនៅកន្លែងតែមួយ និងប្រគល់សម្រេចទៅឱ្យថ្នាក់រដ្ឋបាល ដែលនៅកៀកជិតនឹងប្រជាពលរដ្ឋ ជាអ្នកទទួលខុសត្រូវក្នុង ការផ្តល់សេវាជូនប្រជាពលរដ្ឋ (លោករដ្ឋលេខាធិការ ង៉ី ចន្ទ្រ ថុល 2020)។

បញ្ហាប្រឈម និងការរិះគន់៖ ទោះបីជាសារៈសំខាន់នៃការពេញចិត្តរបស់ប្រជាពលរដ្ឋជាសូចនាករនៃអភិបាលកិច្ចល្អក៏ដោយ ក៏អ្នកប្រាជ្ញមួយចំនួនអះអាងថា ការពេញចិត្ត គឺជាប្រធានបទហើយអាចមានឥទ្ធិពលលើកត្តាដែលនៅក្រៅការគ្រប់គ្រងនៃរចនាសម្ព័ន្ធអភិបាលកិច្ច។ Christensen and Laegreid (2005) ណែនាំថា មនោគមវិជ្ជានយោបាយ លក្ខខណ្ឌសេដ្ឋកិច្ច និងឥទ្ធិពលប្រព័ន្ធផ្សព្វផ្សាយរបស់ពលរដ្ឋ អាចប៉ះពាល់ដល់ការយល់ឃើញរបស់ពួកគេចំពោះគុណភាពអភិបាលកិច្ច។ ដូច្នេះ ការពឹងផ្អែកតែលើការស្ទង់មតិពេញចិត្ត ប្រហែលជាមិនអាចចាប់យកប្រសិទ្ធភាពនៃប្រព័ន្ធអភិបាលកិច្ចបានពេញលេញនោះទេ។ ទោះបីជាមានសេវាកម្មសាធារណៈផ្សេងៗជាច្រើនត្រូវបានផ្តល់ជូននៅថ្នាក់ឃុំក៏ដោយ ការរៀបចំរបស់ ស្ថាប័នដើម្បីផ្តល់សេវាកម្មទាំងនោះមិនបានធ្វើឱ្យគេយល់ច្បាស់នៅឡើយទេ។ លើសពីនេះទៅទៀត ការចូលរួមដោយផ្ទាល់ពីក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការផ្តត់ផ្តង់សេវាកម្មទាំងនោះមិនត្រូវបានគេមើលឃើញថាមានលក្ខណៈជាប្រព័ន្ធនោះទេ។ មេរៀនជាច្រើន ដែលបានមកពីការស្រាវជ្រាវស្តីពីការផ្តល់សេវាកម្ម ថ្នាក់មូលដ្ឋាន និងតួនាទីរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់បានបង្ហាញឱ្យឃើញថា ការផ្តល់សេវាកម្មថ្នាក់មូលដ្ឋាន អាចមានលក្ខណៈល្អប្រសើរជាងមុន តាមរយៈការចូលរួមរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ មានប្រសិទ្ធភាពច្រើនជាងមុន។ ការផ្តល់សេវាកម្មសាធារណៈថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពមួយបែបទៀតនោះ គឺការទាមទារឱ្យមានការចូលរួមពីផ្នែកពាក់ព័ន្ធនានា រួមទាំងការធ្វើផែនការ ការធ្វើគំរោងថវិកា ការផ្តល់ហិរញ្ញវត្ថុ ផលិតកម្ម និងការត្រួតពិនិត្យ និងការវាយតំលៃ។ ទាំងអ្នកមានតម្រូវការ និងទាំងអ្នក ផ្តត់ផ្តង់ ទាមទារឱ្យមានសេវាកម្មសាធារណៈនេះ ។ គេបានបង្ហាញឱ្យឃើញថា តម្រូវការរបស់អ្នកប្រើប្រាស់ ផ្សេងៗត្រូវបានកំណត់ជារួម ជាជាងឱ្យបុគ្គលម្នាក់ៗបង្ហាញពីតម្រូវការរបស់ពួកគេចំពោះសេវាកម្មសាធារណៈនោះ។ តួនាទីមួយដែលអាជ្ញាធរមូលដ្ឋានអាចបង្ហាញនៅក្នុងដំណើរការនេះ គឺត្រូវប្រមូលផ្តុំតម្រូវការ សេវាកម្មសាធារណៈទាំងអស់របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ពីព្រោះ

អាជ្ញាធរមូលដ្ឋានមានភាពជិតស្និទ្ធ ជាមួយប្រជាពលរដ្ឋជាងថ្នាក់ខេត្ត ឬថ្នាក់មជ្ឈិម ដូច្នេះពួកគេអាចប៉ាន់ប្រមាណតម្រូវការរបស់ប្រជាពលរដ្ឋ មានប្រសិទ្ធភាពជាង ។ ការប្រឈមមុខចំបងៗ ដែលទាក់ទងនឹងសេវាកម្មសាធារណៈបង្ហាញជាសង្ខេបដូចខាងក្រោម៖

- មានកង្វះខាតជាទូទៅក្នុងការអះអាង ឬបង្ហាញឱ្យបានលំអិតនូវអ្វីដែលជាភារកិច្ចដំរើស និងអ្វីដែលជាភារកិច្ចចាំបាច់ក្នុងការផ្តល់សេវាកម្ម។ ចំណុចនេះបានបង្ហាញពីផលប៉ះពាល់អវិជ្ជមានចំពោះ ការទទួលខុសត្រូវ និងលទ្ធភាពបង្កើតទំនាក់ទំនងរវាងមុខងារ និងការរៀបចំមូលនិធិ ។
- មានផលវិបាកសំរាប់អាជ្ញាធរតាមលំដាប់ថ្នាក់នីមួយៗក្នុងការឆ្លើយតប និងផ្តល់សេវាកម្មប្រកប ដោយប្រសិទ្ធផលដល់ផ្នែកផ្សេងៗគ្នាទាំងទំហំ និងសមត្ថភាពផ្តល់សេវាកម្មរបស់ក្រុមនីមួយៗ។
- អាជ្ញាធរថ្នាក់ខេត្តពុំមានរង្វាន់លើកទឹកចិត្តដើម្បីអភិវឌ្ឍកម្មវិធី-គម្រោងអភិវឌ្ឍន៍ឱ្យបានល្អនោះទេ ដោយកង្វះខាតមូលនិធិ ។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈថ្នាក់ខេត្តពឹងផ្អែកលើហិរញ្ញវត្ថុ និងគំរោង ថែទាំតាមផ្នែកនានារបស់រដ្ឋាភិបាលថ្នាក់មជ្ឈឹមតែប៉ុណ្ណោះ។ គម្រោងផ្តល់សេវាកម្មសាធារណៈ ដែលមានតម្លាភាព និងបានអនុម័តរួចហើយនោះលែងមានតទៅទៀតហើយ ។
- ប្រព័ន្ធផ្ទេរសេវាកម្ម និងប្រព័ន្ធផ្តល់សេវាកម្មបែបមជ្ឈការមិនទាន់បំពេញតម្រូវការឱ្យបានគ្រប់គ្រាន់ ហើយការងារអាទិភាពនានាក្នុងមូលដ្ឋាន ភាពបត់បែន និងការកែតម្រូវផ្សេងៗមិនត្រូវ បានជានា នៅឡើយ ។
- មានផលវិបាកក្នុងការវិនិច្ឆ័យគុណភាពនៃការផ្តល់សេវាកម្ម ហើយពេលខ្លះមិនអាចទទួលយកបាន។ ប្រព័ន្ធត្រួតពិនិត្យការបំពេញការងារនៅមានកំរិតខ្សោយនៅឡើយ ។
- ការចំណាយក្រៅផ្លូវការផ្សេងៗក្លាយទៅជារឿងសាមញ្ញទៅហើយនៅតាមផ្នែកមួយចំនួន។ ត្រូវតែ មានការបញ្ជាក់ឱ្យបានច្បាស់នូវតំបន់ និងផ្នែកទាំងឡាយដែលត្រូវធ្វើការចំណាយទៅលើទាំងផ្លូវការ និងមិនផ្លូវការ និងបញ្ជាក់ឱ្យបានច្បាស់ពីទីកន្លែងដែលសេវាកម្មត្រូវបានផ្តល់ជូនដោយមិនគិតកំរៃ ។

កន្លងមកបច្ចុប្បន្ន គោលនយោបាយអភិវឌ្ឍន៍ប្រព័ន្ធគាំពារ សង្គម ត្រូវបានដាក់ចេញដោយក្រសួង-ស្ថាប័នរដ្ឋជាច្រើន ទៅតាមមុខងារនិងភារកិច្ចរៀងៗខ្លួន។ ការរៀបចំគោលនយោបាយគាំពារសង្គមដោយឡែកពីគ្នា របស់ក្រសួង-ស្ថាប័ននីមួយៗ បង្ហាញពីកង្វះខាតនូវយន្តការ សម្របសម្រួលរួមមួយ។ កត្តានេះនាំឲ្យមានអសង្គតិភាព ភាពខ្វះចន្លោះ ឬភាពត្រួតស៊ីគ្នារវាងគោលនយោបាយនីមួយ ៗ ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រសិទ្ធភាពនៃ ការប្រើប្រាស់ធនធានទាំងធនធានហិរញ្ញវត្ថុ និង ធនធានមនុស្ស។ មិនតែប៉ុណ្ណោះ យន្តការតាមដាន និងត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃការគ្រប់គ្រង ឬដំណើរការកម្មវិធីជាតិនីមួយៗ ក៏មិនទាន់មានវត្តមាននៅឡើយ ដែលនេះជាឧបសគ្គ សម្រាប់ការវាស់ស្ទង់ផលិត-ភាព និងប្រសិទ្ធភាព នៃការវិនិយោគសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់ផលវិបាកផង ដៃរក្នុងការកំណត់គោលនយោបាយអភិវឌ្ឍន៍ជាបន្តបន្ទាប់

(អភិបាលកិច្ចប្រព័ន្ធគាំពារសង្គម)។ ទន្ទឹមនឹងសមិទ្ធិផលទាំងឡាយ ក៏នៅមានបញ្ហាប្រឈមសំខាន់ៗដែលត្រូវដោះស្រាយ ដូចជា៖

- វិសាលភាពគ្របដណ្តប់នៃកម្មវិធីជាតិជំនួយសង្គម និងរបបសន្តិសុខសង្គមនៅមិនទាន់ទូលំទូលាយនិងគ្របដណ្តប់ពេញលេញ ដែលធ្វើឲ្យក្រុមប្រជាជនមួយចំនួន មិនទាន់ទទួល បានការគាំពារ
- ដំណើរការគ្រប់គ្រងកម្មវិធី និងរបបមិនមានលក្ខណៈប្រមូលផ្តុំ នាំឲ្យមានផលប៉ះពាល់ដល់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការបំពេញការងារ និងចំណាយថវិកាខ្ពស់ ព្រមទាំង នាំឲ្យមានអសង្គតិភាពចំពោះអត្ថប្រយោជន៍រវាងក្រុមប្រជាជនគោលដៅផ្សេងៗ
- យន្តការសម្របសម្រួលកម្រិតគោលនយោបាយរវាងស្ថាប័នពាក់ព័ន្ធ និងយន្តការត្រួតពិនិត្យដើម្បីធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពនៃប្រតិបត្តិការគ្រប់គ្រង និងចាត់ចែងកម្មវិធី និងរបបនីមួយៗនៅមានការខ្វះខាត
- បរិដ្ឋានវិនិយោគនៅមិនទាន់មានភាពល្អប្រសើរ ខណៈដែលគោលនយោបាយពន្ធដារក៏នៅ មិនទាន់កំណត់ឲ្យបានច្បាស់លាស់
- ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណ និងអត្រានុកូលដ្ឋានប្រជាជនទូទៅ ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប្រជាជនក្រីក្រនិងងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីរបស់ស្ថាប័នប្រតិបត្តិកររនៅមិនទាន់បានតភ្ជាប់គ្នា ដែលនាំឲ្យមានការត្រួតគ្នាលើការកំណត់អត្តសញ្ញាណ និងការចុះបញ្ជី និងការផ្តល់អត្ថប្រយោជន៍ត្រួតគ្នាផងដែរ និង
- ការយល់ដឹងអំពីប្រព័ន្ធគាំពារសង្គម ដូចជាអត្ថប្រយោជន៍ និងកាតព្វកិច្ចក្នុងការចូលរួមរបស់ប្រជាជននៅក្នុងរបប ឬកម្មវិធីនីមួយៗនៅមានកម្រិតក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥)។

អាស្រ័យដោយហេតុដូចបានលើកមក ទើបកើតមានការសិក្សានេះឡើងមក ដើម្បីស្រាយបំភ្លឺឱ្យបានឃើញថាតើ ការអនុវត្តការងារអភិបាលកិច្ចកម្រិតណាដែលជះឥទ្ធិពលទៅលើភាពពេញចិត្តពីសំណាក់ប្រជាពលនៅក្នុងទីតាំងមូលដ្ឋានសិក្សា។

១.៣. សំណួរស្រាវជ្រាវ

ចំពោះការសិក្សានេះ គឺដើម្បីស្វែងរកនូវចម្លើយឆ្លើយតបនឹងសំណួរដូចខាងក្រោម៖

- ➢ ១. តើអ្វីជាគោលនយោបាយនៃអភិបាលកិច្ចល្អដែលមានស្រាប់នៅកម្ពុជា?
- ➢ ២. តើប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានមានភាពពេញចិត្តកម្រិតណា ចំពោះការអនុវត្តការងារអភិបាលកិច្ច របស់អាជ្ញាធរមូលដ្ឋាន?
- ➢ ៣. តើកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះដំណើរការអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន?

១.៤. កម្មវត្ថុនៃការសិក្សា

តាមរយៈប្រធានបទស្រាវជ្រាវនេះ កម្មវត្ថុនៃការសិក្សារួមមាន៖

- ១. វិភាគគោលនយោបាយនៃអភិបាលកិច្ចដែលមានស្រាប់នៅមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
- ២. វាយតម្លៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើលទ្ធផលនៃការអនុវត្តន៍ការងាររបស់អាជ្ញាធរក្នុងមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង
- ៣. កំណត់ និងវិភាគកត្តាមួយចំនួន ដែលមានឥទ្ធិពលលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង
- ៤. ទាញសរុបធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍

១.៥. ការគោលសម្មតិកម្ម

ចំពោះករណីសិក្សាយើងមានអថេរពីរ គឺអថេរឯករាជ្យ និងអថេរពឹងផ្អែក ដែលយើងលើកយកមកជាដំណោះស្រាយបញ្ហានៃការស្រាវជ្រាវ។ អថេរទាំងពីរមានសារៈសំខាន់ព្រោះវាជាគន្លឹះសំខាន់ សម្រាប់ដំណើរការសិក្សាទៅលើប្រធានបទស្រាវជ្រាវរបស់យើង ឲ្យមានភាពងាយស្រួលក្នុងការស្វែងរកអត្ថន័យដើម្បីបកស្រាយចម្ងល់ដែលពាក់ព័ន្ធ។ តាមរយៈអថេរទាំងពីរ ធ្វើឲ្យយើងទាញបាននូវសម្មតិកម្មចំនួន០៦ឡើងមកក្នុងនោះរួមមាន៖

- សម្មតិកម្មទី១(Ha1)៖ នីតិរដ្ឋ ជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
- សម្មតិកម្មទី២(Ha2)៖ តម្លាភាព ជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
- សម្មតិកម្មទី៣(Ha3)៖ គណនេយ្យភាព ជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
- សម្មតិកម្មទី៤(Ha4)៖ ការឆ្លើយតប ជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
- សម្មតិកម្មទី៥(Ha5)៖ ការចូលរួម ជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តនៃប្រជាពលរដ្ឋចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

១.៦. ទិសាលភាព និងដែនកំណត់នៃការសិក្សា

ដើម្បីឱ្យការសិក្សាអំពីប្រធានបទទាក់ទងទៅនឹង «ភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ខេត្តបាត់ដំបង» មានភាពត្រឹមត្រូវ គឺត្រូវបានធ្វើឡើងឃុំបវេលផ្ទាល់ជាទីតាំងសិក្សា ក្នុងបំណងវែកញែកស្វែងរក ប្រសិទ្ធភាពអនុវត្តការងារអភិបាលកិច្ចជាក់ស្តែង និងរកលទ្ធផលដែលមានភាពវិជ្ជមាន ឬអវិជ្ជមានទៅលើប្រជាពលរដ្ឋក្នុងទីតាំងគោលដៅសិក្សាជួបប្រទះ។ ដោយឡែកសម្រាប់ទិន្នន័យដែលយើងយកមកវិភាគ ជាចំណុចចង្អុលបង្ហាញ ចំពោះរង្វាស់ភាពពេញចិត្តបស់ប្រជាពលរដ្ឋឆ្លើយតបទៅលើការផ្តល់ សេវាកម្មនៃអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន តាមរយៈការជ្រើសរើសយកទំហំសំណាកក្នុងចំនួនកំណត់មួយក្នុងចំណោមស្ថិតិសំណាកសាកលនៃចំនួនប្រជាពលរដ្ឋដាក់ស្តែងក្នុងទីតាំង ដោយផ្អែកលើរូបមន្តគណនាទំហំសំណាកដោយជ្រើសរើសយកភាពលម្អៀង៥%។

ដោយការការស្រាវជ្រាវនេះមានដែនកំណត់ ដូចនេះយើងលើកយកតែចំណុចមួយចំនួនមកសិក្សាតែប៉ុណ្ណោះដែលទាក់ទងទៅនឹងប្រធានបទក្នុងនោះរួមមាន៖

- ការសិក្សាកំណត់អត្តសញ្ញាណ និងសក្តានុពលនៃការអនុវត្តអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ធៀបនឹងផែនការយុទ្ធសាស្ត្រ គោលនយោបាយដែលរដ្ឋាភិបាលបានដាក់ចេញ។
- ធ្វើការវាយតម្លៃរវាងប្រសិទ្ធភាពនៃការអនុវត្តអភិបាលកិច្ចរបស់ អាជ្ញាធរមូលដ្ឋានទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ។
- សិក្សាអំពីយុទ្ធសាស្ត្រ គោលការណ៍អភិបាលកិច្ចល្អ និងកំណែទម្រង់ដែលមានស្រាប់សម្រាប់ការអនុវត្តនាបច្ចុប្បន្ន និងអនាគត។
- សិក្សាស្វែងយល់ពីឥទ្ធិពលវិជ្ជមានក្នុងដំណើរការអនុវត្តការងារអភិបាលកិច្ចទាក់ទងនឹងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ។

លើសពីនេះដើម្បីវិភាគទិន្នន័យបឋម ការសិក្សាត្រូវបានកំណត់ ចំពោះទំហំសំណាកដែលមានអ្នកឆ្លើយតបសរុបគឺចំនួន ៣៨៩នាក់។ ដោយផ្អែកលើរូបមន្តគណនាទំហំសំណាកតាមស្ថិតិចំនួនសាកលភាព ដោយជ្រើសរើសយកភាពលលម្អៀង ៥%។ ទោះបីជាការសិក្សាបច្ចុប្បន្នមានកម្រិតក្នុងវិសាលភាព និងការគ្របដណ្តប់របស់វាក៏ដោយ ប៉ុន្តែការរក្សាការខិតខំប្រឹងប្រែង ពេលវេលាលទ្ធភាពទទួលបានទិន្នន័យ និងឧបសគ្គផ្សេងទៀត ការសិក្សានេះជាការប៉ុនប៉ងយ៉ាងពេញទំហឹងតាមទិសដៅនៃកម្មវត្ថុខាងលើ។

១.៧. គោលបំណង និងសារៈសំខាន់នៃការសិក្សា

ក្នុងការលើកយកប្រធានបទនេះមកសិក្សា គឺដោយមានគោលបំណងសំខាន់ចង់ស្វែងយល់អំពីឥទ្ធិពលជាក់ស្តែង ទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋផ្ទាល់មានលទ្ធផលបែបណា នៃការអនុវត្តន៍ការងារផ្តល់សេវាកម្ម របស់អាជ្ញាធរមូលដ្ឋាន ហើយមានភាពត្រឹមត្រូវទៅនឹងអ្វីដែលរដ្ឋាភិបាលបានដាក់ចុះឱ្យអនុវត្តកម្រិតណា។ គោលបំណងនៃការស្រាវជ្រាវ សំដៅដល់ប្រធានបទ និងចំណោទបញ្ហាដែលបានចោទឡើង បន្ទាប់មកវិភាគរកចំណុចខ្លាំង ចំណុចខ្សោយដើម្បីធ្វើការកែលម្អទៅលើចំណុចខ្វះខាតជាក់ស្តែង ព្រមទាំងធ្វើការសន្និដ្ឋានលើគ្រប់ចំណុចទាំងអស់រួមដោយការផ្តល់ជាគំនិតយោបល់ និងអនុសាសន៍ពីលើចំណុចដែលត្រូវកែលម្អ ឬបន្តអនុវត្តបន្ថែម។

ចំណែកឯសារៈសំខាន់នៅក្នុងប្រធានបទស្រាវជ្រាវ ដែលបានលើកយកមកធ្វើការសិក្សា គឺនឹងផ្តល់នូវខ្លឹមសារជាទូទៅ ដែលយើងត្រូវយកមកពិចារណាឱ្យមានការយល់ដឹងថាតើរវាងភាពគាប់ចិត្តពីសំណាក់អ្នកទទួលរងឥទ្ធិពលពីសមិទ្ធផលនៃកិច្ចការអភិបាលកិច្ច ទន្ទឹមនឹងអ្នកអនុវត្តការងារផ្ទាល់ក្នុងគុណភាពកម្រិតណា ហើយអភិបាលកិច្ចល្អមានផលប្រយោជន៍អ្វីខ្លះដល់អង្គភាពស្ថាប័នដែលបានយកមកសិក្សា មានគុណប្រយោជន៍បែបណាខ្លះមកលើប្រជាពលរដ្ឋក្នុងមជ្ឈដ្ឋាននិងមានអត្ថប្រយោជន៍យ៉ាងណា ពីការសិក្សារវាងទំនាក់ទំនងទ្រឹស្តីនឹងតថភាពជាក់ស្តែង ដែលជាកត្តាជះឥទ្ធិពលមកលើការអភិវឌ្ឍរីកចម្រើនរបស់មូលដ្ឋានផ្ទាល់ ក៏ដូចជាសង្គមជាតិទាំងមូល។

១.៨. គម្រោងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះចែកចេញជា ០៦ជំពូកដូចខាងក្រោម៖

- ជំពូកទី១៖ គោលបំណងនៃជំពូកនេះនឹងពិពណ៌នានូវផ្នែកមួយចំនួនដូចជា៖ សាវតានៃការសិក្សា ការថ្លែងបញ្ហា សំណួរស្រាវជ្រាវ គោលបំណងនៃការសិក្សា ការគាំងសម្មតិកម្ម សារៈសំខាននៃការសិក្សា វិសាលភាព និងកំណត់នៃការសិក្សា រួមទាំងគម្រោងនៃការសិក្សាដែល ជាមួយនឹងប្រធានបទ “ភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង”។
- ជំពូកទី២ ៖ គោលបំណងក្នុងជំពូកនេះ គឺពិនិត្យឡើងវិញនូវទ្រឹស្តីដែលមានទាក់ទងនឹងបញ្ហានៃកាសិក្សារស្រាវជ្រាវដោយចែកជា៣ផ្នែក៖ ផ្នែកទី១គឺការរំលឹកទ្រឹស្តីទស្សនទាន (Conceptual Literature) អំពីនិយមន័យនៃពាក្យគន្លឹះសំខាន់ៗ ទាក់ទងនឹងគុណភាពសេវាសាធារណៈ កត្តាដែលនាំឱ្យមានភាពរីកចម្រើន និងសក្តានុពលអភិវឌ្ឍលើអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាន ដែលសំដៅរកភាពពេញចិត្តរបស់ប្រជាពលរដ្ឋ។ នៅក្នុងទ្រឹស្តីដែលមានលក្ខណៈជាក់ស្តែង ឬជាបទពិសោធន៍ (Empirical Literature) ការសិក្សាផ្តោតលើសក្តានុពលនៃគុណភាពសេវាសាធារណៈដែលបានចូលរួមចំណែកទៅលើភាពពេញចិត្តរបស់ពលរដ្ឋនៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ជាចុងក្រោយនៃជំពូកនេះ គឺការសន្និដ្ឋានត្រូវបានផ្តល់ឱ្យក្នុងន័យសរុបសង្ខេបឡើងវិញ។
- ជំពូកទី៣៖ ជំពូកនេះ មានគោលបំណងសំខាន់គឺដើម្បីបង្ហាញពីការសិក្សាទៅលើយុទ្ធសាស្ត្រអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ដើម្បីបំពេញខ្លឹមសារជំពូកនេះត្រូវចែកជា៥ផ្នែក៖ ផ្នែកទី១ ប្រភេទនៃការវិភាគទិន្នន័យ ការកំណត់ទំហំសំណាក និងជ្រើសរើសសំណាក។ ផ្នែកទី២ អំពីប្រភពទិន្នន័យ ផ្នែកទី៣ អំពីឧបករណ៍ស្ថិតិនៃការស្រាវជ្រាវ រីឯផ្នែកទី៤ អំពីវិធីសាស្ត្រនៃវិភាគទិន្នន័យ និងផ្នែកទី៥ អំពីភាពជឿជាក់នៃសំណួរស្រាវជ្រាវ។
- ជំពូកទី៤៖ ការបង្ហាញអំពីការវិភាគទិន្នន័យដែលប្រមូលបានពីប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ជំពូកនេះចែកជា៣ផ្នែកគឺ៖ ទី១វិភាគពីព័ត៌មានអត្តសញ្ញាណអ្នកឆ្លើយតប ផ្នែកទី២ វិភាគអំពីមធ្យមមេគុណកំណត់រកប្រសិទ្ធភាពនៃភាពលំអៀង និងការរង្វាស់វិភាគតាម Regression ដើម្បីកំណត់រវាងទំនាក់ទំនងនៃអថេរឯករាជ្យ និងអថេរពឹងផ្អែក ហើយជាចុងក្រោយការបកស្រាយលទ្ធផលទទួលបានពីការវិភាគ។
- ជំពូកទី៥ ៖ គោលបំណងសំខាន់នៃជំពូកនេះ គឺដើម្បីសង្ខេបការរកឃើញចំណុចសំខាន់ៗនៃការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋាភិបាល។ ជំពូកនេះបង្ហាញពីឥទ្ធិពលនៃគោលយោបាយរបស់ភូមិ ឃុំដែលជាវិសាលភាព សម្រាប់ការសិក្សាស្រាវជ្រាវ និងធ្វើការសន្និដ្ឋានបន្ថែមទៀត។ សម្រាប់ជំពូកនេះ គឺត្រូវបានបែងចែកជា ៣ផ្នែក។ ដោយផ្នែកទី១ ទាក់ទងនឹងការរកឃើញនូវលទ្ធផលនៅក្នុងការសិក្សា ឯផ្នែកទី២ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងផ្នែកទី៣ ការស្រាវជ្រាវនាពេលអនាគត។

ជំពូកទី ២
ការរំលឹកទ្រឹស្តី

សេចក្តីផ្តើម

នៅក្នុងជំពូកទី២នេះ ខ្លឹមសារទាក់ទងនឹងការរំលឹកទ្រឹស្តី រួមមានជាពាក្យគន្លឹះ និយមន័យ ទស្សនៈ គោលគំនិតមួយចំនួនពីក្នុង និងក្រៅតំបន់មានភាពពាក់ព័ន្ធចំពោះអថេរជុំវិញនៃប្រធានបទ៖ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ដែលយើងបានលើកយកមកជាដើមចមនៃការសិក្សា។ ចំពោះជំពូកនេះមានជាការបែងចែកជាប្រាំផ្នែក។ ដោយនៅផ្នែកទី១៖ បង្ហាញអំពីពាក្យគន្លឹះ និយមន័យមួយចំនួន រួមទាំងអំពីគោលគំនិតសំខាន់ៗដែលទាក់ទងនឹងទ្រឹស្តី ដើម្បីជាជំនួយស្មារតីសម្រួលដល់ការបកស្រាយបន្ទាប់ក្នុងប្រធានបទ, ឯផ្នែកទី២៖ និយាយអំពីទ្រឹស្តីដែលមានលក្ខណៈជាក់ស្តែងពិតមួយចំនួនក្នុងការអនុវត្តន៍ ឬជាទ្រឹស្តីបែបពិសោធន៍ផ្អាល់សំដៅលើទិដ្ឋភាពនៃការអនុវត្តការងារអភិបាលកិច្ចរបស់មន្ត្រី ដែលបម្រើប្រយោន៍ជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ចំណែកឯផ្នែកទី៣៖ រៀបរាប់រំលឹកអំពីបទពិសោធន៍ខ្លះៗទៅលើវិធីសាស្ត្រស្រាវជ្រាវ របស់អ្នកសិក្សាមុនៗកន្លងមក, ផ្នែកទី៤៖ បង្ហាញពីគោលគំនិតនៃការសិក្សាស្រាវជ្រាវ ដោយចាត់ចេញជាអថេរឯករាជ្យ និងអថេរពឹងផ្អែក, និងផ្នែកទី៥៖ តាមរយៈការបកស្រាយរួចមានការសរុបសេចក្តីសន្និដ្ឋានដែលជាទីបញ្ចប់នៃជំពូក។

២.១. ពាក្យគន្លឹះ ឬនិយមន័យ

ជាជំហានបន្ទាប់ នៅក្នុងផ្នែកនេះយើងមកដឹងពីអត្ថន័យនៃពាក្យមួយចំនួនពាក់ព័ន្ធ ដែលនឹងត្រូវលើកយកមកបកស្រាយ ដើម្បីឱ្យកាន់តែភាពងាយស្រួលក្នុងការយល់ន័យខ្លឹមសារនៃ អត្ថបទជាបន្តនៅខាងមុខ ដែលពាក្យទាំងនោះមានដូចជា៖

២.១.១. អភិបាលកិច្ច

អភិបាលកិច្ច៖ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា៖ (CIDA) អភិបាលកិច្ច [...] គឺជាវិធីដែលអំណាចត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាល ក្នុងការគ្រប់គ្រងធនធានសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសមួយ (Policy for CIDA on Human Rights, Democratization and Good Governance, 1996)។ វិទ្យាស្ថានអភិបាលកិច្ច (IoG)៖ អភិបាលកិច្ចពាក់ព័ន្ធនឹងអន្តរកម្មរវាងរចនាសម្ព័ន្ធ ដំណើរការ និងប្រពៃណីកំណត់ថាតើអំណាចត្រូវបានអនុវត្តរបៀបណា ការសម្រេចចិត្តត្រូវបានអនុវត្ត និងរបៀបដែលប្រជាពលរដ្ឋ ឬកាគីពាក់ព័ន្ធផ្សេងទៀតមានប្រសាសន៍របស់ពួកគេ (Principles for Good Governance in the 21st Century, 2003)។ របាយការណ៍របស់គណៈកម្មការអភិបាលកិច្ចសកល៖ បុគ្គល និងស្ថាប័នសាធារណៈ និងឯកជន គ្រប់គ្រងកិច្ចការរួមរបស់ពួកគេ។ វាគឺជាដំណើរការបន្តដែលផលប្រយោជន៍ផ្អាល់ ឬប្រយោជន៍ចម្រុះអាចត្រូវប្រមូលផ្តុំ ហើយសកម្មភាពសហប្រតិបត្តិការអាចនឹងត្រូវបានធ្វើឡើង។ វារួមបញ្ចូលទាំងស្ថាប័ន និងរបបផ្លូវការដែលត្រូវបានផ្តល់សិទ្ធិអំណាចក្នុងការអនុវត្តការអនុលោមតាមច្បាប់ ក៏ដូចជាការរៀបចំក្រៅផ្លូវការដែលមនុស្ស និងស្ថាប័នបានយល់ព្រម ឬយល់ឃើញថាមានផលប្រយោជន៍សម្រាប់ពួកគេ (Our Global Neighborhood, 1995)។ គណៈកម្មការអឺរ៉ុប៖ អភិបាលកិច្ច សំដៅលើវិធាន

ដំណើរការ និងអាកប្បកិរិយាដែលផលប្រយោជន៍ជាក់ស្តែង ធនធានត្រូវបានគ្រប់គ្រង ហើយ អំណាចត្រូវបានប្រើប្រាស់នៅក្នុងសង្គម។ របៀបដែលមុខងារសាធារណៈត្រូវបានអនុវត្ត ធនធាន សាធារណៈត្រូវបានគ្រប់គ្រង និងអំណាចបទប្បញ្ញត្តិសាធារណៈត្រូវបានអនុវត្ត គឺជាបញ្ហាចម្បង ដែលត្រូវដោះស្រាយនៅក្នុងបរិបទនោះ។ តម្លៃពិតនៃគោលគំនិតនៃអភិបាលកិច្ច គឺវាផ្តល់នូវវាក្យស័ ព្ទដែលមានលក្ខណៈជាក់ស្តែងជាងលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ។ល។ ទោះបីជាមានលក្ខណៈ បើកចំហ និងទូលំទូលាយក៏ដោយ អភិបាលកិច្ចគឺជាគំនិតដ៏មានអត្ថន័យ និងជាក់ស្តែងទាក់ទងនឹង ទិដ្ឋភាពជាមូលដ្ឋាននៃ ដំណើរការនៃសង្គម និងប្រព័ន្ធនយោបាយ និងសង្គមណាមួយ។ វាអាចត្រូវ បានពិពណ៌នាថាជារង្វាស់ជាមូលដ្ឋាននៃស្ថិរភាព និងដំណើរការនៃសង្គមមួយ (Communication on Governance and Development, 2003)។ ធនាគារពិភពលោក៖ អភិបាលកិច្ចមានទំនៀម ទម្លាប់ និងស្ថាប័នដែលអាជ្ញាធរក្នុងប្រទេសមួយត្រូវបានអនុវត្ត។ នេះរួមបញ្ចូលទាំង (១) ដំណើរ ការដែលរដ្ឋាភិបាលត្រូវបានជ្រើសរើស ត្រួតពិនិត្យ និងជំនួស។ (២) សមត្ថភាពរបស់រដ្ឋាភិបាល ក្នុងការបង្កើត និងអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព។ និង (៣) ការគោរពរបស់ ប្រជាពលរដ្ឋ និងរដ្ឋចំពោះស្ថាប័នដែលគ្រប់គ្រងអន្តរកម្មសេដ្ឋកិច្ច និងសង្គមក្នុងចំណោមពួកគេ (World Bank, Governance Matters 2007:The Worldwide Governance Indicators)។ ធនាគារអភិវឌ្ឍន៍អាស៊ី៖ [អភិបាលកិច្ចគឺ] របៀបដែលអំណាចត្រូវបានអនុវត្តក្នុងការគ្រប់គ្រង ធនធានសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសមួយសម្រាប់ការអភិវឌ្ឍ (Governance: Sound Development Management, 1995)។ UNDP៖ អភិបាលកិច្ច ត្រូវបានចាត់ទុកដោយ UNDP ថាជាការអនុវត្តអំណាចសេដ្ឋកិច្ច នយោបាយ និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេសនៅ គ្រប់កម្រិត និងមធ្យោបាយដែលរដ្ឋលើកកម្ពស់ការរួបរួមសង្គម សមាហរណកម្ម និងជានាសុខុមាល ភាពរបស់ប្រជាជនរបស់ពួកគេ។ វាទទួលយកវិធីសាស្ត្រទាំងអស់ដែលត្រូវបានប្រើដើម្បីចែកចាយ អំណាច និងគ្រប់គ្រងធនធានសាធារណៈ និងអង្គការដែលបង្កើតរដ្ឋាភិបាល និងការអនុវត្តគោលន យោបាយ។ វារួមបញ្ចូលយន្តការ ដំណើរការ និងស្ថាប័នដែលប្រជាពលរដ្ឋ និងក្រុមបង្ហាញផល ប្រយោជន៍របស់ពួកគេ អនុវត្តសិទ្ធិស្របច្បាប់របស់ពួកគេ បំពេញកាតព្វកិច្ចរបស់ពួកគេ និងដោះ ស្រាយភាពខុសគ្នារបស់ពួកគេ (UNDP and Governance, Experience and Lessons Learned, 1997)។ អ្នកនិពន្ធផ្សេងៗនិយាយស្រដៀងគ្នាខ្លាំងណាស់។ ការវិភាគពីទស្សនៈនៃ គោលនយោបាយសាធារណៈ គឺជារឿងមួយដែលញឹកញាប់បំផុត។ នៅក្នុងគំនិតទាំងនេះ "អភិបាលកិច្ច" មិនត្រូវបានយល់ដូចជា: គោលនយោបាយនិងតួនាទីរបស់អ្នកនយោបាយ, ប៉ុន្តែ សង្កត់ធ្ងន់លើសំណើនៃគោលនយោបាយ ការអភិវឌ្ឍន៍សង្គម ឥទ្ធិពល និងប្រសិទ្ធភាព ការចូលរួម របស់តួអង្គជាច្រើនតាមដែលអាចធ្វើទៅបានសម្រាប់ការសម្រេចចិត្តរួមគ្នា និងប្រតិកម្មគ្រប់គ្រាន់ និងទាន់ពេលវេលាសម្រាប់ការរំញោចពីខាងក្រៅ (Rhodes 1996, Salomon 2002)។ អ្នកនិពន្ធ ផ្សេងទៀតសង្កត់ធ្ងន់ទៅលើអភិបាលកិច្ចសង្គម-នយោបាយដែលត្រូវបានប្រើសម្រាប់ទស្សនៈវិភាគ និងបទដ្ឋានសម្រាប់អភិបាលកិច្ចសង្គម "សមូហភាព" ទាំងអស់នៅក្នុងវិស័យសាធារណៈ ឯកជន ឬផ្នែកពលរដ្ឋ (Kooiman 2003)។ សំខាន់បំផុតគឺអន្តរកម្ម និងដំណើរការសង្គម។ ដូចដែលបាន បង្ហាញដោយ Levi-Faur (2011) អភិបាលកិច្ចអាចទទួលយកទម្រង់ដូចខាងក្រោម៖ អភិបាល

កិច្ចជារចនាសម្ព័ន្ធសំដៅទៅលើសំណុំផ្លូវការ និងក្រៅផ្លូវការនៃស្ថាប័នពាក់ព័ន្ធ។ អភិបាលកិច្ចជាដំណើរការដែលសំដៅទៅលើសក្តានុពល និងមុខងារឈានមុខគេដែលប្រព្រឹត្តទៅក្នុងដំណើរការបង្កើតគោលនយោបាយ។ អភិបាលកិច្ចជាយន្តការមួយដែលសំដៅទៅលើនីតិវិធីរបស់ស្ថាប័ននៃការសម្រេចចិត្តក៏ដូចជាការអនុលោមតាម និងការត្រួតពិនិត្យ។ ហើយអភិបាលកិច្ច ជាយុទ្ធសាស្ត្រដែលសំដៅទៅលើការរៀបចំរចនាស្ថាប័ន និងមេកានិចក្នុងគោលបំណងជះឥទ្ធិពលលើជម្រើស និងចំណូលចិត្ត។ ដោយសារភាពមិនច្បាស់លាស់នៃគោលគំនិតនៃអភិបាលកិច្ច និងទស្សនៈផ្សេងគ្នាដែលវាអាចត្រូវបានប្រើដើម្បីយោង វាពិបាកក្នុងការស្វែងរកនិយមន័យលើសលប់ (Grande, 2012)។ អត្ថន័យនៃអភិបាលកិច្ចនៅតែប្រែប្រួលអាស្រ័យលើវិធីសាស្ត្រស្រាវជ្រាវ វិន័យ និងបរិបទទ្រឹស្តី (Bevir, 2009)។

២.១.២. នីតិរដ្ឋ

នីតិរដ្ឋ គឺជាគោលគំនិតដែលពិពណ៌នាអំពីសិទ្ធិអំណាចកំពូលនៃច្បាប់លើសកម្មភាព និងអាកប្បកិរិយារបស់រដ្ឋាភិបាល ។ វាត្រូវគ្នាទៅនឹងស្ថានភាពមួយដែលទាំងរដ្ឋាភិបាល និងបុគ្គលត្រូវបានចងដោយច្បាប់ និងអនុវត្តតាមវា។ វាជាការប្រឆាំងនឹងរបបផ្តាច់ការ ឬការគ្រប់គ្រងតាមអំពើចិត្ត។ នីតិរដ្ឋ គឺជាផលិតផលនៃការអភិវឌ្ឍន៍ប្រវត្តិសាស្ត្រជាច្រើនសតវត្សមកហើយ ហើយត្រូវបានផ្សារភ្ជាប់ទៅនឹងការកើនឡើង នៃទម្រង់រដ្ឋាភិបាលបែបប្រជាធិបតេយ្យសេរីនៅលោកខាងលិច។ នីតិរដ្ឋ គឺជាប្រធានបទនៃទ្រឹស្តីប្រកួតប្រជែង។ សម្រាប់អ្នកខ្លះ គំនិតនេះមានអត្ថន័យផ្លូវការសុទ្ធសាធ។ នៅក្រោមគោលគំនិតនៃនីតិរដ្ឋនេះ រដ្ឋត្រូវតែធ្វើសកម្មភាពស្របតាមច្បាប់ដែលខ្លួនបានប្រកាសឱ្យប្រើ ហើយច្បាប់ទាំងនេះត្រូវតែបំពេញតាមចំនួនជាក់លាក់នៃលក្ខណៈអប្បបរមា។ គោលគំនិតមានន័យទូលំទូលាយជាងនេះ មានន័យថារួមបញ្ចូលនូវឧត្តមគតិនៃយុត្តិធម៌ និងមិនលម្អៀង។ អត្ថន័យបន្ថែមទៀតក៏អាចត្រូវបានកំណត់តាមគោលគំនិតតាមមនោគមវិជ្ជានយោបាយផ្សេងៗដែរ (Anthony Valcke, 2012)។ នីតិរដ្ឋជាគោលគំនិតប្រកួតប្រជែងមានសារៈសំខាន់ផ្ទាល់នៅក្នុងការគ្រប់គ្រងរដ្ឋណាមួយនៅកម្រិតទូទៅ ឬកម្រិតជាក់លាក់។ ភាពរឹងមាំនៃទិដ្ឋភាពស្ថាប័នគឺអាស្រ័យលើអំណាចទាំងបី រួមមានអំណាចប្រតិបត្តិ អំណាចនីតិបញ្ញត្តិ អំណាចតុលាការនៅក្នុងប្រទេសណាមួយ។ នៅប្រទេសខ្លះដែលនីតិរដ្ឋរឹងមាំ អំណាចទាំងបីត្រូវបានបំបែកចេញពីគ្នាចំណែកប្រទេសដែលគេស្គាល់ថាជារដ្ឋបរាជ័យ ឬរដ្ឋក្នុងសង្គ្រាមស៊ីវិល អំណាចទាំងបីត្រូវបានប្រើប្រាស់ខុស។ តាមទស្សនៈរបស់ពួកគេ Marks and Cooper (1988) ចង្អុលបង្ហាញ "ទោះបីជាគោលការណ៍នៃការបែងចែកអំណាចក៏ដោយ សាខានីមួយៗនៃរដ្ឋាភិបាលទាំងបីត្រួតលើគ្នាក្នុងកម្រិតខ្លះ។" តាមពិត នីតិរដ្ឋរឹងមាំត្រូវការមូលដ្ឋានច្បាប់រឹងមាំដែលជា "ក្របខ័ណ្ឌនៃ ប្រព័ន្ធរដ្ឋាភិបាល គឺជារដ្ឋធម្មនុញ្ញ។ ដោយសាររដ្ឋធម្មនុញ្ញអនុវត្តមុខងារសំខាន់ពីរ៖ ជាវិជ្ជមានវាបង្កើត និងរក្សាប្រព័ន្ធនៃអំណាចសាធារណៈ ហើយអវិជ្ជមានវាគ្រប់គ្រង និងគ្រប់គ្រងអំណាចសាធារណៈ រួមទាំងអំណាចរដ្ឋបាល ដោយកំណត់ព្រំដែន និងដែនកំណត់របស់វា(Cane, 2016, ទំ. 4) ។ នីតិរដ្ឋត្រូវបានគេអះអាងជាញឹកញាប់ថាជាកត្តាសំខាន់ បើមិនមានវាជាធាតុចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍអន្តរជាតិ ដែលជាគោលដៅអភិវឌ្ឍន៍ដ៏ចាំបាច់បំផុត ដោយនីតិរដ្ឋត្រូវបានគេគិតថាដើម្បីលើក

កម្ពស់គឺ កំណើនសេដ្ឋកិច្ច ការអនុលោមតាមច្បាប់ និងការគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស។ ដោយឡែក ជារឿយៗគេបានអះអាងថា ដរាបណាមន្ត្រីនៃរដ្ឋអនុលោមតាមនីតិរដ្ឋ រដ្ឋនោះជាធម្មតាទំនងជានឹងរីករាយនឹងកំណើនសេដ្ឋកិច្ច និងការអនុលោមតាមច្បាប់របស់ខ្លួន ក៏ដូចជានឹងប្រព្រឹត្តចំពោះសមាជិករបស់ខ្លួនជាមួយនឹង កម្រិតនៃការគោរពកាន់តែច្រើន។ ជាឧទាហរណ៍ យើងឃើញការអះអាងនីមួយៗ ក្នុងចំណោមការអះអាងទាំងបីនេះត្រូវបានឆ្លុះបញ្ចាំង នៅក្នុងសេចក្តីថ្លែងការណ៍បេសកកម្មរបស់មជ្ឈមណ្ឌល Bingham សម្រាប់នីតិរដ្ឋ ដែលពិពណ៌នាអំពីនីតិរដ្ឋ ថាជា "គោលគំនិតជាសកល និងជាក់ស្តែងដែលគាំទ្រការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ។" ដោយសារការអះអាងទាំងនេះ វាមិនមែនជារឿងចម្លែកទេដែលកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ បានកំណត់ការលើកកម្ពស់នីតិរដ្ឋជាគោលដៅចម្បងមួយនៃរបៀបវារៈនៃការអភិវឌ្ឍន៍ក្រោយឆ្នាំ 2015។

២.១.៣. តម្លាភាព

តម្លាភាពគឺជាតម្លៃសាធារណៈដែលទាមទារឱ្យប្រជាពលរដ្ឋត្រូវបានជូនដំណឹងអំពីរបៀបនិងមូលហេតុដែលការសម្រេចចិត្តត្រូវបានធ្វើឡើង រួមទាំងនីតិវិធី។ លក្ខណៈវិនិច្ឆ័យដែលបានអនុវត្តដោយអ្នកធ្វើសេចក្តីសម្រេចរបស់រដ្ឋាភិបាល កស្តុតាងដែលត្រូវបានប្រើដើម្បីឈានទៅដល់ការសម្រេចចិត្ត និងលទ្ធផល។ ជាញឹកញាប់តម្លាភាពសំដៅទៅលើការចូលប្រើដល់ព័ត៌មាន(Taryn Vian)។ តម្លាភាព មានន័យថាការសម្រេចចិត្តដែលបានធ្វើឡើង និងការអនុវត្តរបស់ពួកគេត្រូវបានធ្វើឡើងក្នុងលក្ខណៈមួយដែលអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ។ វាក៏មានន័យផងដែរថា ព័ត៌មានគឺអាចរកបានដោយសេរី និងអាចចូលប្រើប្រាស់ដោយផ្ទាល់សម្រាប់អ្នកដែលនឹងត្រូវបានប៉ះពាល់ដោយការសម្រេចចិត្តបែបនេះ និងការអនុវត្តរបស់ពួកគេ។ វាក៏មានន័យផងដែរថា ព័ត៌មានគ្រប់គ្រាន់ត្រូវបានផ្តល់ ហើយថាវាត្រូវបានផ្តល់ជាទម្រង់ និងប្រព័ន្ធផ្សព្វផ្សាយដែលអាចយល់បានយ៉ាងងាយស្រួល (UNESCAP 2009)។ តម្លាភាព សំដៅលើភាពអាចរកបានជាសាធារណៈនៃព័ត៌មានដែលអាចប្រើប្រាស់បាន។ នេះអាចកាត់បន្ថយហានិភ័យនៃអំពើពុករលួយ ដោយសារវាអនុញ្ញាតឱ្យមានការត្រួតពិនិត្យលើតួអង្គសាធារណៈ និងការសម្រេចចិត្តរបស់ពួកគេ។ រដ្ឋាភិបាលមានកាតព្វកិច្ចផ្តល់ភាពច្បាស់លាស់លើច្បាប់ និងលទ្ធផលនៃដំណើរការផ្តល់សេវាថែទាំសុខភាព និងបង្ហាញពីផលប្រយោជន៍បន្ទាប់បន្សំដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកផ្តល់សេវាថែទាំសុខភាព និងអ្នកបង្កើតគោលនយោបាយ (Vian T 2012, Paschke A. Dimancesco D. Vian T. et al 2018) ។ តម្លាភាពត្រូវបានចាត់ទុកថាជាកត្តាចាំបាច់ ទោះបីជាមិនមានលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់គណនេយ្យភាព និងការទប់ស្កាត់អំពើពុករលួយ [Fox J., Dev Pract 2007] ។

"អនុញ្ញាតឱ្យមានការពិតសម្រាប់អ្នកដទៃ ដើម្បីមើលឃើញថាតើគេជ្រើសរើសអ្វី ឬប្រហែលគិតគូឱ្យចេញជាអ្វីមួយ ឬមានពេលវេលាប៉ុណ្ណា មធ្យោបាយបែបណា និងជំនាញអ្វីដើម្បីបង្ហាញឱ្យឃើញ"។ អត្ថន័យថ្មីនៃតម្លាភាព ៖ ការបង្ហាញនៃសកម្មភាព។" (Oliver 2004)

២.១.៤. គណនេយ្យភាព

គណនេយ្យភាព គឺជាគុណតម្លៃសាធារណៈដែលទាមទារឱ្យស្ថាប័នរដ្ឋាភិបាលពន្យល់ និងធ្វើឱ្យយល់បាននូវការអនុវត្តរបស់ពួកគេក្នុងការសម្រេចបាននូវគោលដៅ និងការដោះស្រាយតម្រូវការសាធារណៈប្រៀបធៀបទៅនឹងស្តង់ដារ និងការប្តេជ្ញាចិត្ត។ វាតម្រូវឱ្យមានសកម្មភាពដែលមើលឃើញ និងឆ្លើយតប ប្រសិនបើស្តង់ដារ និងការប្តេជ្ញាចិត្តមិនត្រូវបានបំពេញ។ គណនេយ្យភាពសំដៅលើកាតព្វកិច្ចរបស់អ្នកដែលមានអំណាចក្នុងការពន្យល់ ធ្វើឱ្យយល់បាន និងទទួលខុសត្រូវចំពោះការសម្រេចចិត្ត សកម្មភាព និងការអនុវត្តរបស់ពួកគេ។ មន្ត្រីមានទំនួលខុសត្រូវក្នុងការធ្វើសកម្មភាពស្របតាមស្តង់ដារ និងការប្តេជ្ញាចិត្តដែលបានផ្សព្វផ្សាយជាសាធារណៈក្នុងទម្រង់នៃច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ នីតិវិធី និងគោលនយោបាយ (Paschke A. Dimancesco D. Vian T.et al. 2018)។ អ្នកជំនាញកត់សម្គាល់នូវធាតុផ្សំចំនួនបីនៃការទទួលខុសត្រូវ៖ 1) ទំនួលខុសត្រូវក្នុងការឆ្លើយតប ឬកាតព្វកិច្ចដើម្បីបង្ហាញពីភាពត្រឹមត្រូវនៃសកម្មភាពរបស់មនុស្សម្នាក់។ 2) ការអនុវត្ត, ផលវិបាកដែលដាក់ប្រសិនបើសកម្មភាពនិងយុត្តិកម្មមិនពេញចិត្ត; និង 3) ការឆ្លើយតប ឆន្ទៈរបស់អ្នកទទួលខុសត្រូវក្នុងការឆ្លើយតបទៅនឹងការទាមទារដែលបានធ្វើឡើង (Lambert-Mogiliansky A., J Dev Econ 2015)។ ការអនុវត្តត្រូវតែបង្កើតផលវិបាកដាក់គំនាបដល់ភ្នាក់ងារពុករលួយដែលមានទំហំធំល្មម ដើម្បីទប់ស្កាត់អំពើពុករលួយ (Klitgaard R, MacLean-Abaroa R. Parris HL.2000)។ គណនេយ្យភាពសង្គម អាចរួមបញ្ចូលនីតិវិធីសារទុក្ខ និងសវនកម្មសង្គម ដើម្បីប្រមូលទិន្នន័យប្រកបដោយគុណភាព និងបរិមាណលើមតិប្រជាពលរដ្ឋអំពី និងបទពិសោធន៍រស់នៅជាមួយសេវាកម្ម (Andersson N. 2011)។ គណនេយ្យភាពសាធារណៈមានន័យថា រដ្ឋាភិបាល និងនិយោជិតរបស់ខ្លួនមានទំនួលខុសត្រូវ ហើយសកម្មភាពរបស់ពួកគេត្រូវបានបើកចំហជាសាធារណៈ។ សរុបមក កំណត់ត្រានៃសកម្មភាពរបស់រដ្ឋាភិបាលគួរតែបើកចំហចំពោះប្រជាជន លុះត្រាតែវាពាក់ព័ន្ធនឹងសន្តិសុខរបស់ប្រទេស (Bovens, 2007:453)។ ទំនួលខុសត្រូវសាធារណៈ ផ្តល់នូវតួលេខគួរឱ្យទុកចិត្ត ទំនួលខុសត្រូវ យុត្តិធម៌ ភាពច្បាស់លាស់ ការប៉ុនប៉ងកែលម្អ និងគុណវុឌ្ឍិសីលធម៌របស់មន្ត្រីសាធារណៈ។ គណនេយ្យភាពសាធារណៈធានាថាសង្គមទទួលបានតម្លៃសម្រាប់ថវិការបស់ខ្លួន ហើយធនធានសាធារណៈមិនត្រូវបានបង្វែរទៅប្រើប្រាស់ឯកជនទេ (Ejere, 2012:19)។

២.១.៥. ការឆ្លើយតប

ការឆ្លើយតប សំដៅលើសមត្ថភាពរបស់ស្ថាប័ន និងមន្ត្រីសាធារណៈក្នុងការឆ្លើយតបទៅនឹងតម្រូវការ កង្វល់ និងចំណូលចិត្តរបស់សាធារណជនក្នុងលក្ខណៈទាន់ពេលវេលា និងសមស្រប។ វាជានាថាគោលនយោបាយ សេវាកម្ម និងការសម្រេចចិត្តឆ្លុះបញ្ចាំងពីការទាមទារ និងការរំពឹងទុករបស់ប្រជាជន ដោយជំរុញឱ្យមានទំនុកចិត្តលើដំណើរការអភិបាលកិច្ច។ ការឆ្លើយតបជាញឹកញាប់ត្រូវបានគេមើលឃើញថាជាគោលការណ៍សំខាន់នៃអភិបាលកិច្ចល្អ ព្រោះវាបញ្ជាក់ពីកាតព្វកិច្ចរបស់រដ្ឋក្នុងការបំពេញតម្រូវការស្របច្បាប់របស់ប្រជាពលរដ្ឋ និងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរតម្រូវការសង្គម។ ការឆ្លើយតបក៏ពាក់ព័ន្ធនឹងការបង្កើតយន្តការដែលប្រជាពលរដ្ឋអាច

បញ្ចេញនូវកង្វល់ និងការរំពឹងទុករបស់ពួកគេ ដែលបន្ទាប់មកត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការធ្វើការសម្រេចចិត្ត។ អ្នកប្រាជ្ញ និងអង្គការសំខាន់ៗបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការឆ្លើយតបក្នុងការគ្រប់គ្រងដូចជា៖ UNDP (1997) កំណត់ការឆ្លើយតបជាគោលការណ៍អភិបាលកិច្ច ដែលស្ថាប័ន និងដំណើរការនានាព្យាយាមបម្រើភាគីពាក់ព័ន្ធទាំងអស់ក្នុងចន្លោះពេលសមស្របមួយ។ Grindle (2007) ពន្យល់ពីការឆ្លើយតបជាសមត្ថភាពរបស់ស្ថាប័នអភិបាលកិច្ចក្នុងការស្តាប់ និងដោះស្រាយកង្វល់សាធារណៈ ដោយសង្កត់ធ្ងន់លើតម្រូវការសម្រាប់អភិបាលកិច្ចដែលអាចបត់បែនបាន និងសម្របខ្លួន។ ធនាគារពិភពលោក (1992) ក៏បានគូសបញ្ជាក់ផងដែរថា ការឆ្លើយតបក្នុងអភិបាលកិច្ចគឺអំពីរបៀបដែលសេវាសាធារណៈ និងគោលនយោបាយសមស្របទៅនឹងចំណូលចិត្ត និងតម្រូវការរបស់សង្គម ដោយជានានូវសមធម៌ និងបរិយាប័ន្ន។ Hyden, Court, and Mease (2004) ណែនាំថា ការឆ្លើយតបគឺជារង្វាស់នៃថាតើស្ថាប័នរដ្ឋាភិបាលមានប្រតិកម្មយ៉ាងណាចំពោះការទាមទាររបស់សង្គម ដែលមានសារៈសំខាន់សម្រាប់ទំនុកចិត្តសាធារណៈ និងអភិបាលកិច្ចប្រជាធិបតេយ្យ។ការឆ្លើយតប សំដៅលើសមត្ថភាពរបស់ស្ថាប័នគ្រប់គ្រង និងមន្ត្រីក្នុងការឆ្លើយតបទៅនឹងតម្រូវការ ចំណូលចិត្ត និងកង្វល់របស់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធក្នុងលក្ខណៈទាន់ពេលវេលា និងសមស្រប។ វាគឺជាធាតុផ្សំដ៏សំខាន់នៃអភិបាលកិច្ចល្អ ព្រោះវាជានាថាគោលនយោបាយសាធារណៈ សេវា និងសកម្មភាពនានាត្រូវបានស្របតាមផលប្រយោជន៍សាធារណៈ ហើយយន្តការផ្តល់យោបល់គឺស្ថិតនៅក្នុងកន្លែងដើម្បីដោះស្រាយបញ្ហាប្រឈម និងបញ្ហាដែលកំពុងកើតមាន។ យោងតាមគណៈកម្មការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) ការឆ្លើយតបគឺជា "សមត្ថភាពរបស់ស្ថាប័ន និងដំណើរការនានា ដើម្បីបម្រើភាគីពាក់ព័ន្ធទាំងអស់ក្នុងរយៈពេលដ៏សមស្របមួយ" (UNESCAP, 2009)។ នេះធានាថាប្រព័ន្ធអភិបាលកិច្ចនៅតែអាចសម្របខ្លួនបាន និងមានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ ជាពិសេសនៅពេលដោះស្រាយបញ្ហាកង្វល់សាធារណៈ។ OECD (2015) ចាត់ទុកការឆ្លើយតបជាធាតុស្នូលនៃអភិបាលកិច្ចសាធារណៈ ដែលរដ្ឋាភិបាលត្រូវតែអាចសម្របគោលនយោបាយ និងសេវាកម្មរបស់ពួកគេដោយផ្អែកលើធាតុចូលសាធារណៈ ដូច្នេះហើយការកែលម្អការជឿទុកចិត្តរវាងប្រជាពលរដ្ឋ និងស្ថាប័ន។ ការឆ្លើយតបក្នុងន័យនេះ គឺត្រូវបានភ្ជាប់ទៅទាំងប្រសិទ្ធភាព និងគណនេយ្យភាព ដោយជានាថា អភិបាលកិច្ចត្រូវបានតម្រង់ទិសឆ្ពោះទៅរកតម្រូវការវិវត្តនៃសង្គម។ Bevir (2013) កត់សម្គាល់ថា ការឆ្លើយតបតម្រូវឱ្យមន្ត្រីសាធារណៈបើកចំហចំពោះមតិយោបល់របស់ប្រជាពលរដ្ឋ និងកែប្រែសកម្មភាពរបស់ពួកគេស្របតាម។ វាពាក់ព័ន្ធនឹងយន្តការសម្រាប់ការស្តាប់ និងការឆ្លើយតប ដែលជំរុញឱ្យមានការចូលរួម និងតម្លាភាព ជាធាតុសំខាន់ៗនៃអភិបាលកិច្ចល្អ។ ដើម្បីឲ្យអភិបាលកិច្ចមានការឆ្លើយតបយ៉ាងពិតប្រាកដ លោក បេរី អះអាងថា ត្រូវតែមានការចូលរួមយ៉ាងស៊ីសង្វាក់គ្នាជាមួយប្រជាពលរដ្ឋ ដោយផ្តោតលើការស្តាប់សកម្ម និងការបង្កើតគោលនយោបាយដដែលៗ។ Graham, Amos, and Plumptre (2003) អះអាងថា ការឆ្លើយតបគឺមានសារៈសំខាន់ចំពោះអភិបាលកិច្ចល្អ ជាពិសេសនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ ដោយសារវាជានាថាស្ថាប័នសាធារណៈនៅតែទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ។ ពួកគេគូសបញ្ជាក់ថា រចនាសម្ព័ន្ធអភិបាលកិច្ចដែលឆ្លើយតបគឺមានសារៈសំខាន់ក្នុងការដោះស្រាយការតវ៉ាជាសាធារណៈ និងការរក្សាភាពស្របច្បាប់

នៃស្ថាប័នរដ្ឋាភិបាល ជាពិសេសនៅក្នុងសង្គមចម្រុះ។ Rothstein and Teorell (2008) ផ្តល់យោបល់ថា ការឆ្លើយតបត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងគុណភាពរបស់រដ្ឋាភិបាល ដោយកត់សម្គាល់ថា រដ្ឋាភិបាលដែលឆ្លើយតបមិនត្រឹមតែស្តាប់ប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាពដែលឆ្លុះបញ្ចាំងពីតម្រូវការរបស់សាធារណៈជនផងដែរ។ ពួកគេសង្កត់ធ្ងន់ថា ការឆ្លើយតបបង្កើនសមត្ថភាពរបស់រដ្ឋក្នុងការធ្វើសកម្មភាពក្នុងនាមប្រជាពលរដ្ឋរបស់ខ្លួន ការកែលម្អលទ្ធផលអភិបាលកិច្ច។

២.១.៦. ការចូលរួម

តម្លាភាពជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងការចូលរួម និងការពេញចិត្តរបស់ប្រជាពលរដ្ឋកាន់តែច្រើន។ នៅក្នុងប្រទេសកម្ពុជា គំនិតផ្តួចផ្តើមតម្លាភាពត្រូវបានណែនាំនៅកម្រិតផ្សេងៗ ប៉ុន្តែប្រសិទ្ធភាពរបស់ពួកគេនៅក្នុងតំបន់ជនបទដូចជាឃុំបវេល នៅតែមិនទាន់បានស្វែងយល់នៅឡើយ (Chheang, 2017)។ ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសកម្មភាពរបស់រដ្ឋាភិបាលមានកម្រិតជាញឹកញាប់ ដែលប៉ះពាល់ដល់ការពេញចិត្តរបស់ពួកគេចំពោះអភិបាលកិច្ច។ ទោះយ៉ាងណាក៏ដោយ មានការខ្វះខាតទិន្នន័យជាក់ស្តែង អំពីរបៀបដែលតម្លាភាពក្នុងដំណើរការធ្វើការសម្រេចចិត្តមានឥទ្ធិពលផ្ទាល់ទៅលើការពេញចិត្តរបស់ពលរដ្ឋនៅក្នុងទីឃុំបវេល។ ការស្រាវជ្រាវនាពេលអនាគតអាចស៊ើបអង្កេតពីរបៀបដែលការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានព័ត៌មាននៅកម្រិតមូលដ្ឋានប៉ះពាល់ដល់ការយល់ឃើញនៃគុណភាពអភិបាលកិច្ច។

៣. ទំនួលខុសត្រូវ៖

គណនេយ្យភាព ត្រូវបានទទួលស្គាល់ថាជាកត្តាសំខាន់ក្នុងការសម្រេចបាននូវអភិបាលកិច្ចល្អ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទនៃឃុំបវេល មានបញ្ហាប្រឈមក្នុងការធ្វើឱ្យមន្ត្រី

មូលដ្ឋានទទួលខុសត្រូវ ដោយសារយន្តការមានកម្រិតសម្រាប់មតិយោបល់របស់ប្រជាពលរដ្ឋ និងកង្វះសមត្ថភាពស្ថាប័ន (Hughes & Un, 2011)។ កង្វះនេះច្រើនតែនាំឱ្យពលរដ្ឋមិនពេញចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ អក្សរសិល្ប៍មិនទាន់បានដោះស្រាយឱ្យបានគ្រប់គ្រាន់នូវប្រសិទ្ធភាពនៃវិធានការគណនេយ្យភាពដែលមានស្រាប់នៅថ្នាក់ឃុំនោះទេ។ ការស្រាវជ្រាវគឺចាំបាច់ដើម្បីស្វែងយល់ពីរបៀបដែលការពង្រឹងយន្តការគណនេយ្យភាព អាចធ្វើអោយប្រសើរឡើងនូវការពេញចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងឃុំបវេល ជាពិសេសទាក់ទងនឹងការផ្តល់សេវាសាធារណៈ។

៤. ការឆ្លើយតប៖

ការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ គឺមានសារៈសំខាន់សម្រាប់ជំរុញការពេញចិត្តជាមួយនឹងអភិបាលកិច្ចមូលដ្ឋាន។ ការសិក្សាបង្ហាញថា រដ្ឋាភិបាលក្នុងតំបន់របស់កម្ពុជា រួមទាំងអ្នកនៅតាមតំបន់ជនបទដូចជាឃុំបវេលជារឿយៗ មានការតស៊ូក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ដោយសារឧបសគ្គធនធាន និងអសមត្ថភាពការិយាធិបតេយ្យ (Eng, 2019)។ កង្វះការឆ្លើយតបនេះអាចប៉ះពាល់ដល់ការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះប្រសិទ្ធភាពរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវមានកំណត់ ស្វែងយល់ពីរបៀបដែលការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាននៅក្នុងឃុំបវេល ប៉ះពាល់ដល់ការពេញចិត្តរបស់ប្រជាពលរដ្ឋ។ ការពិនិត្យស៊ីជម្រៅបន្ថែមទៀតអំពីរបៀបដែលរដ្ឋាភិបាលក្នុងតំបន់ដោះស្រាយបញ្ហាដូចជា ហេដ្ឋារចនាសម្ព័ន្ធ សេវាសុខភាព និងការអប់រំនឹងផ្តល់នូវការយល់ដឹងដ៏មានតម្លៃ។

៥. ការចូលរួម៖

ការចូលរួមត្រូវបានចាត់ទុកថាជាធាតុផ្សំដ៏សំខាន់នៃអភិបាលកិច្ចល្អ។ នៅក្នុងប្រទេសកម្ពុជា កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តក្នុងស្រុក ប៉ុន្តែបញ្ហាប្រឈមនៅតែមាន ជាពិសេសនៅតំបន់ជនបទ (Kim, 2016)។ នៅក្នុងឃុំបវេល ឱកាសសម្រាប់ការចូលរួមប្រកបដោយអត្ថន័យអាចមានកម្រិត ដែលអាចនាំឱ្យមានអារម្មណ៍នៃការមិនរាប់បញ្ចូល និងកាត់បន្ថយការពេញចិត្ត។ ខណៈពេលដែលមានគម្លាតគួរឱ្យកត់សម្គាល់ក្នុងការយល់ដឹងពីរបៀបដែលប្រជាពលរដ្ឋនៅក្នុងឃុំបវេលយល់ឃើញ និងចូលរួមក្នុងដំណើរការអភិបាលកិច្ច។ ការស្រាវជ្រាវអាចផ្តោតលើឧបសគ្គចំពោះការចូលរួម និងរបៀបដែលការកើនឡើងនៃឱកាសសម្រាប់ការចូលរួមអាចបង្កើនការពេញចិត្តជាមួយនឹងអភិបាលកិច្ចមូលដ្ឋាន។ ការពិភាក្សា និងចន្លោះប្រហោងទាំងនេះបង្ហាញពីតម្រូវការសម្រាប់ការស្រាវជ្រាវបន្ថែម ដោយផ្តោតលើរបៀបដែលការអនុវត្តអភិបាលកិច្ចល្អ ប៉ះពាល់ដល់ការពេញចិត្តរបស់ប្រជាពលរដ្ឋស្ថិតនៅក្នុងឃុំបវេល ដោយគិតគូរពីបញ្ហាប្រឈមជាក់លាក់ និងបរិបទនៃតំបន់។

២.៤. គោលគំនិតនៃការសិក្សា

តាមរយៈការរំលឹកទ្រឹស្តី ដែលបានលើកមកសិក្សា ទាក់ទងនឹងការអនុវត្តទ្រឹស្តីជាក់ស្តែងផ្សារភ្ជាប់ជាមួយនឹងប្រធានបទស្រាវជ្រាវរបស់យើងដែលបានលើកឡើងខាងលើអំពី ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង យើងទាញបានថា នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម ជាអថេរឯករាជ្យ(IV) ចំណែកឯភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ជើរតួជាអថេរពឹងផ្អែក (DV) ដូចដែលបង្ហាញខាងក្រោមនេះ៖

អថេរឯករាជ្យ (IV)



២.៥. សេចក្តីសន្និដ្ឋាន

អក្សរសិល្ប៍ស្តីពីផលប៉ះពាល់នៃអភិបាលកិច្ចល្អ (នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម) ស្តីពីការពេញចិត្តរបស់ប្រជាពលរដ្ឋនៅថ្នាក់រដ្ឋបាលមូលដ្ឋាន ជាពិសេសនៅឃុំបវេល បង្ហាញពីប្រធានបទទំនាក់ទំនងគ្នា ការជជែកវែកញែក
ការពិភាក្សា និងចន្លោះប្រហោងជាច្រើន៖

ប្រធានបទសំខាន់ គឺនិយាយអំពីរបៀបដែលគោលការណ៍នៃអភិបាលកិច្ចល្អរួមចំណែកដល់ការលើកកម្ពស់ការពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាកម្មរបស់រដ្ឋាភិបាលក្នុងតំបន់។ អភិបាលកិច្ចល្អត្រូវបានគេមើលឃើញថាជាគំនិតពហុភាគី ដែលវិមាត្រនីមួយៗ (នីតិរដ្ឋ តម្លាភាព

គណនេយ្យភាព ការឆ្លើយតប និងការចូលរួម) ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ទំនុកចិត្ត ការចូលរួម និងការពេញចិត្តជារួមរបស់ប្រជាពលរដ្ឋ។

មានការជជែកដេញដោលគ្នាជាបន្តបន្ទាប់លើរបៀបដែលវិមាត្រនីមួយៗនៃអភិបាលកិច្ចល្អ ប៉ះពាល់ដល់ការពេញចិត្តរបស់ប្រជាពលរដ្ឋ។ ខណៈពេលដែលអ្នកស្រាវជ្រាវខ្លះអះអាងថា ការអនុវត្តច្បាប់ដ៏តឹងរ៉ឹង និងតម្លាភាពកាន់តែច្រើន តែងតែនាំឱ្យមានការពេញចិត្តកើនឡើង (Uslaner, 2013; Fox, 2007) អ្នកផ្សេងទៀតបានលើកឡើងថា ប្រសិទ្ធភាពនៃកត្តាទាំងនេះ អាស្រ័យលើរបៀបដែលពួកគេត្រូវបានយល់ឃើញ និងអនុវត្តនៅថ្នាក់មូលដ្ឋាន។ (Lindstedt & Naurin, 2010)។ ជាឧទាហរណ៍ តម្លាភាពដោយគ្មានការទទួលខុសត្រូវ ឬការអនុវត្តច្បាប់ដោយគ្មានភាពយុត្តិធម៌ ប្រហែលជាមិនផ្តល់លទ្ធផលដែលចង់បានទាក់ទងនឹងការពេញចិត្តនោះទេ។

នៅក្នុងបរិបទកម្ពុជា ជាពិសេសនៅក្នុងឃុំបវេល ការសិក្សាបង្ហាញថា ខណៈពេលដែលក្របខ័ណ្ឌច្បាប់ និងរចនាសម្ព័ន្ធអភិបាលកិច្ចមាន បញ្ហាប្រឈមដូចជាការអនុវត្តមិនស៊ីសង្វាក់គ្នា កង្វះលទ្ធភាពទទួលបានព័ត៌មាន គណនេយ្យភាពមានកម្រិត ឧបសគ្គធនធាន និងការចូលរួមមានកម្រិតរារាំងដល់ប្រសិទ្ធភាពនៃគោលការណ៍អភិបាលកិច្ចទាំងនេះ (Un & Hughes, 2015; Eng, 2019)។ ដៃនកំណត់ទាំងនេះប៉ះពាល់ដល់របៀបដែលប្រជាពលរដ្ឋយល់ឃើញ និងទំនាក់ទំនងជាមួយរដ្ឋាភិបាលមូលដ្ឋាន ដែលជារឿយៗនាំឱ្យមានការមិនពេញចិត្ត។

អក្សរសិល្ប៍បង្ហាញពីចន្លោះប្រហោងសំខាន់ៗ ជាពិសេសទាក់ទងនឹងការស្រាវជ្រាវជាក់ស្តែងដែលផ្តោតលើឃុំបវេល។ មានការខ្វះខាតការសិក្សាលម្អិតដែលពិនិត្យមើលថាតើធាតុនីមួយៗនៃអភិបាលកិច្ចល្អមានឥទ្ធិពលលើការពេញចិត្តនៅក្នុងមូលដ្ឋានជាក់លាក់នេះយ៉ាងដូចម្តេច។ ជាឧទាហរណ៍ ខណៈពេលដែលមានការយល់ដឹងទូទៅអំពីបញ្ហាអភិបាលកិច្ចនៅក្នុងប្រទេសកម្ពុជា ការសិក្សាមួយចំនួនតូចបានស្វែងយល់ពីបញ្ហាប្រឈមពិសេសដែលឃុំជនបទជួបប្រទះ ដូចជាបវេល ទាក់ទងនឹងតម្លាភាព យន្តការគណនេយ្យភាព ការឆ្លើយតបទៅនឹងតម្រូវការក្នុងឃុំ និងឱកាសចូលរួមពិតប្រាកដ។

ការសំយោគអក្សរសិល្ប៍ដែលមានស្រាប់បង្ហាញថា ឥទ្ធិពលនៃអភិបាលកិច្ចល្អលើការពេញចិត្តរបស់ប្រជាពលរដ្ឋគឺស្មុគស្មាញ និងអាស្រ័យលើបរិបទ។ ខណៈពេលដែលគោលការណ៍នៃអភិបាលកិច្ចល្អត្រូវបានទទួលស្គាល់ជាសកល ថាមានសារៈសំខាន់សម្រាប់ការជំរុញការពេញចិត្ត ការអនុវត្តជាក់ស្តែង និងការយល់ឃើញរបស់ពួកគេនៅថ្នាក់មូលដ្ឋាន ដូចជានៅក្នុងឃុំបវេល ដើរតួយ៉ាងសំខាន់ក្នុងការកំណត់លទ្ធផល។ ការដោះស្រាយគម្លាតដែលបានកំណត់ ជាពិសេសតាមរយៈការធ្វើការសិក្សាតាមមូលដ្ឋាន និងជាក់ស្តែង នឹងផ្តល់នូវការយល់ដឹងកាន់តែច្បាស់អំពីវិធីបង្កើនការអនុវត្តអភិបាលកិច្ចល្អ ហើយជាលទ្ធផល ធ្វើអោយប្រសើរឡើងនូវការពេញចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងឃុំបវេល។

ជំពូកទី៣
វិធីសាស្ត្រនៃការស្រាវជ្រាវ

សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ គឺដើម្បីពន្យល់អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការសិក្សានាពេលបច្ចុប្បន្ន។ ជំពូកនេះបានចែកចេញជា ៥ផ្នែកធំៗដែលក្នុងនោះរួមមាន ផ្នែកទី១ ពន្យល់អំពីប្រភេទ នៃការវាយតម្លៃទៅលើប្រភេទនៃការសិក្សាស្រាវជ្រាវ រីឯផ្នែកទី២ ទី៣ និងទី៤ បង្ហាញអំពីទំហំគំរូ ប្រភេទ ប្រភព ធនធានប្រមូលទិន្នន័យ បង្ហាញពីឧបករណ៍សម្រាប់ស្រង់ស្ថិតិ និងវិភាគទិន្នន័យដែលប្រមូលបាន ចំណែកឯការសន្និដ្ឋាន ជាចំណុចបញ្ចប់នៃជំពូកនេះ។

៣.១. ប្រភេទនៃការវិភាគទិន្នន័យ

ប្រភេទនៃការវិភាគទិន្នន័យនេះ បានធ្វើឡើងក្នុងការសិក្សាគឺជាបរិមាណវិស័យនៅក្នុងធម្មជាតិ ហើយការវិភាគលើគំនិតយោបល់របស់មន្ត្រីរាជការក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅលើប្រសិទ្ធភាព នៃការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ក្នុងការសិក្សាស្រាវជ្រាវទាំងអស់ត្រូវប្រើប្រាស់ទិន្នន័យបឋមជាការស្ទង់មតិមន្ត្រី រាជការជាក់ស្តែង នៅក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ/សង្កាត់ និងត្រូវបានប្រើប្រាស់ការវិភាគទិន្នន័យបែបបរិមាណវិស័យ។ បរិមាណ ឬយើងស្គាល់ថាជាការវិភាគទិន្នន័យបែប Qualitative research និង Quantitative research។ ដោយផ្អែកលើទ្រឹស្តី និងប្រភេទនៃការវិភាគទិន្នន័យស្របតាមការសិក្សាផ្សេងៗទៀតដែលបានធ្វើការសិក្សាស្រាវជ្រាវលើគំនិតយោបល់របស់មន្ត្រីរាជការក្នុង រដ្ឋបាលថ្នាក់ក្រោមជាតិភាគច្រើនគេប្រើប្រាស់ការវិភាគតាមបែបបរិមាណវិស័យ ឬ Qquatitative research ដែលការវិភាគនេះនឹងផ្អែកលើលទ្ធផលដែលទទួលបានមកពីការសម្ភាសន៍ដែលប្រើ ជាទម្រង់សំណួរប្រភេទខ្លីៗ បែបយល់ស្រប ឬមិនយល់ស្រប នេះបើយោងតាមការសិក្សាស្រាវជ្រាវមួយដែលបង្ហាញពី ការរៀបចំបទសម្ភាសន៍ជាក្រុម ឬជាបុគ្គល ដើម្បីទទួលបានមតិ យោបល់ទៅលើអាកប្បកិរិយា បទពិសោធន៍ ការវាយតម្លៃទៅលើអត្តចរិត របស់អ្នកសម្ភាសន៍ ដើម្បីទទួលបានលទ្ធផលពិតប្រាកដជាក់ស្តែង (Rowley, 2012)។ យោងតាមការសិក្សាស្រាវជ្រាវ កន្លងមកបានបង្ហាញឱ្យឃើញពីភាពពាក់ព័ន្ធគ្នារវាងអ្នកស្រាវជ្រាវមុន និងប្រធានបទមួយនេះ ហេតុដូចនេះយើងបានជ្រើសរើសយកការវិភាគទិន្នន័យតាមបែបបរិមាណ ដើម្បីវាយតម្លៃលើប្រសិទ្ធភាពនៃ ការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ ត្រូវបានអនុវត្តតាមលក្ខណៈបរិមាណវិស័យ។ ជាពិសេសបន្ទាប់ពីការរៀបចំកម្រងសំណួរសម្រាប់សម្ភាសន៍ យើងនឹងធ្វើការសិក្សាទៅលើទំនាក់ទំនងរបស់កម្រងសំណួរនីមួយៗ ដើម្បីឲ្យដឹងថាមានភាពពាក់ព័ន្ធគ្នាប៉ុន្មានភាគរយ ហើយតើកម្រងសំណួរដែលបានសិក្សានោះអាចគ្របដណ្តប់អ្វីដែលយើងបានវិភាគដែរឬទេ ដោយធ្វើការសម្ភាសន៍សាកល្បងចំនួន ២៥ នាក់ជាមុនសិន។ ដោយបានពិចារណា លើកត្តាពេលវេលា និងការចូលរួមសហការឆ្លើយតបរបស់មន្ត្រីរាជការព្រមទាំងមានចំនួនអ្នកឆ្លើយតបខ្ពស់។ ដូចនេះវិធីសាស្ត្រនៃការស្រាវ ជ្រាវ គឺសមស្របសម្រាប់ការសិក្សាជាងគេ ហើយវិធីសាស្ត្រដែល

បានរចនាឡើងដើម្បីធ្វើការវាស់វែង និងសាកល្បងទិន្នន័យដែលមានពីមុនមកនោះ គឺមានការទាមទារចំនួនអ្នកឆ្លើយតបច្រើន។

៣.២. ទំហំ និងបច្ចេកទេសជ្រើសរើសសំណាក

ការប្រមូលសំណាក និងប៉ាន់គំរូគឺយើងជ្រើសរើសតែប្រជាពលរដ្ឋមួយចំនួនដែល បានកំណត់ថាពួកគាត់កំពុងរស់នៅក្នុង ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ចំពោះការវិភាគនេះ គឺត្រូវបានផ្តោតសំខាន់ទៅលើកត្តាកំណត់ នៃការចូលរួមសហការណ៍ដោយផ្ទាល់ អំពីសំណាក់វត្តមានរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ដែលមានឥទ្ធិពលទៅលើការអនុវត្តការងារអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន នៅក្នុងភូមិ ឃុំផ្ទាល់។ នៅក្នុងដំណាក់កាលគណនានេះ ការសិក្សាត្រូវស្គាល់កម្រិតជឿជាក់ក្នុងការគណនាដើម្បីទទួលបានសំណាកពិតប្រាកដ។ ក្នុងករណីការសិក្សានេះ ត្រូវបានបញ្ជាក់ជាភាគរយ និងតំណាងឱ្យចំនួនភាគរយពិតនៃ ចំនួនសាកលភាព (Population) ដែលនឹងជ្រើសរើសចម្លើយស្ថិតនៅក្នុងគម្លាតនៃភាពជឿជាក់។ នៅពេលដែលកម្រិតជឿជាក់ ៩៥% មានន័យថាលទ្ធផលនៃការគណនាទំហំ សំណាកអាចលម្អៀងនូវកម្រិត ៥%។ បើសិនជាកម្រិតជឿជាក់ ៩៩% មានន័យថាលទ្ធផលនៃការគណនាទំហំសំណាកអាចលម្អៀងនូវកម្រិត ១%។ សម្រាប់ករណីសិក្សា បច្ចុប្បន្ននេះ ការគណនារកទំហំសំណាក ត្រូវបានប្រើប្រាស់ក្នុងកម្រិតលម្អៀងនូវកម្រិត ៥ភាគរយដោយផ្អែកតាមរយៈរូបមន្តរបស់យ៉ាសមាន Yamane (1967) សម្រាប់គណនារកទំហំសំណាកដោយផ្អែកលើចំនួនសកលភាពប្រជាពលរដ្ឋសរុបនៅ ក្នុងឃុំចំនួន ៦,៧៧៤ នាក់ ។ សម្រាប់រូបមន្តដែលត្រូវប្រើដើម្បីគណនាគឺ៖ $n = \frac{N}{1+N(e)^2}$ ដែលក្នុងនោះ n ជាទំហំសំណាក, N ជាចំនួនប្រជាពលរដ្ឋ, e ជាកម្រិតលម្អៀង ៥%។ ដោយចំនួនប្រជាពលរដ្ឋនៅក្នុងឃុំ សរុបមាន ៦,៧៧៤នាក់ ដូច្នេះទំហំសំណាក គឺ $n = \frac{13515}{1+13515(0.05)^2} = 389$ នាក់ ។ នៅក្នុងលក្ខខណ្ឌនៃច្បាប់ទំហំសំណាក នៅក្នុងបរិបទធម្មតានៃការសិក្សាបែបចិត្តសាស្ត្រ ដែល ទាក់ទងនឹងការអង្កេតដែលពាក់ព័ន្ធនឹងបញ្ហា ខុតដែលពាក់ព័ន្ធនឹងបញ្ហាដូចជា ការធ្វើតេស្តសមត្ថភាព រង្វាស់អាកប្ប កិរិយា ឬបុគ្គលិកលក្ខណៈជាដើម ការសិក្សាអាចកំណត់បានដូចតទៅ៖ បើទំហំសំណាក (n)=១០០ មានន័យថា "គ្រប់គ្រាន់" ។ ប្រសិនបើទំហំសំណាកមានចំនួន (n) ២០០ ទទួលបានកម្រិត "ល្អ" និង ក្នុងករណីបើគណនាឃើញ ទំហំសំណាក (n) មានចំនួន ចាប់ពី400 ឡើងទៅគឺ "អស្ចារ្យ" ។ សំគាល់ កម្រិតនៃការគណនានៃច្បាប់ទាំងនេះគឺ យក ៥ ភាគរយ (Rules of Thumb for Minimum Sample Size for Multiple Regression, n.d.) ដូច្នេះសម្រាប់ទំហំសំណាកនៃការសិក្សាបច្ចុប្បន្ន គឺ ៣៨៩នាក់ ជាចំនួនដែលទទួលបាន កម្រិត "ល្អប្រពៃ" ហើយសម្រាប់ការសិក្សាប្រមូលទិន្នន័យ ។

នៅពេលដែលកំណត់ទំហំសំណាករួចស្រេចបាច់ បច្ចេកទេសជ្រើសរើសសំណាកបែបស្រទាប់ (Stratified Sampling) ត្រូវបានអនុវត្តដោយកំណត់យកចំនួន សាកលភាពរងជាចំនួនពលរដ្ឋនៅក្នុងភូមិនីមួយៗ ត្រូវបានហៅថាជាស្រទាប់(Strata) សម្រាប់គណនារកទំហំសំណាកក្នុងភូមិនីមួយៗ តាមរយៈរូបមន្ត Stratified Random Sample គឺ ៖ $n_k = \frac{n \times N_k}{N}$ ដែលក្នុងនោះមាន n_k = ចំនួនសំណាកក្នុងមួយភូមិនីមួយៗ, n = ទំហំសំណាករួម, N_k=ចំនួនប្រជាពលរដ្ឋក្នុង

មួយភូមិនីមួយៗ, N = ចំនួនពលរដ្ឋក្នុងឃុំ(១៨ឆ្នាំឡើង) ។ យើងប្រើប្រាស់រូបមន្តខាងលើដើម្បីគណនារកចំនួនសំណាកប្រជាជនក្នុងភូមិនីមួយៗ ។ ខាងក្រោមនេះជាតារាង ទំសំសំណាកតាមភូមិនីមួយៗនៅក្នុងឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង៖

ទំហំសំណាកនៃឃុំបវេល				
ល.រ.	ឈ្មោះភូមិ	ចំ.ប្រ.តាមភូមិ		ទំហំសំណាក
		ប្រ.សរុប	ប្រ.អាយុ១៨ឆ្នាំឡើង	
១	បវេល១	2335	1820	52
២	ដាច់ព្រំត្រ	1664	1432	41
៣	សង្កែវារ	1215	1043	30
៤	៣ម	1497	1257	36
៥	កំពង់ភ្នៅ	1575	1252	36
៦	ស្នឹងដាច់	1245	1021	29
៧	ស្ពានកណ្តាល	1357	1132	33
៨	សាំងរាំង	2029	1581	45
៩	ស្វាយជ្រុំ	1217	982	28
១០	ដូនអាវ	729	554	16
១១	សំរោងជ័យ	681	517	15
១២	ព្រៃតាឡូញ	1245	924	27
សរុប		16789	13515	389

យោងទៅតាមការគណនារកទំហំសំណាកដែលបានគណនាខាងលើ ចំពោះការសិក្សាស្រាវជ្រាវមួយនេះ គឺត្រូវការជ្រើសរើសយកសំណាកចំនួន ៣៨៩នាក់ ដែលស្ថិតនៅក្នុងចំណោមប្រជាជនចំនួន ១៣៥១៥នាក់ ដើម្បី ចូលរួមឆ្លើយនូវកម្រងសំណួរ។

៣.៣. ប្រភពទិន្នន័យ

ចំពោះប្រធានបទនេះ ដោយសារតែពាក់ព័ន្ធទៅនឹងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើការអនុវត្តន៍ការងារអភិបាលកិច្ច សេវាកម្មសាធារណៈនានារបស់អាជ្ញាធរមូលដ្ឋានឃុំបវេល ទើបយើងធ្វើការជ្រើសរើសយកសំណាកសម្រាប់វាយតម្លៃ នៅក្នុងទីតាំងសិក្សា ដែលត្រូវមានការចូលរួមពីប្រជាពលរដ្ឋដែលនៅក្នុងមូលដ្ឋានផ្ទាល់។ យើងធ្វើការប្រើប្រាស់ទិន្នន័យចម្បង (Primary data) ដែលជាទិន្នន័យមួយយើងអាចទទួលបានពីការសាកសួរ និងការសម្ភាសន៍ដោយផ្ទាល់ ឬមិនផ្ទាល់ពីសំណាក់ប្រជាពលរដ្ឋដែលមានចំនួន ៣៨៩នាក់ ដែលកំពុងមានវត្តមានផ្ទាល់នៅភូមិនានា ស្ថិតក្នុងឃុំបវេលបច្ចុប្បន្ននេះ។ សម្រាប់ការប្រើប្រាស់ទិន្នន័យបន្ទាប់បន្សំ (Secondary data) គឺជាទិន្នន័យមួយដែលយើង អាចប្រមូលបានពីឯកសារផ្សេងៗ ដែលឯកសារទាំងនោះរួមមានពីនៅក្នុង

បណ្តាញសង្គម តាមរបៀបសាយ ឬពីអាជ្ញាធរមូលដ្ឋានផ្ទាល់ និងបណ្ណាល័យនានាជាដើម ទិន្នន័យនេះត្រូវបានប្រមូលមកពី ការសិក្សាស្រាវជ្រាវពីមុនៗ មិនចំពោះតែទិន្នន័យដែលទទួលពាក់ព័ន្ធនឹងការសិក្សានៅទីតាំងដូចគ្នានោះទេ ប៉ុន្តែវាអាស្រ័យលើការសិក្សាផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងប្រធានបទរបស់យើង ដើម្បីធ្វើការប្រៀបធៀបអំពីភាពត្រឹមត្រូវនៃការសិក្សា ក៏ដូចជាពិនិត្យលើភាពប្រែប្រួលនៃសេវាកម្ម។ ទន្ទឹមនឹងនេះ ចំពោះកម្រងសំណួរត្រូវបានបែងចែកជា២ផ្នែកធំៗ រួមមាន៖ ផ្នែកទី១ អំពីទិន្នន័យជាព័ត៌មានផ្ទាល់ខ្លួន និងផ្នែកទី២ អំពីរង្វាស់ស្ទង់ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើការអនុវត្តអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន។

៣.៤. ឧបករណ៍វិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនៃទិន្នន័យដែលទទួលបានត្រូវបញ្ចូលទៅក្នុងកម្មវិធីSPSS26 និងវិភាគដោយប្រើស្ថិតិពណ៌នា។ លទ្ធផលនៃគំហើញមានឧបករណ៍ស្ថិតិត្រូវបានប្រើសម្រាប់ វិភាគទិន្នន័យដែលមានដូចជា៖

- ការវិភាគទី១៖ ចំពោះការវិភាគទៅលើអត្តសញ្ញាណ របស់អ្នកឆ្លើយតបទាំងអស់ គឺយើងធ្វើការប្រមូលទិន្នន័យ ដោយប្រើប្រាស់នូវឧបករណ៍ Frequency, Percent, Table, និង Graphទាំងបួននេះសម្រាប់វិភាគរក ភេទ អាយុ មុខរបរ ការអប់រំ និងកន្លែងស្នាក់នៅរបស់អ្នកចូលរួមឆ្លើយតប។
- ការវិភាគទី២៖ សម្រាប់ការវាយតម្លៃភាពពេញចិត្ត របស់ប្រជាពលរដ្ឋ និងប្រសិទ្ធភាពការងារអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ដោយប្រើប្រាស់ឧបករណ៍ Weight Arithmetic Mean សម្រាប់ក្នុងការវិភាគទិន្នន័យ។
- ការសិក្សាបានអនុវត្តមាត្រដ្ឋាន Likert ប្រាំចំណុចដើម្បីវាស់ស្ទង់ការយល់ឃើញរបស់អ្នកឆ្លើយតបដោយ៖

1 = មិនយល់ស្របយ៉ាងខ្លាំង (0.80-1.80), 2 = មិនយល់ស្រប (1.81-2.60), 3 = អព្យាក្រឹត (2.61-3.40), 4 = យល់ព្រម (3.41-4.20), និង 5 = យល់ព្រមយ៉ាងខ្លាំង (4.21 - 5.00) ។

Interpretation of Weighted Arithmetic Means of respondents' answer

Scale	ការឆ្លើយតប	ការបកស្រាយ
0.80-1.80	Strongly Dissatisfied	Strongly Disagree
1.81-2.60	Dissatisfied	Disagree
2.61-3.40	Neutral	Neutral
3.41-4.20	Satisfied	Agree
4.21 - 5.00	Strongly Satisfied	Strongly Agree

Source: Bell, Bryman, and Harley (2022)

- ការវិភាគទី៣៖ សម្រាប់ក្នុងការវិភាគនេះ គឺយើងប្រើប្រាស់ឧបករណ៍ពហុរីហ្គ្រេសិន (Regression) តាមរយៈកម្មវិធីវិភាគទិន្នន័យ SPSS26 Version27សម្រាប់ធ្វើការវាយតម្លៃអំពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។
    - Multiple Regression: $Y = b_0 + b_1X_1 + b_2X_2 + b_3X_3 + b_4X_4 + b_5X_5 + \varepsilon$
    - $Y =$ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ(Citizens Satisfaction)
    - $X_1 =$ នីតិរដ្ឋ (Rule of Law)
    - $X_2 =$ តម្លាភាព (Transparency),
    - $X_3 =$ គណនេយ្យភាព (Accountability)
    - $X_4 =$ ការឆ្លើយតប (Responsiveness)
    - $X_5 =$ ការចូលរួម (Participation)
    - b_1, b_2, b_3, b_4, b_5 are the Regression Coefficients of the slope of the independent variables of X_1: Rule of Law, X_2: Transparency, X_3: Accountability, X_4: Responsiveness, X_5: Participation

៣.៥. វិធីសាស្ត្រនៃការវិភាគទិន្នន័យ

ប្រសិន Kaiser-Meyer-Olkin នៃគំរូស្មើគ្នា ឬធំជាង 0.60 នោះយើងគួរតែបន្តជាមួយនឹងការវិភាគ កត្តារុករកគំរូដែលបានប្រើគឺគ្រប់គ្រាន់។ ប្រសិនបើការធ្វើតេស្តរបស់ Bartlett នៃស្វ៊ែរមានសារៈសំខាន់(p<0.05)យើងគួរតែបន្តជាមួយនឹងការវិភាគកត្តារុករកឬសម្រាំង(Admin,2022)។

គោលដៅសំខាន់នៃការស្រាវជ្រាវនេះ ពាក់ព័ន្ធនឹងការប្រើប្រាស់កត្តាវិភាគជាបច្ចេកទេសចម្បង។ កត្តាវិភាគបានប្រើប្រាស់ក្នុងគោលបំណងបង្ហាញអំពីទំហំទិដ្ឋភាពនៃការស្រាវជ្រាវនីមួយៗ ជ្រើសរើសធាតុកម្រង សំណួរជាមួយនឹងការផ្ទុកកត្តាខ្ពស់ និងកំណត់ភាពមិនស្របគ្នាណាមួយរវាងធាតុដែលបានជ្រើសរើស និងអ្វី ដែលបានលើកឡើងតាមទ្រឹស្តី។ ការវិភាគកត្តាគឺមានសារៈសំខាន់ជាពិសេសក្នុងការរកឃើញ "misfit" នៅក្នុងឧបករណ៍ស្រាវជ្រាវ (Questionnaire)។ លើសពីនេះទៅទៀត វាបានជើរតួនាទីយ៉ាងសំខាន់ក្នុងការសម្អាតធាតុង្វាស់ដើម្បីបញ្ជាក់ពីទំហំទិដ្ឋភាពនៃការធ្វើការស្រាវជ្រាវ និងភាពជឿជាក់បាន។ ការធ្វើតេស្តស ម្រាប់វាស់វែងរកភាពសក្តិសមសម្រាប់ទិន្នន័យទៅនឹងការកត្តាវិភាគ (Factor Analysis) ត្រូវហៅ Kaiser- Meyer-Olkin (KMO) និងការធ្វើតេស្តរបស់ Bartlett ភាគរយបន្ថែម (Cumulative percentage) សំណុំពិសេសនៃតម្លៃមាត្រដ្ឋាន (Eigenvalue) ទំនាក់ទំនងសរុប (Item-total correlation) និង ភាពជឿជាក់ ខាងក្នុង (Cronbach Alpha) ជាលទ្ធផលចេញមកពីការក្រុមអថេរវិភាគ (Factor Analysis) នៃធាតុង្វាស់ខាងក្រោមនេះ ជាលទ្ធផលនៃការរកភាពសក្តិសមនៃការក្រុមអថេរសម្រាប់វិភាគ ។

Variables	Sub-dimension	Citation
នីតិរដ្ឋ Rule of Law	ភាពច្បាស់លាស់ផ្នែកច្បាប់ គណនេយ្យ និងភាពតម្លាភាព ស្ថាប័នប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងយុត្តិធម៌ ការការពារសិទ្ធិមនុស្ស	(Grindle, Merilee S.2010)
តម្លាភាព Transparency	ភាពបើកចំហរបស់រដ្ឋាភិបាល ទទួលបានព័ត៌មានជាសាធារណៈ ការប្រាស្រ័យទាក់ទងច្បាស់លាស់ ការសម្រេចចិត្ត និងចូលរួមជាសាធារណៈ គណនេយ្យភាពសាធារណៈ និងតម្លាភាព នៃការអនុវត្តរបស់រដ្ឋាភិបាល	Florini, A. (2007) Hood, C. (2006)
គណនេយ្យភាព Accountability	ការឆ្លើយតប តម្លាភាព និងទំនួលខុសត្រូវ ផ្តល់ព័ត៌មាន និងទទួលមតិពីប្រជាពលរដ្ឋ	Warren (2010) Bouckaert &Van de Walle (2003)
ការឆ្លើយតប Responsiveness	ការឆ្លើយតបប្រកបដោយប្រសិទ្ធិភាព និង ផ្តល់ទំនុកចិត្ត អន្តរកម្មរវាងអាជ្ញាធរ និងពលរដ្ឋ ភាពបត់បែន សេវាទាន់ពេល ទំនួលខុសត្រូវ	Fukuyama (2013) Mansuri &Rao (2013)
ការចូលរួម Participation	សិទ្ធិចូលរួម បញ្ចេញមតិ ទទួលព័ត៌មាន និងតម្លាភាពនៃរដ្ឋាភិបាល សមភាពចំពោះមុខច្បាប់ សេរីភាពសហគមន៍ គណនេយ្យភាពនៃរដ្ឋាភិបាល និងការពារ សិទ្ធិប្រជាពលរដ្ឋ	OHCHR (2022) United Nations (2021) Kaufmann, Kraay &Mastruzzi (2020)

កូដ	ឯកត្តា **(Items)** នៃកម្រងសំណួរ
នីតិរដ្ឋ	
RLQ2	អាជ្ញាធរផ្តល់ប្រព័ន្ធការពារសិទ្ធិមនុស្ស ចំពោះរាល់គ្រប់ពលរដ្ឋដោយគ្មានការរើសអើង។

RLQ1	សកម្មភាពអនុវត្តការងារអភិបាលកិច្ចមូលដ្ឋាន ស្របទៅតាមទម្រង់ច្បាប់បម្រើផលប្រយោជន៍សាធារណជនជារួម។
RLQ4	អាជ្ញាធរអនុវត្តច្បាប់ ជូនពលរដ្ឋដោយយុត្តិធម៌ មិនលំអៀង និងគ្មានអំពើពុករលួយ។
RLQ3	មន្ត្រីអនុវត្តការងារ គោរពតាមទួនាទីស្របច្បាប់ សមហេតុផលជូនពលរដ្ឋ។
តម្លាភាព	
TQ4	អាជ្ញាធរបើកចំហរាល់សកម្មភាព អាចឲ្យប្រជាជនយល់ច្បាស់ពីអ្វីដែលគាត់កំពុងធ្វើ រួមទាំងរបៀបធ្វើ និងផ្តល់មូលហេតុដែលសកម្មភាពនោះកើតឡើង។
TQ3	អាជ្ញាធរជូននូវដំណឹង ព័ត៌មាន ឬសេចក្តីសម្រេចស្របច្បាប់នានា ដោយបើកចំហដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹង។
TQ1	អាជ្ញាធរតែងសម្រេចបង្កើតព័ត៌មាន លក្ខខណ្ឌ ឬសេចក្តីសម្រេចថ្មីណាមួយដោយទូទៅ និងមានប្រយោជន៍រួមចំពោះប្រជាពលរដ្ឋ។
TQ5	មន្ត្រីមិនប្រើអំណាចគាបសង្កត់ តែងផ្តល់សិទ្ធិ និងដោះស្រាយបញ្ហាជូនពលរដ្ឋគ្រប់រូប។
គណនេយ្យភាព	
AQ3	អាជ្ញាធរតែងទទួលខុសត្រូវរួមទៅលើសេចក្តីសម្រេចចិត្ត និងបម្រើការងារជូនប្រជាពលរដ្ឋ។
AQ1	អាជ្ញាធរមូលដ្ឋានមានទំនួលខុសត្រូវការងារ ឬសកម្មភាពនានាតាមតួនាទី និងឆ្លើយតបជាមួយពលរដ្ឋ ។
AQ4	អាជ្ញាធរតែងបង្ហាញរបាយការណ៍ ឬផ្តល់ដំណឹងនូវរាល់សកម្មភាព និងទិដ្ឋភាពនានាដែលកើតមានឡើងក្នុងមូលដ្ឋាន ឱ្យប្រជាពលរដ្ឋបានជ្រាប។
AQ2	អាជ្ញាធរតែងផ្សព្វផ្សាយដំណឹង ព័ត៌មានទូទៅ និងមានបណ្តាញទាក់ទងសម្រាប់ប្រជាពលរដ្ឋបញ្ចេញមតិ ឬកង្វល់ងាយដល់មន្ត្រីដោះស្រាយជូន។
ការឆ្លើយតប	
RQ4	អាជ្ញាធរមានភាពសកម្ម ក្នុងការកែសម្រួល និងដោះស្រាយបញ្ហា ឬការលំបាកនានាជូនប្រជាពលរដ្ឋ។
RQ2	អាជ្ញាធរផ្តល់ជូនសេវាកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព គុណភាពល្អទាន់ពេលវេលា និងផ្តល់ទំនុកចិត្តខ្ពស់ដល់ប្រជាពលរដ្ឋ។
RQ3	អាជ្ញាធរតែងមានការត្រៀមលក្ខណៈជាមុន សម្រាប់ដោះស្រាយបញ្ហាកើតឡើងភ្លាមៗ ជូនប្រជាពលរដ្ឋដោយមិនទុកបញ្ហាចោល។
RQ1	អាជ្ញាធរតែងតែឆ្លើយតបគ្រប់បញ្ហា ឬតម្រូវការចាំបាច់ជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលបានស្នើសុំ។

ការចូលរួម	
PQ4	អាជ្ញាធរតែងតែផ្សព្វផ្សាយ ឱ្យប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ពួកគាត់លើការអភិវឌ្ឍមូលដ្ឋាន។
PQ1	អាជ្ញាធរតែងតែប្រមូលព័ត៌មាន យល់ពីតម្រូវការពិតក្នុងមូលដ្ឋាន និងគិតគូដោះស្រាយជូនរបស់ប្រជាពលរដ្ឋ។
PQ2	អាជ្ញាធរ និងប្រជាពលរដ្ឋតែងមានសកម្មភាពអនុវត្តរួមគ្នាលើដំណើរការកសាងមូលដ្ឋានរបស់ខ្លួន។
PQ3	អាជ្ញាធរតែងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ឱ្យចូលរួមលើកិច្ចការសាធារណៈដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ពួកគាត់។
ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	
CSQ3	មន្ត្រីមានសមត្ថភាព ក្នុងការបំពេញសេវាកម្ម ដោះស្រាយបញ្ហា និងឆ្លើយតបសំណើតាមតម្រូវការប្រជាពលរដ្ឋ។
CSQ8	អាជ្ញាធរលើកស្ទួយសមធម៌ និងយកចិត្តទុកដាក់ទៅលើតម្រូវការខុសៗគ្នារបស់ប្រជាពលដ្ឋ។
CSQ6	ប្រជាពលរដ្ឋតែងមានសិទ្ធិចូលរួមសកម្មភាពចាំបាច់ក្នុងសង្គម និងអាចបញ្ចេញមតិវាយតម្លៃភាពពេញចិត្តទៅលើអភិបាលកិច្ចរបស់អាជ្ញាធរ។
CSQ7	អាជ្ញាធរមូលដ្ឋានផ្តល់ទំនុកចិត្ត មានទំនាក់ទំនងល្អ និងមានភាពស្និទ្ធស្នាលជាមួយប្រជាពលរដ្ឋ។
CSQ2	អាជ្ញាធរមូលដ្ឋានមានទំនួលខុសត្រូវ ស្មោះត្រង់ មានក្រម សីលធម៌ល្អ ក្នុងការបម្រើសេវាកម្មជូនប្រជាពលរដ្ឋ ។

៣.៦. សេចក្តីសន្និដ្ឋាន

ក្នុងដំណាក់កាលនេះ បង្ហាញអំពីលទ្ធផលដែលទទួលបានមកពីការស្ទង់មតិដែល យើងបានសិក្សាស្រាវជ្រាវនៃការប្រមូលទិន្នន័យ ពីសំណាក់ប្រជាពលរដ្ឋ ដែលកំពុងមានវត្តមានតាំងអាស្រ័យរស់នៅផ្ទាល់ក្នុងចំណោមបណ្តាភូមិទាំង១២ នៃឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ដើម្បីធ្វើការវិភាគ ទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីយកមកធ្វើការបកស្រាយ។

នៅក្នុងការរៀបចំជំពូកទី០៣ បានបង្ហាញអោយយើងមើលឃើញកាន់តែជាក់លាក់ និងមានភាពងាយស្រួលក្នុងការសម្រេចចិត្តអំពីវិធីសាស្ត្រក្នុងការស្រាវជ្រាវដែល មានភាពងាយស្រួលនិងប្រទាក់ក្រឡាគ្នាក្នុងការរៀបចំឯកសារស្រាវជ្រាវ ជាពិសេសមានភាពងាយស្រួលក្នុងការងារកំណត់សមាសភាពសំណាក ថាតើត្រូវការចំនួនសំណាកប៉ុន្មានដើម្បីការស្រាវជ្រាវមួយនេះ។ ជាក់ស្តែងនៅក្នុងឯកសារនេះយើងនឹងធ្វើ ការស្រាវជ្រាវតាមការវិភាគជាលក្ខណៈបរិមាណវិស័យ

(Quantitative Research) ហើយទំហំសំណាកដែលយើងគណនាបានពីចំណោមប្រជាពលរដ្ឋក្នុងឃុំដែលត្រូវយកមកវិភាគ គឺមានចំនួនរហូតដល់ ៣៨៩នាក់ ដែលនឹងត្រូវសម្ភាសន៍។ ដោយឡែកទិន្នន័យ ត្រូវបានប្រមូលដោយផ្ទាល់តាមរយៈការសាកសួរសំណួរ និងសម្ភាសន៍ពីប្រជាពលរដ្ឋក្នុងឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង និងមួយផ្នែកទៀតត្រូវបានប្រមូលពីការសិក្សាស្រាវជ្រាវកន្លងមក ដើម្បីធ្វើការប្រៀបធៀបអំពីភាពត្រឹមត្រូវនៃការសិក្សាស្រាវជ្រាវ ក៏ដូចជាការពិនិត្យលើភាពប្រែប្រួលនៃសេវាកម្ម បន្ទាប់ពីទទួលបានទិន្នន័យដែលប្រមូលរួចមក យើងនឹងធ្វើការវិភាគតាមរយៈ SPSS26។

ជំពូកទី៤
អំពីគោលការណ៍អភិបាលកិច្ចល្អ និងទស្សនៈទានកំណែទម្រង់វិជ្ជការ និងសហមជ្ឈការនៅកម្ពុជា

៤.១. គោលការណ៍អភិបាលកិច្ចល្អ

សេចក្តីផ្តើម

អភិបាលកិច្ចល្អ ជាផ្នែកមួយយ៉ាងសំខាន់ក្នុងការជំរុញ និងគាំទ្រដំណើរការ នៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍមួយប្រកបដោយ និរន្តរភាព។ អភិបាលកិច្ចដែលប្រកបដោយសុកវិនិច្ឆ័យ គឺជាអភិបាលកិច្ចល្អ ដោយការចាត់ចែង និងការគ្រប់គ្រងបញ្ហា និងធនធានសាធារណៈ ប្រកបដោយប្រសិទ្ធភាព ហើយឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍របស់សង្គមជាតិទាំងមូល ។

ភាពត្រឹមត្រូវតាមគោលនយោបាយ គឺជាលក្ខខ័ណ្ឌចាំបាច់ដំបូងគេបំផុត នៃអភិបាលកិច្ចល្អ។ ភាពត្រឹមត្រូវតាមគោលនយោបាយ ត្រូវបានពិចារណា ដោយផ្តោតជាសំខាន់ទៅលើកត្តាពីរយ៉ាងគឺ : ១)-ការគាំទ្រដោយប្រជាពលរដ្ឋ ភាគច្រើនបំផុត ឬទាំងអស់ និង ២) -ការបម្រើផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ភាគច្រើនបំផុត ឬទាំងអស់ ។ បើរដ្ឋ ស្ថាប័ន ឬអង្គភាព មិនមានភាពត្រឹមត្រូវតាមគោលនយោបាយទេ នោះយើងមិនអាចនិយាយអំពីអភិបាលកិច្ចល្អបានឡើយ។

ដោយយល់ឃើញពីសារៈសំខាន់នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថា "អភិបាលកិច្ចល្អ គឺជាបុរេលក្ខខ័ណ្ឌសំខាន់បំផុតមួយ ដើម្បីធានាឱ្យមាន ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ក្នុងសង្គម" ។ ផ្អែកលើសារៈសំខាន់នៃអភិបាលកិច្ចល្អ រាជរដ្ឋាភិបាល បាននឹងកំពុងបន្តអនុវត្តផែនការសកម្មភាពអភិបាលកិច្ចល្អ ដោយបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ចូលគោលការណ៍នៃអភិបាលកិច្ចល្អទៅក្នុង ក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីឆ្ពោះទៅរកការអភិវឌ្ឍ ប្រទេសប្រកបដោយជោគជ័យ ។

៤.១.១. និយ្ជតាពក្ងេនៃអភិបាលកិច្ចល្អ

ក. និយមន័យ

អភិបាលកិច្ចល្អ ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនអាស្រ័យនឹង ស្ថានភាពជាក់ស្តែង។ ជាសាមញ្ញអភិបាលកិច្ចល្អមានន័យថា៖ "ជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខដើម្បីបម្រើប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ" ។

ស្រដៀងគ្នានេះដែរ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP 1997) បានឱ្យនិយមន័យថា "អភិបាលកិច្ចល្អ ជាការប្រើប្រាស់អំណាចខាងនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស"។

ខ. គោលបំណងនៃអភិបាលកិច្ច

គោលបំណងនៃអភិបាលកិច្ចល្អ គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយ ដែលផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនបំផុត ដល់ប្រជាពលរដ្ឋ។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើនេះ គេបានទទួលស្គាល់ជាទូទៅថា អភិបាលកិច្ចល្អ ទាមទារនូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព ។ ចំណុចសំខាន់ៗនៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព មានដូចខាងក្រោម៖

- ត្រូវមានសេវាថែទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាជនទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខភាពមាំមួន និងអាយុយឺនយូរ ។ នេះជា កត្តាដែលអាចធ្វើឱ្យប្រជាពលរដ្ឋ មានសុខុមាលភាព និងថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមបានយ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ។
- ត្រូវមានសេវាអប់រំល្អសមស្រប និងគ្រប់គ្រាន់សម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីឱ្យពួកគេមានចំណេះដឹង និងជំនាញពេញលេញក្នុងការបង្កើតឱកាស ឱ្យបានច្រើន និងសមស្របបំផុតសម្រាប់ខ្លួនគេ។
- ត្រូវបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផល ប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើ ដើម្បីរកបានប្រាក់ចំណូល គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជា ស្បៀងអាហារ សំលៀកបំពាក់ ជម្រក ជាដើម សម្រាប់ពួកគេផ្ទាល់ និងក្រុមគ្រួសារ របស់ពួកគេ។

គ. តួអង្គសំខាន់ៗ ក្នុងអភិបាលកិច្ចល្អ

កាលពីមុនគេយល់ឃើញថា មានតែរដ្ឋាភិបាលមួយគត់ ដែលជាតួអង្គនៃ អភិបាលកិច្ចល្អ ។ ប៉ុន្តែបច្ចុប្បន្ននេះ មានគំនិតថ្មីៗជាច្រើនបានបង្ហាញឱ្យឃើញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀតក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ។ ដូចនេះតួអង្គ សំខាន់ក្នុងអភិបាលកិច្ចល្អ មានបីគឺ៖

- ស្ថាប័នរដ្ឋ (ស្ថាប័ននយោបាយ និងរដ្ឋាភិបាល: ជាតួអង្គសំខាន់ជាងគេ)
- ផ្នែកឯកជន
- សង្គមស៊ីវិល

ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និងសង្គមស៊ីវិល មានភាពខុសគ្នាពី ប្រទេសមួយទៅប្រទេសមួយអាស្រ័យលើលក្ខខ័ណ្ឌមួយចំនួនដូចជាប្រព័ន្ធនយោបាយលក្ខណៈអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំង ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច ។ល។

៤.១.២. គោលការណ៍អភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រង សេដ្ឋកិច្ច សង្គមកិច្ច និងសន្តិសុខ ដើម្បីបម្រើផលប្រយោជន៍ រួមរបស់ប្រជាពលរដ្ឋ ដោយបំពេញនូវ គោលការណ៍ទាំង ៩ ដូចខាងក្រោមនេះ៖

ទី១ ការចូលរួម

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ សំដៅទៅលើការចូលរួមរបស់ ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី (អាជ្ញាធរ ប្រជាពលរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល នានា និងអ្នកពាក់ព័ន្ធផ្សេងៗទៀត) ក្នុង ដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្ត សេចក្តីសម្រេចចិត្តនោះ។ សារៈសំខាន់នៃការចូលរួម គឺ ដើម្បីធានាថា ព័ត៌មាន ទាំងឡាយស្តីពីបញ្ហាតម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូប ត្រូវបាន ប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចិត្ត។ ជាទូទៅ ការចូលរួមធ្វើ ឡើងតាម ២របៀប គឺការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង ។

❖ **ការចូលរួមដោយផ្ទាល់**

ការចូលរួមដោយផ្ទាល់ មានន័យថា ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូប ដោយខ្លួនឯង ផ្ទាល់ នៅក្នុងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តី សម្រេចចិត្តនោះ ។ ក្នុងរបប ប្រជាធិបតេយ្យ ប្រជាពលរដ្ឋ មានសិទ្ធិចូលរួមដោយផ្ទាល់ ពាក់ព័ន្ធទៅនឹងកិច្ចការសាធារណៈ និង នៅក្នុងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ដូចជា៖

- ការបោះឆ្នោត
- ការចូលរួមក្នុងគណបក្សនយោបាយ
- ការឈរឈ្មោះបោះឆ្នោត
- ការបង្កើតសមាគម សហគមន៍នានា
- ការចូលរួមនៅក្នុងដំណើរការ និងធ្វើសេចក្តីសម្រេចចិត្តនៅក្នុងការកសាងផែនការអភិវឌ្ឍ ន៍មូលដ្ឋានរបស់ខ្លួន
- ការចូលរួមជាកម្លាំងពលកម្ម និងធនធានរបស់ប្រជាពលរដ្ឋ នៅក្នុង សកម្មភាពអភិវឌ្ឍន៍ មូលដ្ឋានរបស់ខ្លួន ក៏ចាត់ទុកជាការចូលរួមដោយផ្ទាល់ដែរ។ល។

❖ **ការចូលរួមតាមរយៈអ្នកតំណាង**

ការចូលរួមតាមរយៈអ្នកតំណាង មានន័យថា អ្នកតំណាងរបស់ប្រជាពលរដ្ឋ ចូលរួមក្នុង ដំណើរការនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះ។ អ្នកតំណាង ត្រូវតែបំពេញតួនាទីជា អ្នកតំណាងឱ្យឆន្ទៈ និងផលប្រយោជន៍ ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ។ អ្នកតំណាងប្រជា ពលរដ្ឋអាចត្រូវបានជ្រើសរើសតាមនីតិវិធីផ្សេងៗ ទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងដូចជា:

- ការតែងតាំង ឬការជ្រើសរើសដោយមានការព្រមព្រៀងឯកភាពគ្នា
- ការបោះឆ្នោតសកល ឬអសកល (សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជ ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់)
- ទំនៀមទំលាប់ប្រពៃណី ។ល។

ក្នុងការជ្រើសរើសអ្នកតំណាង ត្រូវពិចារណាចំណុចមួយចំនួន ដូចខាងក្រោម :

- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានសមត្ថភាព និងលទ្ធភាពអាច បំពេញតួនាទីជាអ្នកតំណាងបាន
- ជាតំណាងពិតប្រាកដឱ្យក្រុមជាក់លាក់ណាមួយ
- ជ្រើសរើស ឬតែងតាំងអ្នកតំណាងទៅតាមនីតិវិធីដែលសមស្របនឹងស្ថានភាពជាក់ស្តែង
- កំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់
- មានផែនការការងារច្បាស់លាស់
- មាននីតិវិធីផ្លាស់ប្តូរសមាជិកអ្នកតំណាងច្បាស់លាស់
- មានកម្មវិធីពង្រឹងសមត្ថភាព និងការគាំទ្រជាប្រចាំដល់អ្នកតំណាង។ល។

វិធីសាស្ត្រដើម្បីជំរុញការចូលរួម : ដើម្បីជំរុញឱ្យសកម្មភាពចូលរួមកាន់តែមានភាពប្រសើរឡើង និងដើម្បីធានាឱ្យប្រជាពលរដ្ឋ និងអ្នកតំណាងរបស់ ប្រជាពលរដ្ឋមានឱកាសចូលរួមយ៉ាងពេញលេញ ជាពិសេសតំណាងក្រុមអ្នកក្រីក្រ ក្រុមស្ត្រី និងក្រុមងាយរងគ្រោះ។ ចំណុចមួយចំនួនដែលគួរពិចារណា មានដូច ខាងក្រោម :

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួម របស់ពួកគេ
- ផ្សព្វផ្សាយព័ត៌មានស្តីពីកិច្ចប្រជុំ និងព័ត៌មានផ្សេងៗឱ្យបានទូលំទូលាយ ដល់ប្រជាពលរដ្ឋ
- កំណត់ពេលវេលា និងទីកន្លែងប្រជុំឱ្យបានសមស្រប
- បង្កបរិយាកាសនៃការប្រជុំឱ្យមានលក្ខណៈជាចំហ មានការចូលរួមយ៉ាង ផុលផុស និងសប្បាយរីករាយ
- រៀបចំទីកន្លែងប្រជុំប្រកបដោយផាសុខភាព
- រៀបចំឱ្យមានប្រព័ន្ធទទួល និងផ្តល់ព័ត៌មានដែលមានលក្ខណៈងាយៗ និង អាចទទួលយកបាន
- បង្កើតទំនាក់ទំនងល្អ និងស្និទ្ធស្នាលជាមួយប្រជាពលរដ្ឋ ។ល ។

ទី២ នីតិរដ្ឋ

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារឱ្យមានឯកសារក្របខ័ណ្ឌច្បាប់ គ្រប់គ្រាន់ ដើម្បីបម្រើ និងការពារផលប្រយោជន៍សាធារណៈ ការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬក្រុមភាគតិច ហើយច្បាប់ទាំងនោះត្រូវបានអនុវត្ត ដោយមិនលំអៀង។ លើសពីនេះទៀត ត្រូវមានប្រព័ន្ធទទួលខុសត្រូវ មានប្រព័ន្ធ តុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ ។ នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អផ្តោតជាសំខាន់ទៅលើ :

- ឯកសារក្របខ័ណ្ឌច្បាប់
- ការការពារសិទ្ធិមនុស្ស
- ប្រព័ន្ធទទួលខុសត្រូវ
- ប្រព័ន្ធយុត្តិធម៌

- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ ។

ទី៣ តម្លាភាព

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អមានន័យថា រាល់ការសម្រេចចិត្ត និង ការអនុវត្តសេចក្តីសម្រេចនោះ ត្រូវធ្វើឡើង :

- ដោយអនុលោមទៅតាមច្បាប់ និងបទដ្ឋាននានា
- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្ត ត្រូវផ្សព្វផ្សាយជាចំហ តាមរយៈ ប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេស ចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តទាំងនោះ
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់ ។

ទី៤ ការព្រមព្រៀងឯកភាពគ្នា

ការព្រមព្រៀងឯកភាពគ្នាក្នុងន័យ អភិបាលកិច្ចល្អ គឺជាការពិចារណា ទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធ ផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសម្រេចចិត្តដោយមានការព្រមព្រៀង ឯកភាពគ្នាលើជំរើស និងវិធីសាស្ត្រល្អណាមួយ ដែលបម្រើផលប្រយោជន៍ សាធារណៈ ។

ទី៥ សមធម៌

សមធម៌ក្នុងន័យអភិបាលកិច្ចល្អមានន័យថា ក្រុម ឬជនគ្រប់រូបទាំងអស់ ជាពិសេស ក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះ មានឱកាសគ្រប់គ្រាន់ នៅក្នុងការចូលរួមបញ្ចេញយោបល់លើកឡើងនូវតម្រូវការពិត អនុវត្ត សកម្មភាព និងទទួលផលប្រយោជន៍សមស្រប ដើម្បីកែលំអ និងថែរក្សាសុខុមាលភាពរបស់ ពួកគេ។ លើសពីនេះទៀត ពួកគេមានអារម្មណ៍ថា ខ្លួនគឺជាសមាជិកពិតប្រាកដ របស់សង្គម និងមិនត្រូវបានសង្គមបោះបង់ចោលនោះទេ។ សុខុមាលភាពរបស់សមាជិក ឬក្រុមនីមួយៗ គឺជាសុខុមាលភាពរបស់ សង្គមទាំងមូល ។ ដូចនេះ ដំណើរការនៃការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តប្រកបដោយសមធម៌ នឹងធ្វើឱ្យគ្រប់សមាជិកទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ ថា ពួកគេម្នាក់ៗ គឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែកនៅក្នុង ដំណើរការអភិវឌ្ឍន៍សង្គមនោះ ។ លើសពីនេះទៀត មិនមានសមាជិកណាម្នាក់គិតថា ខ្លួនគេត្រូវបានសង្គមបោះបង់ចោលឡើយ។ សុខុមាលភាព ផ្តោតជាសំខាន់ទៅលើ ភាពសប្បាយ ភាពសុខស្រួល សុវត្ថិភាព សន្តិសុខ សុខភាពល្អ ។ល ។ សុខុមាលភាពរបស់មនុស្សម្នាក់ៗ មិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុណ្ណោះទេ តែត្រូវគិតដល់ផ្នែកជំនឿសាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ ព្រមទាំងភាពគ្រប់គ្រាន់ក្នុងជីវភាពរស់នៅផងដែរ ។

ទី៦ ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ

ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជា ដំណើរការ និងរចនាសម្ព័ន្ធគ្រប់គ្រងក្នុង ការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើនអាច បម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតរបស់ សង្គម ។ គោលគំនិតនៃភាពស័ក្តិសិទ្ធិ នៅក្នុងបរិបទអភិបាលកិច្ចល្អក៏បាន

បញ្ហាលផងដែរចំពោះការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន។ ដើម្បីឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការអនុវត្ត ត្រូវពិចារណា លើចំណុចមួយចំនួន ដូចខាងក្រោម :

- ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ (ធនធានមនុស្ស ហិរញ្ញវត្ថុ សម្ភារ ពេលវេលា)
- ការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់
- ជៀសវាងអនុវត្តនូវការិយាធិបតេយ្យ
- ការគិតគូរយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ
- គ្មានអំពើពុករលួយ
- ការសម្រេចចិត្តតាមបែបចូលរួម ។ល។

ទី៧ គណនេយ្យភាព

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការអនុវត្តតួនាទី និងការកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះ ទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុ នូវអ្វីដែលខ្លួនបាន សម្រេច និងអនុវត្ត។ គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ ដែលបានស្នើសុំឱ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបាន អនុវត្តចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។ មិនមែនមានតែស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេដែលត្រូវមាន គណនេយ្យភាព អង្គការសង្គម ស៊ីវិល និងក្រុមហ៊ុនឯកជន ក៏ត្រូវមានគណនេយ្យភាព ជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែល ទទួលរងនូវផលប៉ះពាល់អំពីការសម្រេចចិត្ត។ គណនេយ្យភាព រួមមាន គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ និង គណនេយ្យភាពចំពោះមុខសាធារណជន ។

ទី៨ ការឆ្លើយតប

ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អមានន័យថា ជាការព្យាយាម ខិតខំ ប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបម្រើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្របខ័ណ្ឌពេលវេលាមួយ ដ៏សមហេតុផល ។ ការឆ្លើយតបអាចជា :

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុ ដែលមិនអាចឈានដល់ការធ្វើសកម្មភាព ដើម្បីដោះស្រាយបញ្ហា ឬការលំបាក ទាំងនោះបាន
- សំណើសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ច ដើម្បីជួយដោះស្រាយ បញ្ហា ឬការលំបាកទាំងនោះ ព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះ ដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធនឹងបញ្ហា ឬការលំបាកទាំងនោះ។

ទី៩ ចក្ខុវិស័យជាយុទ្ធសាស្ត្រ

អ្នកដឹកនាំទាំងអស់ និងស្ថាប័នសាធារណៈនានាត្រូវមានទស្សនៈទូលំទូលាយ និងសម្រាប់រយៈពេលវែងអំពីអភិបាលកិច្ចល្អ និងការអភិវឌ្ឍធនធានមនុស្ស ដោយយកចិត្តទុកដាក់អំពីតម្រូវ

ការចាំបាច់នានា ដែលត្រូវអភិវឌ្ឍន៍លើការងារនេះ ។ ជាងនេះទៀត អ្នកដឹកនាំទាំងអស់ត្រូវមានការយល់ដឹងឱ្យបានច្បាស់អំពីទិដ្ឋភាពនានា ផ្នែកប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ដែលពាក់ព័ន្ធនឹងអភិបាលកិច្ចល្អ ។

៤.១.៣. អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌគោលនយោបាយ និងច្បាប់

អភិបាលកិច្ចល្អក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រចតុកោណ

រាជរដ្ឋាភិបាលនីតិកាលទី ៤ នៃរដ្ឋសភា បន្តជំរុញអនុវត្តនូវយុទ្ធសាស្ត្រ ចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ២ សំដៅ លើកស្ទួយកិច្ចអភិវឌ្ឍលើគ្រប់វិស័យនៅក្នុងប្រទេសកម្ពុជា។ ស្នូលនៃយុទ្ធសាស្ត្រចតុកោណគឺ អភិបាលកិច្ចល្អ ដែលផ្តោតការយកចិត្តទុក ដាក់ទៅលើកំណែទម្រង់បួន យ៉ាងគឺ:

១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

២) កំណែទម្រង់ប្រព័ន្ធច្បាប់ និងប្រព័ន្ធយុត្តិធម៌

៣) កំណែទម្រង់រដ្ឋបាលសាធារណៈ

៤) កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

កំណែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតទៅលើការធានាផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋប្រកបដោយ គុណភាព តម្លាភាព និងប្រសិទ្ធភាព។ សេវាសាធារណៈ ដែលមានចែងនៅក្នុងគោលនយោបាយ ស្តីពីការផ្តល់សេវាសាធារណៈនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវបានចងក្រង និងប្រមូលផ្តុំជា ៧ប្រភេទធំៗទៅតាមវិស័យ និងទំនួលខុសត្រូវរបស់ក្រសួង ស្ថាប័ន រួមមាន :

១. ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ

២. ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខសណ្តាប់ធ្នាប់

៣. ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល

៤. ចង្កោមសេវាពាក់ព័ន្ធ នឹងការលើកកំពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យមបរិស្ថានវិនិយោគ និងការចូលរួមរបស់ ផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ

៥. ចង្កោមសេវាពាក់ព័ន្ធនឹងសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី

៦. ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង

៧. ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការធ្វើវិចារណកម្ម ចំណាយ និងការបើកផ្តល់ ។

ការពង្រឹងការផ្តល់សេវាសាធារណៈជាមូលដ្ឋាន សេវាអធិបតេយ្យរបស់រដ្ឋ សេវាពាក់ព័ន្ធទៅនឹងការវិនិយោគ និងពាណិជ្ជកម្មធុនតូច និងមធ្យមតាមរយៈយន្តការ "ច្រកចេញចូលតែមួយ" កាត់បន្ថយការិយាធិបតេយ្យ ព្រមទាំងបង្កើតឡើងនូវយន្តការមួយ ដើម្បីធានាដល់ការអនុវត្តប្រកបដោយតម្លាភាព និងគ្មានអំពើពុករលួយ គឺការបង្កើត ការិយាល័យប្រជាពលរដ្ឋ ។ រាជរដ្ឋាភិបាលបន្តជំរុញអនុវត្តគោល នយោបាយវិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការរៀបចំបទដ្ឋានគតិយុត្ត និងការ ដាក់ចេញនូវវិធានការថ្មីថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាពិសេសការរៀបចំ និងអនុវត្ត លិខិតបទដ្ឋានដែលពាក់ព័ន្ធនឹង ការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិមករដ្ឋបាល ថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យ

បានច្បាស់លាស់នូវតួនាទី សិទ្ធិ អំណាច និងការធានា គណនេយ្យភាពនៅក្នុងការបំពេញការងារ។ ទន្ទឹមនេះដែរ ការគ្រប់គ្រងហិរញ្ញវត្ថុ តាមបែបវិសហមជ្ឈការនឹងត្រូវអនុវត្តដោយភាពទន់ភ្លន់ និងតាមដំណាក់ៗក្នុងរយៈពេលមធ្យម ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការកសាង សមត្ថភាពថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៤.១.៣. អតិបាលកិច្ចល្អក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មានគោលដៅកំណត់ការគ្រប់គ្រង ឃុំ សង្កាត់ទាំងអស់ក្នុង ព្រះរាជាណាចក្រកម្ពុជាតាមនយោបាយវិមជ្ឈការ។

រដ្ឋបាលឃុំ សង្កាត់ មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែង ប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចេរភាពសម្រាប់បំពេញសេចក្តីត្រូវការ ជាមូលដ្ឋាននៅក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិ ស្របតាមនយោបាយទូទៅរបស់រដ្ឋ។

ប្រព័ន្ធនៃអភិបាលកិច្ចមូលដ្ឋានត្រូវអនុវត្តនៅថ្នាក់ឃុំ សង្កាត់ ។ អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់ បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌឃុំ សង្កាត់នីមួយៗ។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ តួនាទីបម្រើការងារមូលដ្ឋាន សម្រាប់ផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន និង តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

ឃុំ សង្កាត់ ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមាន បេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន អំពីជម្រើស ជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេចទាក់ទិននឹងសកម្មភាពបម្រើផលប្រយោជន៍ ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល អំពីការ ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានា ។ (អភិបាលកិច្ចល្អ, ក្រសួងមហាផ្ទៃ, ២០១០)

៤.២. ទស្សនៈទានកំណែទម្រង់វិមជ្ឈការ និងសហមជ្ឈការនៅកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាផ្នែកមួយនៃកំណែទម្រង់រដ្ឋបាល សាធារណៈក្នុងចំណោមកម្មវិធីកំណែទម្រង់ធំៗ ទាំងបួនក្នុងគោលដៅបង្កើតនូវប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិមួយ ដោយឈរលើមូលដ្ឋាននៃការពង្រឹងនិងពង្រីកលទ្ធិប្រជាធិបតេយ្យ ការលើកកម្ពស់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ។ ដើម្បីសម្រេចគោលដៅនេះ ការផ្ទេរសិទ្ធិអំណាចនិងគណនេយ្យភាពទៅក្រុមប្រឹក្សា និងរដ្ឋបាលនៅថ្នាក់ក្រោមជាតិត្រូវបានស្តែងចេញតាមរយៈការបង្កើតច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី

ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលជាយន្តការសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសំដៅលើកកម្ពស់ និងធ្វើឱ្យកាន់តែប្រសើរនៅការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

បន្ទាប់ពីប្រទេសជាតិទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដី ពេញលេញ តាមរយៈការអនុវត្ត "គោលនយោបាយឈ្នះ-ឈ្នះ" ដែលផ្តួចផ្តើមគំនិត និងដឹកនាំអនុវត្តដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានាចុងឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី២ នៃរដ្ឋសភាបានសម្រេចចិត្តអនុវត្តកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ឃុំសង្កាត់ តាមរយៈការដាក់ចេញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០១ និងរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី០១នៅឆ្នាំ២០០២។

ដោយមានបទពិសោធន៍ជោគជ័យនៃការអនុវត្តគោលនយោបាយរឹមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ នៅថ្នាក់ក្រោមជាតិទាំងមូល ដោយបានដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៨។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ បាកកំណត់គោលដៅយុទ្ធសាស្ត្រ នៃកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាដូចខាងក្រោម៖

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- ជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

អត្ថន័យ

សន្ធានុក្រមនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់និយមន័យនៃពាក្យ រឹមជ្ឈការ និងវិសហមជ្ឈការ ដូចខាងក្រោម៖

រឹមជ្ឈការ មានន័យថា រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិ អំណាច និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) ឲ្យទៅក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៅមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។

វិសហមជ្ឈការ មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) ទៅឲ្យអង្គភាពក្រោមបង្គាប់ ឬទៅឲ្យក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននោះ។ ក្នុងន័យនេះភាពជាម្ចាស់មិនបានផ្តល់ឲ្យអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។

៤.២.១. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់

គោលនយោបាយ និងច្បាប់សំខាន់ៗសម្រាប់គាំទ្រដល់ដំណើរការនៃការអនុវត្តកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា រួមមាន៖

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ ទី៤
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ទន្ទឹមនឹងការដាក់ចេញក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ ក្រោមជាតិ។ កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ ដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកចេញជាបីដំណាក់កាលតាមរយៈការរៀបចំឲ្យមានផែនការ អនុវត្តន៍តាមដំណាក់កាលនីមួយៗ។ ផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១(ផអ៣ទី១) ដែលមានរយៈពេល៣ឆ្នាំ+០១ឆ្នាំ(២០១១-២០១៤) និងផែនការអនុវត្តន៍រយៈពេល៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) (២០១៥-២០១៧) បានបញ្ចប់។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តផែនការអនុវត្ត រយៈពេល៣ឆ្នាំ (២០១៨-២០២០) ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាព និងលទ្ធភាព របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

៤.២.២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ ទី៥ និងទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ដោយផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់បួន រួមមាន៖

- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ
- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

កំណែទម្រង់ទាំងបួននេះ ត្រូវបានពង្រឹងពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ។ ជាពិសេស ពាក់ព័ន្ធកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកកំណែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការ ជាកំណែទម្រង់ដ៏មានសារៈសំខាន់បំផុត ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួម គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។

៤.២.៣. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

នៅក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឲ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលបំណងកំណត់អំពីៈ

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ និងច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ ផ្អែកតាមក្របខ័ណ្ឌ យុទ្ធសាស្ត្រនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងដាក់ឲ្យប្រើនៅក្នុងឆ្នាំ ២០០៨។

ក្នុងការដាក់ជើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកតាមស្មារតីនៃច្បាប់រៀបចំខាងលើ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធបានដាក់ចេញនូវ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើន ដើម្បីធានាឲ្យប្រព័ន្ធ អភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកបដោយភាពរលូន មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

៤.២.៤. ច្បាប់រៀបចំអង្គការ

ច្បាប់រៀបចំអង្គការសំដៅលើច្បាប់ស្តីពីការគ្របគ្រងឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។

៤.២.៥.ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

៤.២.៥.១. គោលការណ៍

យោងតាមមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើឲ្យមានចីរភាព ដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

រដ្ឋបាលឯកភាព គឺជាការរៀបចំឲ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការ ក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួល ប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រួមមានសមាសភាពដូចខាងក្រោម៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

គោលការទាំង៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ នីតិវិធី បំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការរៀបចំច្បាប់ និងលិខិតបទដ្ឋាននានា។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង៨ មានដូចខាងក្រោម៖

ទី១៖ ភាពជាតំណាងសាធារណៈ

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោត តាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស គឺជាការផ្តល់ភាពជាតំណាងសាធារណៈដល់ក្រុមប្រឹក្សាជាប់ឆ្នោត គ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានា ក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយមិនមានការរើសអើង ខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

ទី២៖ ស្វ័យភាពរបស់មូលដ្ឋាន

ស្វ័យភាពមូលដ្ឋាន មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋាន របស់ខ្លួនក្នុងដែនសមត្ថកិច្ចដែលច្បាប់បានកំណត់។

ទី៣៖ ការពិគ្រោះយោបល់ និងការចូលរួម

ការពិគ្រោះយល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់

ខ្លួន ដើម្បីរដ្ឋបាល ថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានខក្ខណៈផ្សេងៗគ្នាក្នុងមូលដ្ឋានខ្លួន (ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រជាដើម) សំដៅ ធ្វើសេចក្តីសម្រេចឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

ទី៤៖ ការឆ្លើយតប និងគណនេយ្យភាព

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើ គោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួន ប្រកបដោយការទទួល ខុសត្រូវនៅអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការ ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

ទី៥៖ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន

គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើត និងធ្វើឲ្យមាននិរន្តរភាពបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងលើកកម្ពស់ផាសុខភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច ក្រុមជនក្រីក្រជាដើម ហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយ ពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដែលមានកម្រិតរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

ទី៦៖ ការលើកស្ទួយសមធម៌

ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតប គណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។ ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែង ធានាឲ្យមានការពិគ្រោះយោលបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឲ្យបានសមស្របបំផុត ចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះ ការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនជាតិទាំងនោះ ទទួលបាននូវឱកាសកាន់តែច្រើនអត្ថប្រយោជន៍កាន់តែច្រើនពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានខ្លួន។

ទី៧៖ តម្លាភាព និងសុចរិតភាព

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ជាក្រឹត្យក្រម តម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឲ្យចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់

សម្រាប់ស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សា គណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឲ្យក្លាយជារដ្ឋបាល ដែលមានលក្ខណៈបើកចំហ មានតម្លាភាព ដោយត្រូវធានាឲ្យបានថា សមាជិកក្រុមប្រឹក្សាគ្រប់រូប អភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សាគណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួន ការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុងផ្ទៃក្រៅ និងប្រព័ន្ធនីតិវិធីនានាជាច្រើនដែលបានដាក់ឲ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការ លើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ទី៨៖ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយ ភាពស្អាតស្អំ និងយុត្តិធម៌ ដើម្បីធានាឲ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

៤.២.៥.២. ការរៀបចំប្រព័ន្ធអតិបាលកិច្ចនៅថ្នាក់ក្រោមជាតិ

ក. ឋានៈផ្លូវច្បាប់

មាត្រា៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋនៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាងដែលកើតឡើងពីការបោះឆ្នោតជ្រើសរើស ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺក្នុងគោលបំណងផ្តល់សិទ្ធិអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឲ្យដល់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សា អាចគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាប័ន្ន។

ខ.ក្រុមប្រឹក្សា

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិរួមមាន ក្រុបប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាសកល និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុុមប្រឹក្សាខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាអសកល។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានអាណត្តិ៥ឆ្នាំ និងត្រូវផុតកំណត់នៅពេលក្រុមក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាង

ប្រតិបត្តិ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និងសិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើ សេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។

គ. បុគ្គលិក

ក្រុមប្រឹក្សានីមួយៗមានបុគ្គលិករបស់ខ្លួន ដែលរួមមានបីប្រភេទដូចខាងក្រោម៖

- បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកដែលបានតែងតាំងឲ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា
- បុគ្គលិកដែលបានរៀបចំឡើងវិញឲ្យទៅបំពេញការងារជាមួយក្រុបប្រឹក្សា។

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រឹតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត សម្រាប់មុខតំណែងរបស់ខ្លួនស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/ ០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិក:ដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ឃ. មុខងារ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់មុខងាររបស់ក្រុមប្រឹក្សា នៃមុខងារពីរប្រភេទគឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

មុខងារជាកាតព្វកិច្ច គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬ អនុក្រឹត្យ ឬ ប្រកាស តាមសំណើររបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់កក្រោមជាតិ និងមុខងារជាជម្រើសដែលមានលក្ខណៈជាអាណត្តិទូទៅ។ មុខងារជាជម្រើសដែលមានលក្ខណៈជាអាណត្តិទូទៅត្រូវបាន ប្រគល់ទៅឱ្យក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់មុនការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារជាក់លាក់ណាមួយ ដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តមុខងារផ្សេងៗគ្នាជាច្រើន ដែលបានជ្រើសរើសយកជាអាទិភាពតាមមូលដ្ឋាននីមួយៗ។ បច្ចុប្បន្នរដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបំពេញការងារប្រចាំថ្ងៃដោយផ្អែកលើអាណត្តិទូទៅទាំងនេះ។ (ការគ្រប់គ្រងរដ្ឋបាលក្រុង, សាលាជាតិរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ, ខែកុម្ភៈ ឆ្នាំ២០២០)

គោលនយោបាយ និងសកម្មភាពអទិភាព ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល ក៏បានលើកឡើងពីការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ ស្នូលនៃយុទ្ធសាស្ត្រចតុកោណដែលផ្តោតលើការអនុវត្ត ១.ការកែទម្រង់ និង លើកកម្ពស់សមត្ថ ភាពស្ថាប័ន ២.ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ៣.ការពង្រឹងប្រសិទ្ធភាពនៃការ អនុវត្តការងារ និង ៤.ការពង្រឹងអភិបាលកិច្ចវិស័យឯកជន។ ទិសដៅសំខាន់បំផុតនៃការបង្កើន ល្បឿនកែទម្រង់អភិបាលកិច្ចនេះ ដើម្បីធានាធម្មានុរូបភាព និង ភាពជឿជាក់ពីសាធារណជន តាមរយៈការកសាងប្រព័ន្ធស្ថាប័នរដ្ឋឲ្យមានប្រសិទ្ធភាព ផលិតភាព ភាពឆ្លើយតប គណនេយ្យ ភាព និង តម្លាភាព។

- ❖ **ការបង្កើនល្បឿនកែទម្រង់អភិបាលកិច្ចល្អ៖ ស្នូលនៃយុទ្ធសាស្ត្រចតុកោណ**
- **ការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន**

គោលនយោបាយអាទិភាពសំខាន់ៗ សម្រាប់នីតិកាលទី៦

ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន ជារបៀបវារៈអាទិភាពខ្ពស់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីអនុវត្តការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័នប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពលើការងារស្នូលចំនួន៥ ដូចខាងក្រោម៖

- ការធ្វើវិចារណកម្មមុខងារ ការកិច្ចរចនាសម្ព័ន្ធស្ថាប័ន និងការសម្របសម្រួលអន្តរ ស្ថាប័នដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួង ស្ថាប័ននីមួយៗ ពិសេសតាមរយៈការអនុវត្តម៉ឺងម៉ាត់នូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី។
- ការពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីភាពម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសាមគ្គីភាពផ្ទៃក្នុងស្ថាបន ការរៀបចំ និងអនុវត្តហ្មត់ចត់នូវក្រមប្រតិបត្តិសម្រាប់បំពេញការងារ និងការសម្រិតសម្រាំងរកមន្ត្រីមានសមត្ថភាពខ្ពស់ និងគុណវុឌ្ឍល្អប្រសើរ សម្រាប់ការតែងតាំងមុខតំណែងដឹកនាំនៅក្នុងមុខងារសាធារណៈ។
- ការលើកកម្ពស់គុណាធិបតេយ្យ ក្នុងការជ្រើសរើស ការតែងតាំងមន្ត្រី ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការ ផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈនិងអង្គភាព សាធារណៈ ជាពិសេសការរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងវិស័យសាធារណៈ។
- ការពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធការងារ ក្របខណ្ឌអភិវឌ្ឍធនធានមនុស្សដែលទាក់ទាញសមត្ថភាពជំនាញ និងទេពកោសល្យ និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យមន្ត្រីសាធារណៈ។

- **ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ**

រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តោតលើការងារអាទិភាពចំនួន៦ គឺ៖ ទី១ ការសម្រួចយុទ្ធសាស្ត្រអប់រំ បង្ការ ទប់ស្កាត់ និង បង្ក្រាប ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅក្នុងក្របខណ្ឌ "មិនហ៊ាន មិនអាច និងមិនចង់ " ប្រព្រឹត្តអំពើពុករលួយ ទី២ ការពង្រឹង និងពង្រីកការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានបច្ចុប្បន្នភាពស្តីពី សេវាសាធារណៈ លិខិតបទដ្ឋានគតិយុត្ត និងឯកសារគោលនយោបាយជាតិ។ ទី៣ ការជំរុញឲ្យមានការចូលរួមពីសំណាក់ប្រជាជនក្នុងដំណើរការនៃការអភិវឌ្ឍ ការរៀបចំគោលនយោបាយ និងការអនុវត្ត។ ទី៤ ការជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹងតវ៉ា របស់អ្នកប្រើប្រាស់សេវារួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីគាំទ្រការ អនុវត្ត។ ទី៥ ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្ម ក្នុងវិស័យសាធារណៈ។ ទី៦ ការពង្រឹងប្រសិទ្ធភាពរៀបចំ និងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមិតភាពមុខងារ និងទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ។

- **ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ**

នៅក្នុងនីតិកាលទី៦នៃរដ្ឋសភា រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖ ១. ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំង បង្កើនប្រាក់សោធនជូននិវត្តជន និង អតីតយុទ្ធជន ដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារ ក្នុងរយៈពេល២សប្តាហ៍ម្តង ២. ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និង ការចែករំលែកបច្ចេកទេសតាមរយៈយន្តការវិមជ្ឈការនិងវិសហមជ្ឈការ ដល់អង្គភាពរដ្ឋបាល គ្រប់កម្រិតក្រោមឱវាទក្រសួងស្ថាប័ន គ្រឹះស្ថានសាធារណៈ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បី ទទួលបានស្វ័យភាពសមស្របទាំងការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្ស និង ហិរញ្ញវត្ថុ ទន្ទឹមនឹងការកំណត់ឲ្យបានច្បាស់លាស់នូវគណនេយ្យភាព និង ការទទួលខុសត្រូវរបស់អង្គភាពសាធារណៈ និងមន្ត្រីសាធារណៈ ៣. ការជំរុញនវានុវត្ត និងរដ្ឋបាល ឯកភាពនៅក្នុងកម្រិតក្រុង ស្រុក-ខណ្ឌ ខេត្ត-រាជធានី ដើម្បីធានាប្រសិទ្ធភាពទាំងក្នុងការបំពេញមុខងារ និងទាំងក្នុងការប្រើប្រាស់ធនធាន ៤. ការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធ កម្មដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ជាពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំ និងគ្រប់គ្រងស្ថាប័នសាធារណៈ ៥. ការដាក់ឲ្យអនុវត្តយន្តការតាមដាន និង វាយតម្លៃ ដើម្បីជំរុញការអនុវត្ត កែលម្អវិធានការតម្រង់ទិសយុទ្ធសាស្ត្រ និង ពង្រឹងកិច្ចសហប្រតិបត្តិការ អន្តរក្រសួង សម្រាប់ការកសាង រៀបចំ និង អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ៦. ការពង្រឹងយន្តការចែករំលែក និងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការគ្រប់គ្រង និង ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់ សេវាសាធារណៈនៅក្នុងការវិឆ្ឆដ៏ឆាប់រហ័សនៃបរិការណ៍ជាតិ និងអន្តរជាតិ និង ៧. ការលើកកម្ពស់សេវាយុត្តិធម៌ ដោយបង្កើនប្រសិទ្ធភាពការងាររបស់មន្ត្រី អនុវត្តច្បាប់ ពង្រឹងជំនឿទុកចិត្តពីសាធារណជនលើវិស័យយុត្តិធម៌ និងប្រយុទ្ធប្រឆាំងអំពើបំពានដោយអយុត្តិធម៌នៅក្នុងសង្គមតាមរយៈ (ក)ការពង្រឹងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ (ខ) ការពង្រឹងភាពស្អាតស្អំ និង ក្រមសីលធម៌ វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់ (គ) ការពង្រឹងយន្តការវិន័យការងារ និង ការធ្វើទំនើបកម្មរដ្ឋបាលយុត្តិធម៌ (ឃ) ការលើកកម្ពស់ការផ្តល់សេវាច្បាប់ និង (ង) ការពង្រឹង និង កែលម្អយន្តការដោះស្រាយវិវាទ ដែលអាចឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមប្រកបដោយប្រសិទ្ធភាព។

- **ការពង្រឹងអភិបាលកិច្ចវិស័យឯកជន**

រាជរដ្ឋាភិបាលកម្ពុជានឹងផ្តោតអាទិភាពលើ៖ ១. ការសិក្សា និងការរៀបចំក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យឯកជនដែល ជាគោលការណ៍រួមដើម្បីធានាការគ្រប់គ្រង និង ការអនុវត្តល្អក្នុងវិស័យឯកជន ២. ការសិក្សា និង រៀបចំក្របខ័ណ្ឌគោលនយោបាយលើកកម្ពស់ការទទួលខុសត្រូវផ្នែកសង្គម និងបរិស្ថាន ដើម្បីជំរុញការចូលរួមដោះស្រាយបញ្ហាសង្គម និង លើកកម្ពស់ការថែរក្សាបរិស្ថាន តម្លៃសីល ធម៌សង្គម និង វប្បធម៌ជាតិ ព្រមទាំងពង្រឹងការការពារសិទ្ធិ និង សុវត្ថិភាពអតិថិជន តាមរយៈការជំរុញរៀបចំ និង អនុម័តច្បាប់ស្តីពីការការពារអតិថិជន ៣. ការបន្តអនុវត្តយន្តការសន្ទនាក្នុង ភាពជាដៃគូរវាងរដ្ឋ និង វិស័យឯកជន ក្នុងកម្រិត

គោលនយោបាយ និង បច្ចេកទេសទាំងនៅ ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីជំរុញការពិភាក្សាផ្នែកគោលនយោបាយ និង ស្វែងរកដំណោះ ស្រាយបញ្ហាប្រឈមដោយលើកកម្ពស់ការប្រើប្រាស់តួនាទីនៃសភាពាណិជ្ជកម្ម និង ៤. ការជំរុញ និងការលើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគឡើងវិញលើការចូលរួមអភិវឌ្ឍមូលធនមនុស្ស និងនវានុវត្តន៍។ (រាជរដ្ឋាភិបាលកម្ពុជា, សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣)

កម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (២០១០-២០២០) ត្រូវបានអនុវត្តបញ្ចប់នៅក្នុងឆ្នាំ២០២០ ដោយសម្រេចបានសមិទ្ធផលធំៗជាច្រើន ក្នុងការពង្រឹង និងលើកកម្ពស់អភិបាលកិច្ច និងប្រជាធិបតេយ្យនៅមូលដ្ឋាន ប្រជាពលរដ្ឋមានសិទ្ធិអំណាច ចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តនានានៅមូលដ្ឋានក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ នៅមូលដ្ឋាន ប្រជាពលរដ្ឋទទួលបានសេវាកាន់តែល្អប្រសើរ និងរស់នៅប្រកបដោយសុខក្សេមក្សាន្តក្រោមម្លប់ សន្តិភាព និងការអភិវឌ្ឍ។ ដើម្បីបន្តកំណែទម្រង់ដ៏មានសារៈសំខាន់នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវ ឯកសារទស្សនទានស្តីពីការរៀបចំកម្មវិធីជាតិដំណាក់កាលទី២ ដែលជាគោលការណ៍ណែនាំតម្រង់ទិសដ៏ សំខាន់ សម្រាប់ការរៀបចំតាក់តែងកម្មវិធីជាតិស្តីពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ដល់ឆ្នាំ២០៣០។ ផ្អែកលើឯកសារទស្សនទាននេះ គ.ជ.អ.ប. បានដឹកនាំ និង សម្របសម្រួលការរៀបចំតាក់តែងកម្មវិធីជាតិ ដំណាក់កាលទី២ (ហៅថា កជទី២) ដោយមានការចូលរួមនិងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ជាលទ្ធផល ឯកសារកជទី២ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១។ ក្នុងការអនុវត្ត កជទី២នេះ តម្រូវឱ្យមានការរៀបចំផែនការអនុវត្តជាពីរ ដំណាក់កាលពេលគឺ ដំណាក់កាលទី១ ចាប់ពីឆ្នាំ២០២១ដល់ឆ្នាំ ២០២៥ (ផអ៥ទី១) និងដំណាក់កាលទី២ ចាប់ពីឆ្នាំ២០២៦ដល់ឆ្នាំ២០៣០ (ផអ៥ទី២)។

លេខាធិការដ្ឋាន គ.ជ.អ.ប. បានដឹកនាំ និងសម្របសម្រួលដំណើរការរៀបចំតាក់តែង ផអ ៥ទី១ ដោយមានការចូលរួម និងពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធនានា។ ឯកសារ ផអ៥ទី ១ ត្រូវបាន អនុម័តដោយ គ.ជ.អ.ប. នៅថ្ងៃអង្គារ ១២រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស .២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២។ ផអ៥ទី១ ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធ អភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន លក្ខណៈទំនើបស្វ័យភាព ប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន តាមរយៈ៖

- ការពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្រប តាមចរិតលក្ខណៈ និងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការធ្វើទំនើបកម្ម ប្រព័ន្ធគ្រប់គ្រងតាមបច្ចេកវិទ្យាឌីជីថល

- ការពង្រឹងការគ្រប់គ្រងធនធានមនុស្ស និងការលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កើនធនធានហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបែងចែកថវិកាប្រកប ដោយតម្លាភាព អាចព្យាករណ៍បាន និងធានាដល់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ព្រមទាំងការពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំ និងការអនុវត្តថវិការបស់ខ្លួន
- ការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋដើម្បីជំរុញ លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្តនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២៤ (ផ.ស.ថ.) គឺជាផែនការសកម្មភាពឆ្នាំទី៤ នៃការអនុវត្ត ផអ៥ទី១។ ផ.ស.ថ. ឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ផ្តោតលើការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងធ្វើទំនើបកម្មនូវយន្តការនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គមជូនប្រជាពលរដ្ឋ។*(គ.ជ.អ.ប. NCDD 2024)*

៤.៣. សន្និដ្ឋាន

តាមរយៈគោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល យើងអាចសន្និដ្ឋានថា ការបើប្រាស់គោលការណ៍អភិបាលកិច្ចល្អ និងកំណែទម្រង់របស់រាជរដ្ឋាភិបាលកន្លងមក គឺបានការឆ្លុះបញ្ចាំងអំពីសកម្មភាពដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញ ដើម្បីការអភិវឌ្ឍឲ្យកាន់តែប្រសើរឡើងបន្ថែមលើគ្រប់វិស័យ ដែលជាទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរនៃកសាងនូវសង្គមកម្ពុជាមួយដែលរឹងមាំ ស្ថិតស្ថេរ មានសន្តិភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងមុឹងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស។

ជំពូកទី៥
ការវិភាគភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង

សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ បង្ហាញពីការចូលរួមសហការរបស់ប្រជាពលរដ្ឋដើម្បីវាស់ស្ទង់ពីភាពពេញចិត្តពួកគាត់ រវាងការងារអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ផ្អែកលើទិន្នន័យដែលប្រមូលបានដូចជា៖ នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួមរបស់ប្រជាពលរដ្ឋ គឺត្រូវបានពិចារណាធ្វើជាទិន្នន័យអថេរឯករាជ្យ សម្រាប់វិភាគ។ បន្ថែមពីនេះទៀត ដើម្បីពិនិត្យមើលទៅលើតួនាទីនៃការចូលរួមរបស់ពលរដ្ឋក្នុងការអភិវឌ្ឍន៍គ្នា ជាមួយមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាជ្ញាធរមូលដ្ឋាន ចាត់ទុកជាទិន្នន័យអថេរពឹងផ្អែកសម្រាប់វិភាគ។ ផ្អែកទៅលើទម្រង់នៃការវិភាគខាងលើ ជំពូកនេះបានចែកចេញជា បីផ្នែក ដែលក្នុងនោះរួមមាន៖ ផ្នែកទី១ ការបកស្រាយ ពីភាពជឿជាក់នៃចំនួនសំណួរតាមក្រុមអថេរនីមួយៗ។ ផ្នែកទី ២ ការវិភាគទិន្នន័យ ដែលរួមមាន ការវិភាគព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកឆ្លើយតប និងផ្នែកទី ៣ ជាផ្នែកចុងក្រោយ ដែលបង្ហាញអំពីការវិភាគ ចំពោះភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលជាអាជ្ញាធរមូលដ្ឋាននៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

៥.១. ភាពជឿជាក់នៃឧបករណ៍វិភាគទិន្នន័យ

ដើម្បីបញ្ជាក់ឱ្យមានភាពសុក្រិត្យចំពោះការសិក្សាពីភាពពេញចិត្តរបស់ប្រជាពលរដ្ឋ នៅក្នុងមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ដែលមានឥទ្ធិពលទៅលើប្រសិទ្ធភាពអនុវត្តការងាររបស់អាជ្ញាធរមូលដ្ឋាន កិច្ចការសិក្សាស្រាវជ្រាវនេះបានសម្រេចប្រើប្រាស់ អាល់ហ្វា Cronbach's Alpha (α) ដើម្បីជាវង្វាស់នៃភាពស្ថិតស្ថេរផ្ទៃក្នុងដែលពេញនិយម ក្នុងវិស័យចិត្តសាស្ត្រ និងធ្វើតេស្តជាធាតុដែលអាចទុកចិត្តបាននៃកម្រងសំណួរ នៅក្នុងឧបករណ៍ស្រាវជ្រាវសម្រាប់ធ្វើការសិក្សាភាពស្ថិតស្ថេរ។ ចំពោះឧបករណ៍ស្រាវជ្រាវ ត្រូវគ្រោងឡើងយ៉ាងយកចិត្តទុកដាក់ ដូចជាផ្អែកលើបញ្ហាស្រាវជ្រាវឧបករណ៍ស្ថិតិរួមមាន៖ Nominal Scale និង Interval Scale សុទ្ធតែត្រូវបានកំណត់ជាទម្រង់ សំណួរសម្រាប់អ្នកឆ្លើយតបដោយប្រើប្រាស់៥ រង្វាស់សម្រាប់ឆ្លើយតបដូចជា មិនពេញចិត្តខ្លាំង មិនពេញចិត្ត ធម្មតា ពេញចិត្ត និងពេញចិត្តខ្លាំង។ បន្ទាប់មកក្រោយពីទទួលបានទិន្នន័យ ដែលយើងបានប្រមូលរួច ត្រូវបានវាស់វែងសម្រាប់រកភាពទុកចិត្ត internal Consistency តេស្តទៅលើកម្រងសំណួរ។ ដោយលទ្ធផលតេស្តនៃកម្រងសំណួរនីមួយៗ ត្រូវតែមានលទ្ធផលធំជាង ៧០%ទើបអាចយកទិន្នន័យទៅវិភាគបាន។ ដើម្បីទទួលបាននូវលទ្ធផលសមស្រប ទៅតាមគោលបំណងដែលការសិក្សាស្រាវជ្រាវបានគ្រោងទុក យើងគណនា Cronbach's Alpha តាមរយៈរូបមន្ត $\alpha = \frac{k}{k-1}[1 - \frac{\sum SD_i^2}{SD_t^2}]$។

តាមរយៈការគណនាយើងទទួលបាន ចំនួនប្រជាពលរដ្ឋត្រូវសម្ភាសន៍សរុប គឺមានចំនួន ៣៨៩នាក់។ ដោយក្នុងនោះ យោងតាមលទ្ធផល ពីការសម្ភាសន៍ទៅលើប្រជាពលរដ្ឋនៅក្នុងមូល

ដ្ឋានដែលទទួលបានសរុបចំនួន ៣៨៩នាក់ តាមការបង្ហាញឱ្យឃើញពីកម្រិតនៃភាពជឿជាក់ របស់កម្រងសំណួរតាមរយៈការវិភាគក្នុងឧបករណ៍វិភាគ SPSS26 បានបង្ហាញឱ្យឃើញថាលទ្ធផលនៃសម្មតិកម្មទាំង៤ គឺភាពជឿជាក់អាល់ហ្វា សម្រាប់សម្មតិកម្មនីមួយៗដែលមានដូចបានបង្ហាញក្នុងតារាងខាងក្រោម ៖

តារាងលទ្ធផលនៃការតេស្តភាពជឿជាក់នៃកម្រងសំណួរ **Cronbach's Alpha (α)**

ល.រ.	អថេរ (Variables)	Item	α	រង្វាយតម្លៃ
H1	នីតិរដ្ឋ និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	៤	០.៨២៧	ល្អប្រសើរ
H2	តម្លាភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	៤	០.៨០	ល្អប្រសើរ
H3	គណនេយ្យភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	៤	០.៧៩	ល្អ
H4	ការឆ្លើយតប និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	៤	០.៧៩	ល្អ
H5	ការចូលរួម និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋ	៤	០.៨០	ល្អប្រសើរ
DV	ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន	៥	០.៨៥	ល្អប្រសើរ

៥.២. ការវិភាគទិន្នន័យ

ក្នុងផ្នែកនេះ ទិន្នន័យត្រូវយកមកវិភាគដើម្បីទាញយកនូវលទ្ធផល សម្រាប់បកស្រាយ។ ក្នុងនោះការវិភាគទិន្នន័យរួមមានប្រភេទដូចជា៖ ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍ និងការវាស់ស្ទង់វិភាគទៅលើឥទ្ធិពលនៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើដំណើរការអភិបាលកិច្ចមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

៥.២.១. ព័ត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍

ក្រោយពីការធ្វើសម្រង់មតិយោបល់ តាមរយៈកម្រងសំណួរដែលទទួលបានពីកាសិស្សាស្រាវជ្រាវនេះ គឺយើងទទួលបានចម្លើយ ពីអ្នកចូលរួមសហការណ៍ផ្តល់សម្ភាសន៍ ស្ថិតនៅក្នុងឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង សរុបមានចំនួន ៣៨៩នាក់។ យោងតាមទិន្នន័យលទ្ធផល ដែលទទួលបានពីការសម្ភាសន៍លើប្រជាពលរដ្ឋ យើងទទួលបានការបង្ហាញក្នុងតារាងលទ្ធផល ខាងក្រោមនេះដូចតទៅ ៖

៥.២.១.១. តេទរបស់អ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញខាងក្រោមបានបង្ហាញថាក្នុងចំណោម ប្រជាពលរដ្ឋដែលបានឆ្លើយតបទាំង ៣៨៩នាក់ ក្នុងនោះមានប្រជាពលរដ្ឋដែលជាស្ត្រីចំនួន ៥១% និងប្រជាពលរដ្ឋដែលជាបុរសចំនួន៤៩% ដូចដែលបានបង្ហាញក្នុងតារាង ខាងក្រោម៖

តារាងទី ៥.២.១.១ ភេទរបស់អ្នកឆ្លើយតប



៥.២.១.២. អាយុរបស់អ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញក្នុងដ្យាក្រាមខាងក្រោមនេះ បានយឺងយើញថា ក្នុងចំណោមប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ចំនួន ៣៨៩នាក់ក្នុងនោះយើងយើញថាមានចំនួនដែលផ្តល់សម្ភាសន៍នៅអាយុចាប់ពី១៨-២៥ឆ្នាំ មានចំនួន៣០% ប្រជាពលរដ្ឋដែលមានអាយុចាប់ពី ២៦ឆ្នាំ-៣៥ឆ្នាំ មានចំនួន ១៨% ដោយឡែកប្រជាពលរដ្ឋដែលមានអាយុចាប់ពី ៣៦ ឆ្នាំ-៤៥ឆ្នាំ មានចំនួន ២០% ប្រជាពលរដ្ឋដែលមានអាយុចន្លោះពី ៤៦ឆ្នាំ-៥៥ឆ្នាំ មានចំនួន ១៩% និងប្រជាពលរដ្ឋមានអាយុពី៥៦ឆ្នាំឡើងទៅ មានត្រឹម១៣%តែប៉ុណ្ណោះ ដូចបង្ហាញក្នុងតារាង៖ តារាងទី ៥.២.១.២. អាយុអ្នកឆ្លើយតប



៥.២.១.៣. កម្រិតសិក្សារបស់អ្នកផ្តល់សម្ភាសន៍

តាមទិន្នន័យដែលទទួលបានពីការផ្តល់សម្ភាសន៍ទៅកាន់ប្រជាពលរដ្ឋទាំង ៣៨៩នាក់ យើងសង្កេតឃើញថាប្រជាពលរដ្ឋដែលបានបញ្ចប់ការសិក្សាត្រឹមថ្នាក់ ប្រជាពលរដ្ឋបានសិក្សាត្រឹមបឋមសិក្សាមានចំនួន ៨៩នាក់ ហើយប្រជាពលរដ្ឋដែលបានសិក្សាដល់ថ្នាក់អនុវិទ្យាល័យមាន

ចំនួន ១០១នាក់ជាទិន្នន័យខ្ពស់ជាងគេ រីឯប្រជាពលរដ្ឋបានសិក្សាថ្នាក់វិទ្យាល័យមានចំនួន ៩៨ នាក់ ដោយឡែកប្រជាពលរដ្ឋដែលបានសិក្សាថ្នាក់បរិញ្ញាបត្រមានចំនួន ៣៨នាក់ ចំណែកប្រជាពលរដ្ឋបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៩នាក់ ចំណែកឯប្រជាពលរដ្ឋបានសិក្សាដល់ថ្នាក់បណ្ឌិតគឺមានត្រឹមតែ ០៥នាក់ប៉ុណ្ណោះ ទន្ទឹមនឹងនេះប្រជាពលរដ្ឋដែលមិនបានសិក្សារៀនសូត្រមានរហូតដល់៣៩នាក់ ដូចដែលមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី ៥.២.១.៣ កម្រិតសិក្សារបស់អ្នកឆ្លើយតប



៥.២.១.៤. មុខរបររបស់អ្នកតបសម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញថាក្នុងចំណោមប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ទាំងអស់ចំនួន ៣៨៩នាក់ ក្នុងនោះយើងឃើញថាចំនួនប្រជាពលរដ្ឋដែលបានប្រកបរបរជាអាជីវករ មានមធ្យមភាគរហូតដល់ទៅចំនួន ២០% រីឯប្រជាពលរដ្ឋដែលប្រកបមុខរបរ ជាកសិករមានមធ្យមភាគចំនួនប្រមាណជា២០% ចំណែកប្រជាពលរដ្ឋដែលមន្ត្រីរាជការមានត្រឹមតែ ៤%ប៉ុណ្ណោះ ដោយឡែកប្រជាពលរដ្ឋជាបុគ្គលិកនៅតាមបណ្តាស្ថាប័នឯកជនផ្សេងៗមានអត្រាមធ្យមភាគចំនួន ១៦% ចំពោះប្រជាពលរដ្ឋដែលជាស្ត្រីមេផ្ទះនៅក្នុងភូមិ ឃុំដែលបានផ្តល់សម្ភាសន៍មានចំនួន ១១% និងសិស្សនិស្សិតដែលបានចូលរួមក្នុងការផ្តល់សម្ភាសន៍ចំនួន រហូត២៣% ឯណោះ និងម្យ៉ាងទៀតក៏មានការចូលរួមតបសម្ភាសន៍ពីសំណាក់ប្រជាពលរដ្ឋដែលមានរបរនានាក្រៅបានរៀបរាប់ខាងលើចំនួន ៦%ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី៥.២.១.៤.មុខរបរអ្នកឆ្លើយតប



៥.២.១.៥. អាស័យដ្ឋានរបស់អ្នកផ្តល់សម្ភាសន៍

យោងតាមទិន្នន័យដែលបានបង្ហាញក្នុងតារាងខាងក្រោមនេះបានបង្ហាញឱ្យ យើញថាក្នុងចំណោមប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍ទាំងអស់ចំនួន ៣៨៩នាក់ ដែលក្នុងនោះយើងឃើញចំនួនប្រជាពលរដ្ឋដែលបានរស់នៅក្នុងភូមិបវេលមានចំនួនរហូតដល់22% ប្រជាពលរដ្ឋរស់នៅក្នុងភូមិដាច់ព្រ័ត្រ មានចំនួន 10% ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិសង្កែវារ មានចំនួន 8% រីឯប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិពាមមានចំនួន 7% ប្រជាពលរដ្ឋរស់នៅក្នុងភូមិកំពង់ភ្នៅមានចំនួន9% ហើយប្រជាពលរដ្ឋរស់នៅក្នុងភូមិស្នឹងដាច់ មានចំនួន10% ចំណែកប្រជាពលរដ្ឋរស់នៅក្នុងភូមិស្ពានកណ្តោលមានចំនួន8% និងប្រជាពលរដ្ឋរស់នៅក្នុងភូមិសាំងរាំងមានចំនួន10% ប្រជាពលរដ្ឋនៅភូមិស្វាយជ្រុំ មានចំនួន6% ខណៈដែលប្រជាពលរដ្ឋភូមិដូនអាវមានចំនួន4% ឯប្រជាពលរដ្ឋភូមិសំរោងជ័យមានចំនួន3% និងប្រជាពលរដ្ឋមកពីភូមិព្រៃតាឡូញមានចំនួន3%តែប៉ុណ្ណោះ ដូចមានបង្ហាញក្នុងតារាងទី ៥.២.១.៥ ។

តារាង ៥.២.១.៥. អាសយដ្ឋានអ្នកឆ្លើយតប



៥.៣. លទ្ធផលនៃការវិភាគកត្តារុករក និងតេស្តរកភាពធុកចិត្ត

ការវិភាគកត្តារុករក និងលទ្ធផលតេស្តភាពជឿជាក់ត្រូវបានបង្ហាញក្នុង តារាង៥.៣.១.។ ការស៊ើបអង្កេតបានផ្តោតលើអថេរដែលបានដាក់ចេញចំនួនប្រាំមួយ៖ នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប ការចូលរួម និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ដែលមានតម្លៃកត្តាផ្ទុក (Factor Loading) លើសពី 0.70 និងតម្លៃ KMO សុទ្ធតែធំជាង 50% និងតម្លៃភាពប្រហាក់ប្រហែល (P-value) តូចជា5% ។ លើសពីនេះគ្រប់កត្តានៃអថេរទាំងអស់ តម្លៃ eigenvalue ធំជាង ១ និងតម្លៃភាគរយ cumulative ធំជាង 60% ។ ជាចុងក្រោយដែលជាតេស្តសំខាន់សម្រាប់ ភាពទុកចិត្តគឺ Cronbach Alpha ដែលតម្លៃរបស់វាធំជាង 0.60 ជាតម្លៃដែល តម្រូវនៅក្នុងការវិភាគកត្តារុករក។

យោងទៅលើលក្ខណៈវិនិច្ឆ័យទាំងអស់ នៃកត្តាកំណត់ជះឥទ្ធិពលទៅលើ ការអនុវត្តគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈនៃថ្នាក់ក្រោមជាតិ ដែល អនុវត្តតាមកម្រិតនៃការវិភាគកត្តា និងការធ្វើតេស្តភាពជឿជាក់ដោយមិនចាំបាច់ ដកចេញនូវកត្តា(អថេរ) ណាមួយឡើយ លើកលែងតែសំណួរ (Items) មួយចំនួន តាមអថេរ។ សរុបមករាល់កត្តា(អថេរ)ដែលបានអនុវត្តក្នុងការសិក្សានេះជាកម្រង សំណួរអាចទុកចិត្តបានក្នុងការសិក្សាពីអភិបាលកិច្ចល្អនៅថ្នាក់ក្រោមជាតិ ។

ទិសាគកត្តារុករកនិងតេស្តភាពជឿជាក់

(Exploratory Factor Analysis and Reliability Test)

Items of Questionnaire	**Factor Loading ≥ 60%**	**KMO ≥ 50%**	**Evalue ≥ 1**	**Cumulative > 60%**	***α*** **≥ 60%**
Rule of Law					
RLQ2	.819	0.827**	2.46	0.615	0.787
RLQ1	.791				
RLQ4	.779				
RLQ3	.747				
Tangibility					
TQ4	.822	0.80**	2.57	0.644	0.816
TQ3	.809				

TQ1	.800				
TQ5	.779				
Accountability					
AQ3	.824	0.79**	2.52	0.631	0.804
AQ1	.798				
AQ5	.791				
AQ2	.764				
Responsiveness					
RQ4	.802	0.79**	2.54	0.635	0.809
RQ2	.802				
RQ3	.799				
RQ1	.786				
Participation					
PQ4	.811	0.80	2.57	0.642	0.814
PQ1	.800				
PQ2	.800				
PQ3	.795				
Citizens Satisfaction					
CSQ3	.800	0.85**	3.11	0.622	0.847
CSQ8	.794				

CSQ6	.789				
CSQ7	.788				
CSQ2	.773				

" *Note: **Bartlett's Test of Sphericity Approx. Chi-Square, p-value* < 0.01 "

៥.៤. ទាយតម្លៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអតិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋានៅ ឃុំបខេស

Mean Range of 5-point Likert Scale interpretation 1. Strongly Disagree: 1.00-1.80 (Very unsatisfactory), 2. Disagree: 1.81-2.60 (Unsatisfactory), 3. Fairly Agree: 2.61-3.40 (Fairly satisfactory), 4. Agree: 3.41-4.20 (Satisfactory), 5. Strongly agree: 4.21-5.00 (Very satisfactory) (Dean & Illowsky, 2009)

Scale	ការឆ្លើយតប	ការបកស្រាយ
0.80-1.80	Strongly Disagree	Strongly Dissatisfied
1.81-2.60	Disagree	Dissatisfied
2.61-3.40	Neutral	Neutral
3.41-4.20	Agree	Satisfied
4.21 - 5.00	Strongly Agree	Strongly Satisfied

Result of Weight Arithunetic Mean and Correlation matrix

Variables	Mean	SD	Sat	ROL	Tra	Acc	Res	Par
Satisfaction (DV)	3.7191	.52510	1.000	.624	.634	.639	.653	.694
Rule of Law (IV)	3.6861	.55324		1.000	.755	.711	.679	.611
Transparency (IV)	3.6967	.53276			1.000	.757	.719	.640
Accountability (IV)	3.6532	.51253				1.000	.747	.664

Responsiveness (IV)	3.6998	.52112					1.000	.714
Participation (IV)	3.7010	.52124						1.000

នៅក្នុងការវាស់វែងនៃមធ្យម និងគម្លាងស្តង់ដារ ដោយផ្អែកទៅលើអ្នកឆ្លើយ សំណួរចំនួន ៣៨៩នាក់ លទ្ធផលបានបង្ហាញថាកត្តាកំណត់ជះឥទ្ធិពលទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋានដូចជា (DV) និង (IV) មានកម្រិត (X=3.6532 to X=3.7191) ហើយគម្លាតស្តង់ដា (SD) តូចជាង ១។ ឥរិយាបទរបស់អ្នកឆ្លើយទាំងអស់យល់ថា សំណួរស្ទើរតែ ដូចគ្នា លើសពីនេះលទ្ធផលនៃម៉ាទ្រីសជាប់ទាក់ទងគ្នាត្រូវបានអនុវត្តចំពោះអថេរ ទាំងអស់ដែលបានរកឃើញនៅទូទាំងការវិភាគកត្តាផ្លូវការ និងការធ្វើតេស្តភាពជាដំណាក់កាល ដូចនេះអថេរទាំងអស់មានទំនាក់ទំនងយ៉ាងសំខាន់បើយោងតាមលទ្ធផល។ ចំពោះម៉ាទ្រិសទំនាក់ទំនង មានលទ្ធផលខុសពីសូន្យ បញ្ជាក់ថា ដំណើរការរីហ្គ្រេសិនមិនបានរំលោភលើលីនែអ៊ែរទេ ។

៥.៥. ទិភាគទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចល្អ

គោលបំណងនៃការវិភាគទៅលើសមីការរីហ្គេសិន រួមមានដូចជា៖ ការវិភាគម៉ូដែល ការវិភាគ ANOVA និងការវិភាគ Regression Coefficients លើសពីនេះមានកស្តុតាងដែលបង្ហាញអំពីការតេស្ត Assumptions ដែលជាលក្ខខណ្ឌនាំទៅរកភាពល្អរវាងទិន្នន័យ និងសមីការម៉ូដែល ។

ក្នុងដំហានឈានដល់ការបកស្រាយចំពោះទិន្នន័យ ដែលទទួលបានតាមរយៈការវិភាគទិន្នន័យទី១ ការសិក្សានេះនឹងបង្ហាញពីចំណុចសំខាន់ៗ នៃការគណនា និងការបកស្រាយលើអថេរនីមួយៗដូចជាអថេរឯករាជ្យ (មានសកម្មភាពពីអាជ្ញាធរមូលដ្ឋានរវាងការចូលរួម និងភាពពេញពេញចិត្តរបស់ពលរដ្ឋ) ទាំង៥ ដែលរួមមាន៖ នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការចូលរួម និងការឆ្លើយតប ដោយសំដៅកំណត់ស្វែងរកឱ្យបាននូវភាពពេញចិត្ត និងសហការប្រតិបត្តិការចូលរួមពីប្រជាពលរដ្ឋជាមួយនឹងរដ្ឋាភិបាល ក្នុងដំណើរនៃការអភិវឌ្ឍន៍អភិបាលកិច្ចនៃមូលដ្ឋានផ្ទាល់។

តារាងបង្ហាញពីទំនាក់ទំនងរវាងអថេរឯករាជ្យ និងអថេរពឹងផ្អែក

អថេរពឹងផ្អែក	R = 0.757 R^2 = 0.572 R-Adjust = 0.567	F = 106.330 Sig = 0.000			
អថេរឯករាជ្យ	Regression Coefficient	t-value	Sig	Collinearity	
				Tolerance	VIF
នីតិរដ្ឋ	0.153	2.827	0.005	0.368	2.716
តម្លាភាព	0.109	1.851	0.065	0.309	3.235
គណនេយ្យភាព	0.108	1.856	0.064	0.317	3.159

ការឆ្លើយតប	0.127	2.200	0.028	0.325	3.075
ការចូលរួម	0.319	7.428	0.000	0.437	2.288

៥.៥.១. ការបកស្រាយសេចក្តីសន្និដ្ឋានម៉ូដែល (Summary of Model)

ដោយយោងទៅតាមទិន្នន័យ ដែលបានវិភាគទៅលើការស្រង់មតិរបស់ប្រជាពលរដ្ឋទាំង ៣៨៩នាក់ បានបង្ហាញអោយឃើញ៖ ចំនួន Multiple R=0.៧៥៧ មានន័យថាកម្លាំងទំនាក់ទំនងរវាងអថេរឯករាជ្យ (នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួមរបស់ប្រជាពលរដ្ឋ) និងអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន) មានចំនួន ៧៥.៧០%។

ចំណែកចំនួន R Square ស្មើនឹង ០.៥៧២ មានន័យថាអថេរពឹងផ្អែកត្រូវបាន ពន្យល់ដោយអថេរឯករាជ្យបានចំនួន ៥៧.២០% មានន័យថាមានអថេរឯករាជ្យនៅ សល់ ៤២.៨០% ទៀតដែលមិនបានលើកមកនិយាយនៅក្នុងសមីការម៉ូដែល ។ ដូច្នេះចំនួន៤២.៨០% ហៅថា Disturbance Terms ឬ Error Terms។

ចុងក្រោយតម្លៃ R-Adjust ស្មើ ០.៥៦៧ មានន័យថាអថេរឯករាជ្យនិងអថេរពឹង ផ្អែកបានរួមគ្នាបង្កើតបានម៉ូដែលមានចំនួន ៥៦.៧០% ។

៥..២.២. ការបកស្រាយ ANOVA

យោងតាមលទ្ធផលនៃការគណនាបានបង្ហាញឱ្យឃើញថាតម្លៃនៃ F ស្មើ ១០៦.៣៣០, p-value = 0.000 តូចជាង ១% មានន័យថាអថេរឯករាជ្យ (នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួមប្រជាពលរដ្ឋ) គឺមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ទៅលើអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង) ពិតប្រាកដមែន។

៥.៥.៣. លទ្ធផលនៃ Coefficient Regression

ដោយយោងទៅតាមលទ្ធផល នៃការគណនាសមីការរីហ្គេសិន តម្លៃរបស់ Regression Coefficients ទៅលើអថេរឯករាជ្យនីមួយៗ ដែលបានបង្ហាញអំពីទំនាក់ទំនងជាមួយ អថេរពឹងផ្អែកដូចខាងក្រោម៖

១. នីតិរដ្ឋ និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាន

លទ្ធផលនៃការវិភាគសមីការរីហ្គេសិន (Regression) បានបង្ហាញថា b=0.១៥៣, t = ២.៨២៧, p-value =0.00៥ ដោយចំនួនតូចជាង ១% មានន័យថាអថេរឯករាជ្យ (នីតិរដ្ឋ) គឺពិតជាមានទំនាក់ទំនងគ្នាខ្លាំងក្នុងសារៈសំខាន់តូចជាង<0.0១ ជាមួយនឹងអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន) នៅកម្រិត ១ភាគរយ ។ ដោយផ្អែកលើលទ្ធផលខាងលើនេះ សម្មតិកម្មទី១ (Ha1) ៖នីតិរដ្ឋ មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់

លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ត្រូវបានទទួលយក ។ ហេតុដូចនេះយើងអាចសន្និដ្ឋានថានីតិរដ្ឋ គឺពិតជាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ធ្វើឱ្យមានភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ពិតប្រាកដមែន។

២. តម្លាភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាន

ដោយយោងតាមលទ្ធផលនៃការវិភាគសមីការរីហ្គ្រេសិន (Regression) បាន

បង្ហាញថា b= 0.១០៩, t= ១.៨៥១, p-value= 0.0៦៥ ដែលចំនួនវាតូចជាង១0% មានន័យថាអថេរឯករាជ្យ (តម្លាភាព) ពិតជាមានទំនាក់ទំនងគ្នានៅក្នុងសារៈសំខាន់ ធំជាង>0.0៥ តែតូចជាង<0.១0 ជាមួយនឹងអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋាន) នៅកម្រិត ១0ភាគរយ។ ដោយផ្អែកលើលទ្ធផលខាងលើនេះ សម្មតិកម្មទី២ (Ha2)៖ "តម្លាភាព មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង'' ត្រូវបានទទួលយក ។ ហេតុដូចនេះយើងអាចសន្និដ្ឋានថាតម្លាភាព គឺពិតជាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ល្មមទាក់ទងលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ពិតប្រាកដមែន។

៣. គណនេយ្យភាព និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាន

តាមលទ្ធផលនៃការវិភាគសមីការរីហ្គ្រេសិន (Regression) យើងសង្កេតឃើញថា b = 0.១0៨ t= ១.៨៥៦, p-value=0.0៦៤ ដែលចំនួនតូចជាង ១0% មានន័យថាអថេរឯក រាជ្យ (គណនេយ្យភាព) ពិតជាទំនាក់ទំនងគ្នានៅក្នុងសារៈសំខាន់ ធំជាង>0.0៥ តែតូចជាង<0.១0 ជាមួយអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋាន) នៅកម្រិត ១0ភាគរយ។ ដោយផ្អែកលើលទ្ធផលខាងលើនេះ សម្មតិកម្មទី៣(Ha3)៖ "គណនេយ្យភាព មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ល្មមលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង" ត្រូវបានទទួលយក។ ហេតុដូចនេះយើងអាចសន្និដ្ឋានថាគណនេយ្យភាព គឺពិតជាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ល្មមលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបងពិតប្រាកដមែន។

៤. ការឆ្លើយតប និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាន

យោងទៅតាមរយៈលទ្ធផលដែលទទួលបាន ពីការវិភាគសមីការរីហ្គ្រេសិន(Regression) បានបង្ហាញឱ្យឃើញថា b= 0.១២៧, t=២.២00, p-value = 0.0២៨ ដែលចំនួន តូចជាង ៥% នោះមានន័យថាអថេរឯករាជ្យ (ការឆ្លើយតប)ពិតជាមានទំនាក់ទំនងនៅក្នុងសារៈសំខាន់ តូចជាង

<0.05 ជាមួយអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន) នៅកម្រិត ៥ភាគរយ។ ដោយផ្អែកលើលទ្ធផលខាងលើនេះ សម្មតិកម្មទី៤(Ha4)៖ "ការឆ្លើយតប មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ល្មមលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង" ត្រូវបានទទួលយក។ ហេតុដូចនេះយើងអាចសន្មតថាការឆ្លើយតប គឺពិតជាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ល្មមដែលធ្វើឱ្យមានភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបងពិតប្រាកដមែន ។

៥. ការចូលរួម និងភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច នៃអាជ្ញាធរមូលដ្ឋាន

ដោយយោងតាមរយៈលទ្ធផល ដែលយើងទទួលបានអំពីការវិភាគលើសមីការរីហ្គ្រេសិន (Regression) បានបង្ហាញឱ្យឃើញថា b= 0.369, t=7.428, p-value = 0.000 ដែលចំនួនតូចជាង ១% នោះមានន័យថាអថេរឯករាជ្យ (ការចូលរួម)ពិតជាមានទំនាក់ទំនងខ្លាំងជាមួយអថេរពឹងផ្អែក (ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន) នៅកម្រិត ១ភាគរយ។ ដោយផ្អែកលើលទ្ធផលខាងលើនេះ សម្មតិកម្មទី៤(Ha5)៖ "ការចូលរួមរបស់ប្រជាពលរដ្ឋ មានឥទ្ធិពល និងសារៈសំខាន់លើភាពពេញចិត្តនៃប្រជាពលរដ្ឋចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង" ត្រូវបានទទួលយក។ ហេតុដូចនេះយើងអាចធ្វើការសន្មត់ថាការចូលរួម គឺពិតជាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ដែលធ្វើឱ្យមានភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបងពិតប្រាកដមែន ។

តបទៅតាមការបកស្រាយខាងលើបានបង្ហាញថា សម្មតិកម្មទាំង៥ សុទ្ធសឹងតែជាកត្តាដែលជះឥទ្ធិពលវិជ្ជមានដល់ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ពោលគឺ យើងឃើញថានៅក្នុងមូលដ្ឋានសិក្សាផ្ទាល់ ភាគច្រើនប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន ពួកគាត់មានការឱ្យតម្លៃទៅលើការចូលរួម សហការគ្នាទៅវិញទៅមក ហើយមានចំណុចខ្វះតិចតួចប៉ុណ្ណោះ ដែលជាកត្តាមួយជម្រុញបង្កើនសក្តានុពលក្នុងការអភិវឌ្ឍ និងពង្រឹងភាពចម្រើននៅក្នុងមូលដ្ឋានភូមិ ឃុំបន្តទៅមុខបន្ថែមទៀត។

តាមរយៈការបកស្រាយខាងលើមកនេះ លទ្ធផលខាងលើបានបង្ហាញឱ្យឃើញថា នៅក្នុងចំណោមសសម្មតិកម្មទាំង៥ ដែលបានលើកឡើង គឺសុទ្ធសឹងជាកត្តាកំណត់ដែលជះឥទ្ធិពលដល់ភាពពេញលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាននៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ក្នុងករណីនេះផងដែរបានរកឃើញថាលើកលែង មានអថេរចំនួន២ រួមមាន៖ តម្លាភាព និងគណនេយ្យភាព ដែលជាកត្តាមានជះឥទ្ធិពល ទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋដូចគ្នា ប៉ុន្តែស្ថិតនៅក្នុងកម្រិតស្រាល (Partial Significance) ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុលបវេល ខេត្តបាត់ដំបង។

សម្មតិកម្ម		Significant	Interpretation
Ha1	នីតិរដ្ឋ មានឥទ្ធិពលវិជ្ជមាននិងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។	0.005***	ត្រូវទទួលយក
Ha2	តម្លាភាព មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។	0.065*	ត្រូវទទួលយក
Ha3	គណនេយ្យភាព មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។	0.064*	ត្រូវទទួលយក
Ha4	ការឆ្លើយតប មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។	0.028***	ត្រូវទទួលយក
Ha5	ការចូលរួម មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តនៃប្រជាពលរដ្ឋចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។	0.000***	ត្រូវទទួលយក

៥.៤.៤. **ការតេស្ត Assumptions**

ចំពោះក្នុងការសិក្សាប្រភេទបែបវិភាគទិន្នន័យ ដោយប្រើទំនាក់ទំនងសមីការរីហ្គេសិនលក្ខខណ្ឌសម្រាប់ប្រើប្រើសមីការបែបនេះ ទាមទារឱ្យមានការធ្វើតេស្តរកការសន្មត់សម្រាប់បំពេញលក្ខខណ្ឌ ភាពល្អសក្តិសមនៃវាងកម្រិតនៃការកំណត់ទំហំសំណាក និងម៉ូដែលសមីការ។ ហេតុដូច្នេះហើយនៅក្នុងផ្នែកនេះ ការសិក្សាត្រូវត្រួតពិនិត្យទៅលើទំនាក់ទំនងរវាង អថេរឯករាជ្យ (Multicollinearity), កម្រិតនៃការចែកចាយធម្មតា (Normal Distrivution), Homoscedasticity។

ក. Multicollinearity

ការធ្វើតេស្តនេះមានគោលបំណងស្វែងរកទំនាក់ទំនងរវាងអថេរឯករាជ្យនិងអថេរមិនឯករាជ្យ ជាមួយគ្នានេះការវិភាគនិងបកស្រាយ កំណត់យកតម្លៃ VIF តូចជាង ៥ (VIF<5) និង Tolerance ធំជាង ០.២០ (Tolerance>0.20) យោងតាមលោក O'Brien R.M, បោះពុម្ពនៅឆ្នាំ 2007 ។ ដូច្នេះតម្លៃ Variance Inflation Factors នៃអថេរឯករាជ្យនីមួយៗ នៅក្នុងតារាងខាងលើសុទ្ធតែតូចជាង ៥ និងតម្លៃ Tolerance អថេរនីមួយៗក៏សុទ្ធតែធំជាង ២០%ទាំងអស់ ។ វាត្រូវសន្និដ្ឋានបានថា អថេរឯករាជ្យទាំងប្រាំ (នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចលរួម) នីមួយៗគឺមានទំនាក់ទំនងនឹងគ្នាពិតមែន។

ខ. ការតេស្ត Normal Distribution

រូបគំនូរ៖ ការចែកចាយធម្មតា (Normal distribution)



នៅក្នុងក្រាហ្វ ការចែកចាយធម្មតា (Error! Reference source not found.) បង្ហាញថាទិន្នន័យគឺស្ថិតនៅក្នុងការចែកចាយធម្មតា ដោយសារសូន្យ គឺជាចំណុចកណ្តាលនៃ ក្រាហ្វ ហើយទិន្នន័យស្ថិតនៅចន្លោះពី 4 ដល់ +4 ។ ដោយក្រាហ្វ គឺមានទម្រង់ជាខ្សែកោងរាងកណ្តឹង (Bell-curve) ។ នេះគឺបានបង្ហាញពីលទ្ធផល នៃការចែកចាយទិន្នន័យសម្រាប់ម៉ូដែលសមីការរីហ្គេសិនបានយ៉ាងល្អ។ ដូច្នេះ យើងអាចសន្មត់ថា វិធីសាស្ត្រត្រូវបានចែកចាយជាធម្មតា។ លើសពីនេះ គំរូនៃអថេរមានភាពល្អគ្រប់គ្រាន់ដើម្បីដំណើរវិភាគតាមសមីការរីហ្គេសិន (Multiple Regression) ។

សម្រាប់ជាតឹកតាងបន្ថែមទៀតនៅក្នុងក្រាហ្វ P-P plot នៃZ-pred. និង Z-resid. គឺបានបង្ហាញថា វាមានលក្ខណៈធម្មតាល្អដូចបង្ហាញក្នុង Error! Reference source not found.ខាងលើ។ ចំណុចតូចៗ (Small plots) ដែលពង្រាយរាងតោងកៀកសន្ទុកតាមនឹងខ្សែបន្ទាត់ធម្មតា (Normal line) មានន័យថាវាបង្ហាញការតម្រឹមយ៉ាងល្អឥតខ្ចោះ នៃការស្មង់មតិសំណាកទិន្នន័យពីព្រោះគម្លាតទិន្នន័យពីមួយទៅមួយ គឺមានបង្គុំទំនាក់ទំនងប្រទាក់ក្រឡាគ្នាបានល្អ។ ដោយផ្អែកលើក្រាហ្វ យើងអាចសន្មត់ថាវិធីសាស្ត្របែបនេះត្រូវបានចែកចាយជាធម្មតា។ ហើយគួបផ្សំលើសពីនេះ ចំពោះគំរូនៃម៉ូដែលនៃអថេរ មានភាពល្អគ្រប់គ្រាន់ដើម្បីដំណើរការសមីការរីហ្គេសិនចុងក្រោយ (Multiple regression)។



គ. Homoscedasticity check

លទ្ធផលនៃទិន្នន័យ Homoscedastic ពី scatterplot ក្នុង (Error! Reference source not found.) ខាងក្រោមបង្ហាញថាគ្រោងគឺនៅជិតនឹងបន្ទាត់ត្រង់ដែលមក ពី Z RESID (អ័ក្ស Y ជាស្តង់ដារសំណល់ រីហ្គេសិន) ប្រឆាំងនឹង ZPRED (អ័ក្ស X ជាស្តង់ដារកំណត់តម្លៃព្យាករណ៍) ។ទិន្នន័យត្រូវបានចែកចាយយ៉ាងល្អ នៅព័ទ្ធជុំវិញអ័ក្សសូន្យគឺនៅចន្លោះរវាងអ័ក្ស X និងអ័ក្ស Y (ចន្លោះពី 2 ដល់ +2) ។ សរុបមក អថេរដែលបាព្យាករណ៍ (Independent Variables) ទាក់ទងទៅនឹង អថេរអាស្រ័យ (Dependent variable)។


Scatterplot
Dependent Variable: Satisfaction
Regression Standardized Residual
Regression Standardized Predicted Value
4
2
0
-2
-4
-2
-1
0
1
2
3
0.0

ជំពូកទី៦
សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ គឺបង្ហាញអំពីលទ្ធផលដែលបានរកឃើញជាចុងក្រោយនៃការសិក្សាស្រាវជ្រាវ។ ដោយហេតុដូច្នេះ នៅជំពូកនេះត្រូវបានបែងចែកជាបួនផ្នែក៖ ផ្នែកទី១ សេចក្តីសង្ខេបពីលទ្ធផលដែលបានវិភាគក្នុងជំពូកទី៥ខាងលើរួចមក, ផ្នែកទី២ ជាសេចក្តីសន្និដ្ឋាន, ផ្នែកទី៣ ផលប៉ះពាល់ដែលលបានមកពីការសិក្សា (Implication) និងផ្នែកទី៤ ដែលជាផ្នែកចុងក្រោយអំពីការសិក្សាស្រាវជ្រាវបន្តនាថ្ងៃអនាគតទៀត។

៦.១. សេចក្តីសង្ខេបលទ្ធផល

យោងតាមលទ្ធផលនៃការវិភាគទិន្នន័យ បានបង្ហាញថាលទ្ធផលមធ្យមមេគុណរបស់អថេរទាំងប្រាំរួមមាន នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម មានទំនោរខិតទៅរកកម្រិតភាពពេញចិត្តពីប្រជាពលរដ្ឋ។ ចំណែកឯលទ្ធផលនៃរីហ្គ្រេសិនបានរកឃើញថាអថេរឯករាជ្យទាំង៥ មានទំនាក់ទំនងជាមួយអថេរពឹងផ្អែកស្ថិតនៅកម្រិត ១%, ៥% និង១០%។ បន្ទាប់ពីការស្ទង់មតិពីប្រជាជនពលរដ្ឋ តាមរយៈកម្រងសំណួររួចមក យើងទទួលបាន៣៨៩នៃការឆ្លើយតបពីសំណាក់ប្រពលរដ្ឋរស់នៅក្នុងចំណោម១២ភូមិ នៅឃុំបវេល នៃស្រុកបវេល ខេត្តបាត់ដំបង។ ក្នុងនោះយើងសង្កេតឃើញមានអថេរចំនួន៣ មាន៖ នីតិរដ្ឋ ការឆ្លើយតប និងការចូលរួម ដែលមានមានសារៈសំខាន់ និងជាកត្តាជះឥទ្ធិពលវិជ្ជមានទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ចំណែកឯ អថេរ២ទៀតក្នុងនោះមានអថេរ តម្លាភាព និងគណនេយ្យភាព ដែលមានកម្រិតភាពវិជ្ជមាន និងមានសារៈសំខាន់ជាកត្តាជះឥទ្ធិពលនៅក្នុងកម្រិតស្រាល (Partial Significance) ទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។

សម្មតិកម្មទី១**(Ha1)**៖ នីតិរដ្ឋ មានឥទ្ធិពលវិជ្ជមាននិងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ច អាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង “ត្រូវបានទទួលយក”។ ដោយការរកឃើញនេះមានភាពស្របទៅនឹងការសិក្សារបស់ Daham Smko Hussein, Kittisak Jermsittiparsert និងPaiman Ahmad (2019) ដោយរបកគំហើញទាក់ទងនឹងឯកសារនេះ ថាប្រព័ន្ធអភិបាលកិច្ចក្នុងប្រទេសនីមួយៗត្រូវបានរៀបចំឡើងស្របតាមបរិបទនៃរដ្ឋ និងតំបន់។ ហើយអភិបាលកិច្ចត្រូវបានផ្សំជាមួយនឹងភាពរឹងមាំនៃនីតិរដ្ឋ ដូច្នេះកត្តាដែលជះឥទ្ធិពលដល់នីតិរដ្ឋមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការដឹកនាំអភិបាលកិច្ច។ ការសិក្សារបស់ Alice R. Thompson (2019) អំពី៖ "នីតិរដ្ឋ និងអភិបាលកិច្ចល្អ៖ របៀបដែលប្រព័ន្ធច្បាប់មានឥទ្ធិពលលើការពេញចិត្តរបស់ប្រជាពលរដ្ឋ" និក្ខេបបទនេះ សិក្សាពីទំនាក់ទំនងរវាងស្ថាប័នច្បាប់រឹងមាំ ការអនុវត្តនីតិរដ្ឋ និងទំនាក់ទំនងផ្ទាល់របស់វាជាមួយនឹងការពេញចិត្តរបស់សាធារណៈជនក្នុងអភិបាលកិច្ច។ ករណីសិក្សារួមមានឧទាហរណ៍ពីអាមេរិកឡាទីន និងអាស៊ីអាគ្នេយ៍។ ការសិក្សអំពី "នីតិរដ្ឋ និងការយល់ឃើញរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចល្អ៖ ការវិភាគជាក់ស្តែង" ដោយ David P.

Foster (2018) និក្ខេបបទនេះផ្តល់នូវការវិភាគជាក់ស្តែងអំពីរបៀបដែលនីតិរដ្ឋប៉ះពាល់ដល់ការយល់ឃើញរបស់ពលរដ្ឋ និងការពេញចិត្តចំពោះអភិបាលកិច្ច ដោយប្រើទិន្នន័យពីសន្ទស្សន៍អភិបាលកិច្ចសកល និងការស្ទង់មតិមតិសាធារណៈ។ និងការសិក្សាអំពី៖ "តួនាទីនៃនីតិរដ្ឋក្នុងការលើកកម្ពស់ការពេញចិត្តរបស់ប្រជាពលរដ្ឋ និងការជឿទុកចិត្តលើអភិបាលកិច្ច" ដោយ Grace O. Williams (2021) សង្ខេប៖ ការស្រាវជ្រាវនេះផ្តោតលើតួនាទីដែលនីតិរដ្ឋដើរតួក្នុងការជំរុញការជឿទុកចិត្ត និងការពេញចិត្តជាសាធារណៈនៅក្នុងស្ថាប័នរដ្ឋាភិបាល ដោយផ្តោតជាពិសេសទៅលើសង្គមក្រោយជម្លោះ។

សម្មតិកម្មទី២**(Ha2)**៖ តម្លាភាព មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង “ត្រូវបានទទួលយក”។ ដោយស្របតាមយៈការសិក្សារបស់ Ade Risna Sari (2023)ដែលបានសន្និដ្ឋានថាអភិបាលកិច្ចល្អមានផលប៉ះពាល់ជាវិជ្ជមានយ៉ាងសំខាន់ទៅលើគុណភាព នៃការសម្រេចចិត្តក្នុងការគ្រប់គ្រងសាធារណៈ។ ការអនុវត្តគោលការណ៍អភិបាលកិច្ចល្អនាំមកនូវអត្ថប្រយោជន៍ផ្សេងៗ រួមទាំងការបង្កើនតម្លាភាព។ ការសិក្សារបស់ Lars Tummers (2015) នៅក្នុងនិក្ខេបបទនេះ Tummers ស្វែងយល់ពីរបៀបដែលតម្លាភាពមានឥទ្ធិពលលើការអនុវត្តវិស័យសាធារណៈ និងផលប៉ះពាល់របស់វាទៅលើការពេញចិត្តរបស់ប្រជាពលរដ្ឋ។

សម្មតិកម្មទី៣**(Ha3)**៖ គណនេយ្យភាព មាននឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង “ត្រូវបានទទួលយក”។ ស្របតាមការសិក្សារបស់ Sonja R. Williams (2018) "ផលប៉ះពាល់នៃគណនេយ្យភាពលើការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ច៖ ការសិក្សាប្រៀបធៀប" ដែលនិក្ខេបបទនេះ សិក្សាអំពីរបៀបដែលទម្រង់នៃទំនួលខុសត្រូវផ្សេងៗគ្នាក្នុងក្របខ័ណ្ឌអភិបាលកិច្ចប៉ះពាល់ដល់ការពេញចិត្តរបស់ប្រជាពលរដ្ឋ។ ការសិក្សារបស់ Maria H. Rojas(2017) អំពី៖ "យន្តការគណនេយ្យភាព និងផលប៉ះពាល់របស់ពួកគេលើការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រងសាធារណៈ"។ ការសិក្សារបស់ Evelyn C. Lee (2020) អំពី៖ "គណនេយ្យភាព និងទំនុកចិត្តសាធារណៈ៖ ការស្វែងយល់ពីទំនាក់ទំនងរវាងគណនេយ្យភាពអភិបាលកិច្ច និងការពេញចិត្តរបស់ប្រជាពលរដ្ឋ"។ ការសិក្សារបស់ Maria J. Delgado (2021) អំពី៖ "ឥទ្ធិពលនៃយន្តការគណនេយ្យភាពលើការអនុវត្តវិស័យសាធារណៈ និងការពេញចិត្តរបស់ប្រជាពលរដ្ឋ"។ ការសិក្សារបស់ Daniel A. Green (2018) អំពី៖ "គណនេយ្យភាព និងការពេញចិត្តរបស់ប្រជាពលរដ្ឋ៖ ការសិក្សាអំពីការអនុវត្តអភិបាលកិច្ចក្នុងការគ្រប់គ្រងទីក្រុង"។ ការសិក្សារបស់ Clara M. Singh (2020) អំពី ៖ "ការពិនិត្យទំនាក់ទំនងរវាងគណនេយ្យភាព និងការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ"។ ការសិក្សារបស់ Robert K. Johnson (2019) អំពី ៖ "គណនេយ្យភាពសាធារណៈ និងឥទ្ធិពលរបស់វាទៅលើការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងសេវាកម្មរបស់រដ្ឋាភិបាល" និងការសិក្សារបស់ Elena V. Petrova (2022) អំពី ៖ "គណនេយ្យភាពក្នុងអភិបាលកិច្ច៖ ផលប៉ះពាល់សម្រាប់ការពេញចិត្ត និងទំនុកចិត្តរបស់ប្រជាពលរដ្ឋ"។

សម្មតិកម្មទី៤**(Ha4)**៖ ការឆ្លើយតប មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើពេញចិត្តរបស់ប្រជាពលរដ្ឋចំពោះអភិបាលកិច្ចអាជ្ញាធរមូលដ្ឋាន ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង “ត្រូវបានទទួលយក”។ យោងស្របតាមការសិក្សាអំពីៈ "ការឆ្លើយតបរបស់រដ្ឋាភិបាល និងការពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចបែបប្រជាធិបតេយ្យៈ ការសិក្សាប្រៀបធៀប" ដោយ Sarah L. Johnson (2021) ដោយនិក្ខេបបទនេះសិក្សាអំពីរបៀបដែលការឆ្លើយតបរបស់ស្ថាប័នរដ្ឋាភិបាលចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ និងការទាមទារមានឥទ្ធិពលលើការពេញចិត្តរបស់ប្រជាពលរដ្ឋទាំងមូល ដោយប្រើករណីសិក្សាពីប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ ការសិក្សាអំពីៈ "ការឆ្លើយតបសេវាកម្មសាធារណៈ និងការពេញចិត្តរបស់ប្រជាពលរដ្ឋៈ តួនាទីនៃអភិបាលកិច្ចល្អ" ដោយ Michael T. Carter (2020) ដោយសង្ខេបៈ ការស្រាវជ្រាវនេះផ្តោតលើរបៀបដែលការឆ្លើយតបក្នុងការផ្តល់សេវាសាធារណៈរួមចំណែកដល់ការពេញចិត្តរបស់ប្រជាពលរដ្ឋ ដោយផ្តោតលើរបៀបដែលគោលការណ៍នៃអភិបាលកិច្ចល្អ ដូចជាតម្លាភាព និងគណនេយ្យភាពត្រូវបានរក្សា។ ការសិក្សាអំពីៈ "ការឆ្លើយតប និងអភិបាលកិច្ចល្អៈ ការលើកកម្ពស់ការពេញចិត្តរបស់ប្រជាពលរដ្ឋតាមរយៈការចូលរួមរបស់រដ្ឋាភិបាលយ៉ាងសកម្ម" ដោយ Jessica A. Reed (2019) ដោយនៃសង្ខេបៈ និក្ខេបបទនេះសិក្សាពីរបៀបដែលការចូលរួមរបស់រដ្ឋាភិបាលយ៉ាងសកម្ម ដោយផ្តោតលើការឆ្លើយតបទៅនឹងការតវ៉ា និងតម្រូវការសាធារណៈ ជំរុញការពេញចិត្តរបស់ប្រជាពលរដ្ឋកាន់តែច្រើនចំពោះអភិបាលកិច្ច។ និងការសិក្សាអំពីៈ "តាមគោលការណ៍កំណត់របស់រដ្ឋាភិបាលពេញចិត្តរបស់ប្រជាពលរដ្ឋ សិក្សាអំពីការងារប្រចាំថ្ងៃសាធារណៈ" ដោយ David K. Williams (2018) ដោយសង្ខេបៈ ការសិក្សានេះពិនិត្យលើការយល់ឃើញ នៃកិច្ចពិភាក្សាជាសាធារណៈ ក៏ដូចជាវេទិការបស់រដ្ឋាភិបាល និងជាវេទិការនៃកិច្ចប្រជុំរបស់រដ្ឋាភិបាល និងបង្កើនការពេញចិត្តរបស់ប្រជាពលរដ្ឋ។

សម្មតិកម្មទី៥**(Ha5)**៖ ការចូលរួម មានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់លើភាពពេញចិត្តនៃប្រជាពលរដ្ឋចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង “ត្រូវបានទទួលយក”។ យោងតាមការសិក្សារបស់ Fernandez, M. E. (2021) អំពីៈ"ផលប៉ះពាល់នៃការចូលរួមរបស់ប្រជាពលរដ្ឋលើការទទួលខុសត្រូវ និងការពេញចិត្តរបស់រដ្ឋាភិបាល" ការសិក្សានេះស្វែងយល់ពីរបៀបដែលទម្រង់ផ្សេងគ្នានៃការចូលរួមរបស់ពលរដ្ឋប៉ះពាល់ដល់ការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងការពេញចិត្តរបស់ពលរដ្ឋដោយប្រើករណីសិក្សាពីប្រទេសមួយចំនួន។ ការសិក្សារបស់ Smith, J. W. (2020)អំពីៈ "ការចូលរួម និងអភិបាលកិច្ចល្អៈ ការវិភាគប្រៀបធៀបនៃការពេញចិត្តរបស់ប្រជាពលរដ្ឋនៅក្នុងទីក្រុង និងជនបទ"។ ការស្រាវជ្រាវនេះពិនិត្យលើភាពខុសគ្នានៃការពេញចិត្តរបស់ប្រជាពលរដ្ឋទាក់ទងនឹងការអនុវត្តអភិបាលកិច្ចនៅក្នុងទីក្រុងធៀបនឹងការរស់នៅជនបទ ដោយផ្តោតលើតួនាទីនៃការចូលរួម និងការសិក្សារបស់ Anna K.White (2019) អំពីៈ "តួនាទីនៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ និងទំនុកចិត្តសាធារណៈ" និក្ខេបបទនេះសិក្សាពីរបៀបដែលការចូលរួមរបស់ប្រជាពលរដ្ឋរួមចំណែកដល់អភិបាលកិច្ចល្អ និងបង្កើនការជឿទុកចិត្តរបស់សាធារណជន ដោយផ្តោតលើគំរូប្រជាធិបតេយ្យ និងការចូលរួមផ្សេងៗ។ ការសិក្សារបស់ Daniel T. Roberts (2020) អំពីៈ"ការចូលរួមរបស់ប្រជាពលរដ្ឋ និង

ការពេញចិត្តជាសាធារណៈក្នុងអភិបាលកិច្ចមូលដ្ឋាន៖ ការសិក្សារបស់ក្រុមប្រឹក្សាក្រុង" ដោយការសិក្សានេះពិនិត្យលើទំនាក់ទំនងរវាងការចូលរួមរបស់ប្រជាពលរដ្ឋ និងការពេញចិត្តរបស់សាធារណៈជនក្នុងអភិបាលកិច្ចមូលដ្ឋាន ដោយផ្តោតលើតួនាទីនៃតម្លាភាព និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ និងការសិក្សារបស់ Emily S. Harper (2018) អំពី៖ "អភិបាលកិច្ចល្អតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ៖ ការវាយតម្លៃប្រសិទ្ធភាពនៃយន្តការចូលរួម" ដោយ និក្ខេបបទនេះវាយតម្លៃយន្តការចូលរួមផ្សេងៗគ្នាដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីបង្កើនអភិបាលកិច្ចល្អ និងវាយតម្លៃប្រសិទ្ធភាពរបស់ពួកគេក្នុងការកែលម្អការពេញចិត្តរបស់ប្រជាពលរដ្ឋ។

៦.២. សេចក្តីសន្និដ្ឋាន

ផ្អែកតាមរយៈលទ្ធផលខាងលើ ឃើញថាអថេរសូចនាករនៃការអភិបាលកិច្ចល្អរួមមាន៖ នីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប ការចូលរួម សុទ្ធសឹងតែជាកត្តាដែលជៈឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ទាក់ទងទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅក្នុង ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ លើកលែងតែអថេរពីរ គឺតម្លាភាព និងគណនេយ្យភាពដែលជៈឥទ្ធិពលក្នុងកម្រិតស្រាលទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ចំពោះអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋានឃុំបវេល ស្រុកបេល ខេត្តបាត់ដំបង។

អាស្រ័យដូចបានរៀបរាប់ខាងលើ សម្រាប់ការសិក្សាមួយនេះអាចបង្ហាញឱ្យឃើញពីការវាយតម្លៃបានថា ប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុង ឃុំបវេល មានភាពពេញចិត្តចំពោះអភិបាលកិច្ចល្អ ដោយហេតុថា ព្រោះតែនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់ គឺតែងត្រូវការចំបាច់នូវការសម្របសម្រួលពីសំណាក់របស់មន្ត្រីដែលជាអាជ្ញាធរមូលដ្ឋាន ហើយមន្ត្រីរាជការដែលធ្វើការនៅក្នុងមូលដ្ឋាន គឺរមែងតែងតែបានផ្តល់ជូនឱ្យប្រជាពលរដ្ឋនូវភាពស្និទ្ធស្នាលកក់ក្តៅ ការយកចិត្តទុកដាក់ ផ្តល់ទំនុកចិត្ត មានការចូលរួម និងបំពេញការងារតាមភារកិច្ចប្រកបដោយសមត្ថភាពក្នុងការផ្តល់សេវាកម្មសាធារណៈប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងសមស្របទៅតាមស្តង់ដារ។ ហើយបន្ថែមពីលើនេះអភិបាលកិច្ចល្អរបស់អាជ្ញាធរមូលដ្ឋាន គឺបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់ភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋគ្រប់ៗរូប ដែលប្រើប្រាស់សេវាសាធារណៈ និងតែងមានការជម្រុញកៀងគរលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ឱ្យមានការចូលរួមបញ្ចេញមតិ អាចទទួលបានព័ត៌មាន ផ្តល់ចំណេះដឹង និងសហការចូលរួមរាល់គ្រប់សកម្មភាពទាក់ទងនឹងការអភិឱ្យមូលដ្ឋាន។ ម៉្យាងវិញទៀតអាជ្ញាធរមូលដ្ឋាន នៅកៀកជិតប្រជាពលរដ្ឋ ងាយក្នុងការជួយសម្រួលនិងស្វែងយល់ពីតម្រូវការ ដោះស្រាយបញ្ហាជូនប្រជាពលរដ្ឋជានិច្ចគ្រប់កាល:ទេស: ដែលជួយបង្កើនលើកកម្ពស់គុណភាពជីវិតធ្វើឱ្យ ភូមិ ឃុំមានសុខសន្តិភាព និងសុវត្ថិភាពយូរអង្វែង។

សរុបមក យោងតាមខ្លឹមសារលទ្ធផលដែលទទួលបានតាមរយៈការស្រាវជ្រាវ ទន្ទឹមនឹងតថភាពជាក់ស្តែង គឺមិនត្រឹមតែបានបង្ហាញពីកត្តាលីករសំខាន់ៗ ដែលមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ទាក់ទងទៅនឹងភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើអភិបាលកិច្ចល្អតែប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធផលនៃការអនុវត្តការងារអភិបាលកិច្ច ស្ថិតក្នុងស្ថានភាពពិតជៀបឆ្លើយតបទៅនឹងកំណែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងមហាផ្ទៃ ដែលបានដាក់

ចេញឱ្យអនុវត្តរួចមក និងដូចជាបានបង្ហាញឱ្យឃើញកាន់តែច្បាស់ពីភាពជោគជ័យនៃកំណែទម្រង់ដែលលេចចេញជាសមិទ្ធផលផ្លែផ្កាមានការរីកចម្រើនក្នុងមូលដ្ឋាន និងដូចជាចំណែកមួយនៃសង្គមជាតិជាក់ស្តែងផងដែរ។ ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ គឺជារង្វាស់ដ៏សំខាន់មួយសម្រាប់ធ្វើការវាយតម្លៃពីភាពជោគជ័យនៃអភិបាលកិច្ចល្អ។ គោលការណ៍នៃនីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម បូកបញ្ចូលគ្នាជារួមបានជាសមិទ្ធផលក្នុងការផ្តល់សេវាកម្មសាធារណៈនានា ពោលគឺការបំពេញមុខងារ អនុវត្តតួនាទីបំពេញនូវតម្រូវការរបស់ប្រជាពលរដ្ឋ គឺជាកត្តាសំខាន់ក្នុងការធានាថា ប្រព័ន្ធអភិបាលកិច្ចបំពេញតាមការរំពឹងទុក និងតម្រូវការ សេចក្តីទុកចិត្តរបស់ប្រជាពលរដ្ឋ។ ហេតុដូចនេះ ការស្រាវជ្រាវនាពេលអនាគត គួរតែបន្តស្វែងយល់ពីភាពខុសប្លែកកាន់តែប្រសើរ និងរីកចម្រើនទៅមុខនៃរបៀបដែលយន្តការអភិបាលកិច្ចផ្សេងៗមានឥទ្ធិពលអភិវឌ្ឍន៍ដល់កម្រិតណាមួយ ដែលធ្វើឱ្យមានការផ្លាស់ប្តូរនៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋ នៅពេលខាងមុខបន្តទៀត ដែលពោរពេញទៅដោយភាពរីកលូតលាស់នៃទំនើបកម្ម បរិបទ វប្បធម៌ នយោបាយ និងសេដ្ឋកិច្ចកាន់តែវិឌ្ឍន៍ឥតឈប់ឈរ។

៦.៣. លទ្ធផល និងអនុសាសន៍

ជាលទ្ធផលនៃការសិក្សានេះបង្ហាញថា អថេរទាំង៥នៃអភិបាលកិច្ចល្អដែលបានលើកឡើងពិតជាជះឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ទៅលើគុណភាពនៃការសម្រេចចិត្តរបស់ប្រជាពលរដ្ឋដោយពេញចិត្ត និងជឿជាក់លើការអនុវត្តការងារអភិបាលកិច្ចនៃអាជ្ញាធរមូលដ្ឋាន។ គោលការណ៍អភិបាលកិច្ចល្អ ដូចជានីតិរដ្ឋ តម្លាភាព គណនេយ្យភាព ការឆ្លើយតប និងការចូលរួម គឺដើរតួនាទីយ៉ាងសំខាន់ ក្នុងការលើកកម្ពស់គុណភាពនៃការសម្រេចចិត្តបន្តអភិវឌ្ឍន៍ ខិតខំប្រឹងប្រែងពី និងផ្តល់ជាលទ្ធផលដែលជាសេវាកម្មសាធារណៈ បំពេញជូនពីសំណាក់មន្ត្រីដែលបម្រើផល់ប្រយោជន៍ជារួមដល់ប្រជាពលរដ្ឋគ្រប់រូបក្នុងមូលដ្ឋាន។ នៅពេលដែលរដ្ឋាភិបាល ក៏ដូចជាស្ថាប័នពាក់ព័ន្ធបានអនុវត្តគោលការណ៍ទាំងនេះបានល្អ ការអនុវត្តការងារជាលទ្ធផលមានទំនោរទៅកាន់តែសមហេតុផល ប្រកបដោយប្រសិទ្ធភាព និងសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្ស។ ជាលទ្ធផលដោយសង្កេតឃើញថាការសិក្សាមួយនេះ បានបង្ហាញឲ្យឃើញអំពីកត្តាមួយចំនួនដែលបញ្ជាក់ច្បាស់ថាមានឥទ្ធិពលវិជ្ជមាន និងសារៈសំខាន់ទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ដូចបានបង្ហាញក្នុងតារាង និងការបកស្រាយខាងលើកន្លងមកនេះ ចាត់ទុកជាព័ត៌មានដល់អង្គភាពពាក់ព័ន្ធអាជ្ញាធរដែលជាអ្នកធ្វើការសម្រេចចិត្ត អ្នកធ្វើគោលនយោបាយ ឬអ្នកធ្វើផែនការ គួតែបន្តអភិវឌ្ឍន៍ឬត្រូវមានការពង្រឹងបន្ថែមទៅលើគុណភាពនៃអភិបាលកិច្ច ឱ្យកាន់តែមានភាពល្អប្រសើរឡើងជាងមុន ដែលជះឥទ្ធិពលទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តាមរយៈការបកស្រាយវិភាគពីខាងលើរួចមកយើងទាញបានចំណុចពិចារណាមួយចំនួនដូចខាងក្រោម៖

- **លទ្ធផល / ផលប៉ះពាល់៖**

១. នីតិរដ្ឋ៖ ដោយមើលឃើញពីផលប៉ះពាល់យ៉ាងសំខាន់ ការពង្រឹងនីតិរដ្ឋគួរតែជាអាទិភាពមួយសម្រាប់រដ្ឋាភិបាលមូលដ្ឋាន។ នេះបង្កប់នូវការអនុវត្តច្បាប់ប្រកបដោយភាពស៊ីសង្វាក់គ្នា ភាពយុត្តិធម៌ក្នុងដំណើរការតុលាការ និងការដោះស្រាយវិវាទផ្លូវច្បាប់ណាមួយ ជាពិសេសពាក់ព័ន្ធ

នឹងសិទ្ធិដីធ្លី និងទ្រព្យសម្បត្តិ ដែលជារឿងធម្មតានៅក្នុងតំបន់ជនបទ (Uslaner, 2013)។ នេះអាចនាំឱ្យប្រសើរឡើងនូវទំនុកចិត្ត និងការពេញចិត្តក្នុងចំណោមប្រជាពលរដ្ឋ ជំរុញឱ្យសង្គមកាន់តែមានភាពយុត្តិធម៌។

២. តម្លាភាព៖ ទោះបីជាមានសារៈសំខាន់មួយផ្នែកក៏ដោយ តម្លាភាពនៅតែមានសារៈសំខាន់ក្នុងការលើកកម្ពស់ទំនុកចិត្ត និងការពេញចិត្ត។ ភាពពាក់ព័ន្ធនៅទីនេះគឺថា រដ្ឋាភិបាលក្នុងតំបន់គួរតែផ្តោតលើការលើកកម្ពស់ការអនុវត្តការចែករំលែកព័ត៌មាន ជាពិសេសអំពីថវិកា ដំណើរការធ្វើការសម្រេចចិត្ត និងសេវាសាធារណៈ (Meijer, 2013)។ នេះមានន័យថាការបង្កើតវេទិកាដែលអាចចូលដំណើរការបានកាន់តែច្រើនសម្រាប់ប្រជាពលរដ្ឋដើម្បីទទួលបានព័ត៌មាន ដែលអាចកែលម្អការយល់ឃើញអំពីតម្លាភាពបន្តិចម្តងៗ។

៣. គណនេយ្យភាព៖ សារៈសំខាន់មួយផ្នែកនៃគណនេយ្យភាពបង្ហាញថា ទោះបីជាវាមានសារៈសំខាន់ក៏ដោយ យន្តការបច្ចុប្បន្នអាចមិនគ្រប់គ្រាន់។ ការពង្រឹងទំនួលខុសត្រូវតម្រូវឱ្យអនុវត្តបណ្តាញមតិកែលម្អកាន់តែច្បាស់សម្រាប់ប្រជាពលរដ្ឋក្នុងការរាយការណ៍អំពីទុក្ខព្រួយ និងតាមដានសកម្មភាពរបស់រដ្ឋាភិបាលក្នុងតំបន់ (Bovens, 2010)។ សវនកម្មទៀងទាត់ និងការបង្ហាញជាសាធារណៈអំពីការអនុវត្តរបស់រដ្ឋាភិបាលក៏អាចបង្កើនការយល់ឃើញអំពីការទទួលខុសត្រូវផងដែរ។

៤. ការឆ្លើយតប៖ ដោយសារការឆ្លើយតបមានឥទ្ធិពលយ៉ាងខ្លាំង ទៅលើការពេញចិត្តរបស់ប្រជាពលរដ្ឋ រដ្ឋាភិបាលមូលដ្ឋានគួរតែផ្តល់អាទិភាពក្នុងការដោះស្រាយតម្រូវការ និងកង្វល់ជាក់លាក់របស់ប្រជាពលរដ្ឋយ៉ាងឆាប់រហ័ស។ នេះអាចពាក់ព័ន្ធនឹងការបង្កើតប្រព័ន្ធផ្តល់សេវាដែលឆ្លើយតបកាន់តែច្រើន ដូចជាការិយាល័យរដ្ឋាភិបាលចល័តសម្រាប់តំបន់ដាច់ស្រយាល ឬការកែលម្អបណ្តាញទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងមន្ត្រី (Vigoda-Gadot, 2007)។

៥. ការចូលរួម៖ ឥទ្ធិពលសំខាន់នៃការចូលរួមបង្ហាញថា ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តមានសារៈសំខាន់ណាស់។ នេះបញ្ជាក់ថា អាជ្ញាធរមូលដ្ឋានគួរតែបង្កើតយន្តការដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងសកម្មរបស់ពលរដ្ឋក្នុងបញ្ហាអភិបាលកិច្ច ដូចជាកិច្ចប្រជុំសហគមន៍ ការចូលរួមថវិកា ឬការបង្កើតក្រុមប្រឹក្សាប្រឹក្សាប្រជាពលរដ្ឋ (Fung, 2015)។ នេះអាចនាំឱ្យមានអារម្មណ៍នៃភាពជាម្ចាស់ និងការពេញចិត្តក្នុងចំណោមអ្នករស់នៅ។

❖ សំណូមពរ / អនុសាសន៍

១. ពង្រឹងការយល់ដឹងផ្នែកច្បាប់៖ រដ្ឋាភិបាលក្នុងតំបន់គួរតែចាប់ផ្តើមយុទ្ធនាការយល់ដឹង ដើម្បីអប់រំប្រជាពលរដ្ឋអំពីសិទ្ធិ និងកាតព្វកិច្ចផ្លូវច្បាប់របស់ពួកគេ ដែលអាចពង្រឹងនីតិរដ្ឋ និងបង្កើនការពេញចិត្ត (Mungiu-Pippidi, 2015) ។ សិក្ខាសាលា ការប្រជុំសហគមន៍ និងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលអាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយព័ត៌មាននេះ។

២. កែលម្អយន្តការតម្លាភាព៖ អាជ្ញាធរមូលដ្ឋានគួរតែទទួលយកវេទិកាឌីជីថល ដើម្បីចែករំលែកការសម្រេចចិត្តរបស់រដ្ឋាភិបាល ថវិកា និងការធ្វើបច្ចុប្បន្នភាពគម្រោងដោយបើកចំហ។ ការអនុវត្តវិបផតថលអនឡាញ ដែលប្រជាពលរដ្ឋអាចចូលប្រើប្រាស់ព័ត៌មាននេះអាចជំរុញឱ្យមានវប្បធម៌នៃតម្លាភាព (Held, 2012)។

៣.ពង្រឹងក្របខណ្ឌគណនេយ្យភាព៖ ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យឯករាជ្យ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល និងការបង្កើតយន្តការបណ្តឹងផ្លូវការអាចធ្វើឲ្យប្រសើរឡើងនូវគណនេយ្យភាព។ ការបណ្តុះបណ្តាលមន្ត្រីរដ្ឋាភិបាលក្នុងតំបន់អំពីគោលការណ៍គណនេយ្យភាពក៏អាចបង្កើនការប្រកាន់ខ្ជាប់ផងដែរ (Dubnick, 2014) ។

៤. បង្កើនការឆ្លើយតបតាមរយៈយន្តការមតិកែលម្អ៖ ការបង្កើតប្រព័ន្ធឆ្លើយតបដែលប្រជាពលរដ្ឋអាចផ្តល់មតិកែលម្អតាមរយៈប្រអប់ផ្តល់យោបល់ ការស្ទង់មតិតាមអ៊ីនធឺណិត ឬការប្រជុំសហគមន៍អាចជួយដោះស្រាយបញ្ហាបានភ្លាមៗ។ វានឹងជួយរដ្ឋាភិបាលក្នុងតំបន់សម្របសេវាកម្មរបស់ពួកគេដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព (Walker, James, & Brewer, 2017)។

៥. សម្របសម្រួលការចូលរួមកាន់តែច្រើន៖ រដ្ឋាភិបាលគួរតែលើកទឹកចិត្តឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋដោយរៀបចំការប្រជុំសាលាក្រុងជាទៀងទាត់ និងការចូលរួមពីតំណាងសហគមន៍ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ការផ្តល់នូវការលើកទឹកចិត្ត ឬការទទួលស្គាល់សម្រាប់អ្នកចូលរួមសកម្មអាចជំរុញឱ្យមានការចូលរួមកាន់តែច្រើន (Aars & Fimreite, 2013)។

៦.៤. ដែនកំណត់និងការសិក្សាអនាគត

ដោយផ្អែកលើដែនកំណត់នៃការសិក្សាបច្ចុប្បន្នដូចបានរៀបរាប់ក្នុងជំពូកទី១ វិសាលភាពសម្រាប់ការសិក្សាស្រាវជ្រាវបន្ថែមត្រូវបានបង្ហាញដូចខាងក្រោម៖

១. ស្វែងយល់ពីឥរិយាបទរបស់ប្រជាពលរដ្ឋក្នុងការស្វែងរកការប្រើប្រាស់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ នៅឃុំបវេល ដោយធ្វើការសម្ភាសប្រជាពលរដ្ឋចំនួន ៣៨៩ នាក់ប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសជាទំហំសំណាក។ ការសិក្សានេះអាចផ្តល់លទ្ធផលកាន់តែប្រសើរជាងនេះទៅទៀត ប្រសិនសិនបើទំហំនៃការស្រាវជ្រាវអាចបង្កើនច្រើនជាងការសិក្សាបច្ចុប្បន្ននេះ។

២. ដើម្បីពិនិត្យស្វែងរកមើលកត្តាដែលជះឥទ្ធិពល លើការសហការចូលរួមរបស់មន្ត្រីជាមួយនឹងប្រជាពលរដ្ឋ អថេរឯករាជ្យមានដូចជា នីតិរដ្ឋ, តម្លាភាព, គណនេយ្យភាព, ការឆ្លើយតប និងការចូលរួម ដែលការសិក្សាបច្ចុប្បន្ននេះបានលើកយកមកពិចារណា។ ការសិក្សាអាចផ្តល់នូវលទ្ធផលល្អប្រសើរជាងនេះ បើសិនជាអថេរឯករាជ្យនឹងបង្កើនចំនួនច្រើនជាងការសិក្សាបច្ចុប្បន្ន។

៣. សម្រាប់និស្សិតឬ អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ នាពេលអនាគតអាចគិតគូ លើផ្នែកផ្សេងៗទៀត រួមទាំងទីតាំងនៃការសិក្សាជទៃទៀតនៅក្នុងឃុំ ស្រុក ឬខេត្តទាំងមូល ដើម្បីលើកយកធ្វើការវាយតម្លៃកំណត់បាននូវភាពវិជ្ជមាន និងសារៈសំខាន់ដែលជាកត្តានៃភាពពេញចិត្តរបស់ប្រជាពលរដ្ឋទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង ។ ដូច្នេះ ដែនកំណត់នៃការសិក្សាបច្ចុប្បន្នបានផ្តល់ការយល់ដឹងសម្រាប់ការស្រាវជ្រាវបន្ថែមក្នុងវិស័យរដ្ឋបាលថ្នាក់ក្រោមជាតិ ទៅលើប្រសិទ្ធភាពនៃអភិបាលកិច្ចល្អរបស់អាជ្ញាធរមូលដ្ឋាន។

សរុបមក តាមការសិក្សាបច្ចុប្បន្នបានព្យាយាមធ្វើការវិភាគលើទិន្នន័យ ដោយប្រើទំហំគំរូបន្ថែមទៀត វាយតម្លៃប្រសិទ្ធភាព និងឥទ្ធិពលរបស់វាទៅលើភាពពេញចិត្តរបស់ប្រជាពលរដ្ឋដោយប្រើអថេរឯករាជ្យបន្ថែមទៀត នៅក្នុងទីតាំងសិក្សាឃុំបវេល ស្រុកបវេល នៃខេត្តបាត់ដំបងនេះ។

ឯកសារយោង

Aars, J., & Fimreite, A. L. (2013). Local government and citizen participation in public administration review. International Review of Administrative Sciences, 79(2), 363-382.

Aars, J., & Fimreite, A. L. (2013). Local government and citizen participation in public administration review. International Review of Administrative Sciences, 79(2), 363-382.

Abers, Rebecca (2000), Inventing Local Democracy: Grassroots Politics in Brazil, Boulder, CO: Lynne Rienner.

Ahmad, P. (2019). The Importance of the Rule of Law in Governance. Journal of University of Raparin, 6(1), 73-90. https://doi.org/10.26750/vol(6).no(1).paper6

Alston, P., & Robinson, M. (Eds.). (2005). Human Rights and Development: Towards Mutual Reinforcement. Oxford University Press.

Anderson, P. (2024). Transparency and Accountability in Governance. Governance Quarterly.

Andersson N. Building the community voice into planning: 25 years of methods development in social audit. BMC Health Sery Res. 2011:11:S1. PubMed PMID: 22376121: PubMed Central PMCID: PMCPMC3397387. IPMC free articlel [PubMed] [Google Scholarl from https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/

Ansell, C., & Torfing, J. (2021). Public Governance as Co-Creation: A Strategy for Revitalizing the Public Sector and Rejuvenating Democracy. Cambridge University Press.

Ansell, Christopher K. (2011), Pragmatist Democracy: Evolutionary Learning as Public Philosophy, New York: Oxford University Press.

Anthony Valcke Senior Rule of Law Advisor, American Bar Association Rule of Law Initiative Solicitor (England & Wales) “The Rule of Law: Its Origins and Meanings (A Short Guide for Practitioners) (March, 1 2012)”, https://search.app/th4VyZrkTwcqSKjs5

Asian Development Bank (Governance: Sound Development Management, 1995)

Bevir, M. (2013). A Theory of Governance. University of California Press.

Bevir, Mark (2013), Governance: A Very Short Introduction, Oxford: Oxford University Press.

Bingham Centre for the Rule of Law, Mission Statement, available at: http://binghamcentre.biicl.org/mission-statement , accessed 24 August 2015

Bingham, Lisa B., Tina Nabatchi and Rosemary O'Leary (2005), 'The new governance: Practices and processes for stakeholder and citizen participation in the work of government', Public Administration Review, 65 (5), 547-558.

Bouckaert, G., & Van de Walle, S. (2003). Comparing Measures of Citizen Trust and User Satisfaction as Indicators of 'Good Governance': Difficulties in Linking Trust and Satisfaction Indicators. International Review of Administrative Sciences, 69(3), 329-343.

Bouckaert, G., & Van de Walle, S. (2003). Public sector performance and accountability. Public Administration Review, 63(3), 346-353.

Bovens, M. (2010). Two concepts of accountability: Accountability as a virtue and as a mechanism. West European Politics, 33(5), 946-967.

Bovens, M. (2021). The Politics of Information: Transparency and Accountability in Governance. Oxford University Press.

Boyte, Harry (2011), 'Constructive politics as public work: Organizing the literature', Political Theory, 39 (5), 630-660.
Brown, R., & Ahmed, T. (2024). Participatory Budgeting and Local Governance Responsiveness. Journal of Governance Studies.
Bryson, John M., Barbara C. Crosby and Melissa M. Stone (2006), 'The design and implementation of cross-sector collaborations: Propositions from the literature', Public
Bryson, John M., Kathryn S. Quick, Carissa Schively Slotterback and Barbara C. Crosby (2013), 'Designing public participation processes', Public Administration Review, 73 (1), 23-34.
Cane, P. (2016). Controlling administrative power, Cambridge, United Kingdom, Cambridge University Press. From Hussein, D., Jermsittiparsert, K.,
Chen, M., Zhang, L., & Hernandez, G. (2024). AI and Digital Governance: Enhancing Responsiveness. Digital Governance Review.
Chheang, V. (2017). Cambodia's decentralization: The path toward good governance? Asian Politics & Policy, 9(1), 4-22.
Chien, Nguyen Ba, and Nguyen Nghi Thanh. 2022. The Impact of Good Governance on the People's Satisfaction with Public Administrative Services in Vietnam. Administrative Sciences 12: 35.
Christensen, T., & Laegreid, P. (2005). Trust in Government: The Relative Importance of Service Satisfaction, Political Factors, and Demography. Public Performance & Management Review, 28(4), 487-511.
Christopher Boom 2015 The Importance of the Thin Conception of the Rule of Law for International Development: A Decision-Theoretic Account, Article in The Law and Development Review December 2015, https://search.app/7aQj3XEm9XoR9q2T7
CIDA (1996): Policy for CIDA on Human Rights, Democratization and Good Governance. ISBN 0-662-24393-5. URL:http://www.acdicida.gc.ca/CIDAWEB/acdicida.nsf/En/REN-218124821-P93#pdf , [cit.2007 09-28 from Governance: defining the concept Article October 2007 by Petr Vymětal Prague University of Economics and Business Source: OAI, https://search.app/AJoG9fDBpiVq2DjK8
Cooper, Terry L., Thomas A. Bryer and Jack W. Meek (2006), 'Citizen-centered collaborative public management', Public Administration Review, 66 (S1), 76-88.
Cornwall, A., & Coelho, V. S. (2023). Spaces for Change? The Politics of Citizen Participation. Zed Books.
Cornwall, A., & Gaventa, J. (2020). Power, Participation and Political Renewal: Theoretical Perspectives on Public Participation. In New Democratic Spaces? Routledge.
Dang, V. M., & Nguyen, T. T. H. (2018). Evaluating satisfaction of citizens on quality of public administration services in the Central Highlands of Vietnam. Advances in Economics and Business, 6(5), 308–314. https://doi.org/10.13189/aeb.2018.060504
Dubnick, M. J. (2014). Accountability and the promise of performance: In search of the mechanisms. Public Performance & Management Review, 27(3), 376-417.
Ejere, E.S.I., 2012. Promoting Accountability in Public Sector Management in Today's Democratic Nigeria. Book of Proceedings – Tourism and Management Studies

International Conference Algarve 2012 vol.3. University of the Algarve, Portugal https://search.app/EbFhJ6f1MAkTqNgN7

Ekpe, A. N. (2008). Effective management of socio-political conflicts in Akwa-Ibom state: Chief Godswill a pabio's effort. The Public Administration, 2(2), 63-70. from - Considering the Responsiveness, Accountability and Transparency Implications of Hybrid Organization in Local Governance: A Comparison of Public Service Provision Approaches in Myanmar and Thailand by Saw Khine Thet Tun, Grichawat Lowatcharin, Peerasit Kamnuansilpa, Charles David Crumpton June 2021, https://www.researchgate.net/publication/352373901_Considering_the_Responsiveness_Accountability_and_Transparency_Implications_of_Hybrid_Organization_in_Local_Governance_A_Comparison_of_Public_Service_Provision_Approaches_in_Myanmar_and_Thailand

Elwood, C. (1993). Legal and Honest Accountability in Public Institutions. Public Administration Review, 53(2), 156-170.

Eng, N. (2019). Local governance and service delivery in Cambodia. Journal of Southeast Asian Economies, 36(1), 42-63.

Eran Vigoda-Gadot. Responsiveness to Collaboration: Governance, Citizens, and the Next Generation of Public Administration January 2002 Public Administration Review 62(5):527 – 540, https://search.app/VJ27Fmxh7jFm77eH9

European Law Journal. 13(4):447-468 from https://search.app/EbFhJ6f1MAkTqNgN7

Feldman, Martha S. and Kathryn S. Quick (2009), 'Generating resources and energizing frameworks through inclusive public management', International Public Management Journal, 12 (2), 137-171.

Florini, A. (2007). The right to know: Transparency in the age of information. Columbia University Press.

Fox, J. (2007). The uncertain relationship between transparency and accountability. Development in Practice, 17(4-5), 663-671.

Freeman, R. Edward (2010), Strategic Management: A Stakeholder Approach, Cambridge: Cambridge University Press.

Fukuyama, F. (2013). What is governance? Governance, 26(3), 347-368.

Fung, A. (2015). Putting the public back into governance: The challenges of citizen participation and its future. Public Administration Review, 75(4), 513-522.

Fung, Archon (2006), 'Varieties of participation in complex governance', Public Administration Review, 66 (S1), 66-75.

Fung, Archon (2007), 'Democratic theory and political science: A pragmatic method of constructive engagement', American Political Science Review, 101 (3), 443-458.

Garcia, J., & Patel, K. (2024). Institutional Capacity and Governance Effectiveness in Fragile States. Governance and Development Review.

Glob Health Action. 2020: 13(Suppl 1): 1694744. Published online 2020 Mar 20. doi:10.1080/16549716.2019.1694744 https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/

Good Governance: Rule of Law, Transparency, and Accountability: by Michael Johnston Department of Political Science, Colgate University, https://etico.iiep.unesco.org/sites/default/files/2017-09/unpan010193.pdf

Graham, J., Amos, B., & Plumptre, T. (2003). Principles for Good Governance in the 21st Century. Institute on Governance.

Grindle, M. S. (2007). Good enough governance revisited. Development Policy Review, 25(5), 533-574.

Grindle, M. S. (2010). Good governance: Reforming the public sector in developing countries. Harvard University Press.

Heald, D. (2012). Why is transparency about public expenditure so elusive? International Review of Administrative Sciences, 78(1), 30-49.
Hood, C. (2006). Transparency in public management: A global survey. Governance, 19(4), 563-589.
Hood, C., & Heald, D. (2021). Transparency in Governance: The Role of Open Data and Public Disclosure. Routledge.
Hopwood, A. G., & Tomkins, C. (1984). The Role of Accounting in Public Sector Management: The Importance of Accountability. Journal of Public Administration, 22(4), 103-120.https://doi.org/10.3390/admsci12010035
Hughes, C., & Un, K. (2011). Cambodia's economic transformation. NIAS Press.
Hyden, G., Court, J., & Mease, K. (2004). Making Sense of Governance: Empirical Evidence from Sixteen Developing Countries. Boulder, CO: Lynne Rienner.
Innes, Judith E. and David E. Booher (2004), 'Reframing public participation: Strategies for the 21st century', Planning Theory and Practice, 5 (4), 419-436.
International IDEA. (2022). The Global State of Democracy 2022: Forging Social Contracts in a Time of Discontent. Stockholm: International IDEA.
International IDEA. (2023). The Global State of Democracy 2023: Democratic Accountability and Participation. Stockholm: International IDEA.
IoG Principles for Good Governance in the 21st Century, 2003 / OECD (2001): Governance in 21st century. Paris: OECD. ISBN 92-64-18541-0 - No. 51455 2001
Jacobs, Lawrence R., Fay Lomax Cook and Michael X. Delli Carpini (2009), Talking Together: Public Deliberation and Political Participation in America, Chicago, IL: University of Chicago Press.
Johnston, M. (2016, April 12). Good governance: Rule of law, transparency, and accountability. ResearchGate. Retrieved from
Journal of Management, 15 (S1), S9-S25. Young, Iris Marion (2000), Inclusion and Democracy, New York: Oxford University Press
Kaufmann, D., Kraay, A., & Mastruzzi, M. (2020). Worldwide governance indicators. World Bank.
Khatami, M. (2017). The Sovereignty of the People and Government Accountability. In Reflections on Governance and Democracy (pp. 145-160). Publisher.
Khotami, M. (2017). The concept of accountability in good governance. In Proceedings of the International Conference on Democracy, Accountability, and Governance (ICODAG 2017).
Khotami, M. (2017). The concept of accountability in good governance. In Proceedings of the International Conference on Democracy, Accountability, and Governance (ICODAG 2017). Retrieved from https://www.researchgate.net/publication/321349373_The_Concept_Of_Accountability_In_Good_GovernanceMansbridge, Jane (1999), 'On the idea that participation makes better citizens', in Stephen L.
Kim, S. (2016). Participation, performance, and attitudes toward governance in Cambodia. Asian Survey, 56(6), 1129-1151.
Kjaer, A. M. (2014). Governance. Polity Press.
Klitgaard R, MacLean-Abaroa R. Parris HL. Corrupt cities: a practical guide to cure and prevention. Washington (DC): World Bank Institute: 2000. [Google Scholarl from https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/
KOOIMAN, J. (2003): Governing as Governance. London: SAGE.
Kooiman, Jan (2003), Governing as Governance, Thousand Oaks, CA: Sage.

Kumar, S., & Waleed, A. (2024). Corruption and Political Instability: Barriers to Responsive Governance. Journal of Political Science.
Lægreid, P. (2014). Accountability and New Public Management. Financial Accountability & Management, 30(1), 1-19.
Lambert-Mogiliansky A. Social accountability to contain corruption. J Dev Econ. 2015:116:158-168 [Google Scholarl from https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/
Langer, R. (2005). Toward Participatory and Transparent Governance: Report on the Sixth Global Forum on Reinventing Government. ResearchGate. https://www.researchgate.net/publication/229549570_Toward_Participatory_and_Transparent_Governance_Report_on_the_Sixth_Global_Forum_on_Reinventing_Government
Lindstedt, C., & Naurin, D. (2010). Transparency is not enough: Making transparency effective in reducing corruption. International Political Science Review, 31(3), 301-322.
Mansuri, G., & Rao, V. (2013). Localizing development: Does participation work? World Bank.
Mark Bovens,2007 Public Accountability https://search.app/k4jZzdg9TGjFJMwG8
Marks and Cooper (1988), Ci by Hussein, D., Jermsittiparsert, K., & Ahmad, P. (2019). The Importance of the Rule of Law in Governance. Journal of University of Raparin, 6(1), 73-90. https://doi.org/10.26750/vol(6).no(1).paper6 , https://search.app/NfJgdRERVBoLwv8h8
Meijer, A. J. (2013). Understanding the complex dynamics of transparency. Public Administration Review, 73(3), 429-439.
Meijer, A. J. (2014). Transparency. Public Performance & Management Review, 37(3), 489-508.
Miguel Goede, Rostam J. Neuwirth 2014 Good governance and confidentiality: a matter of the preservation of the public sphere
Moore, M. H. (1995). Creating Public Value: Strategic Management in Government. Harvard University Press.
Moore, Mark H. (2014), 'Public value accounting: Establishing the philosophical basis',
Muhamad, R., Abdullah, Z., Abdul Latip, A. R., Saat, S. A., & Abu Bakar, N. (2023). Community satisfaction towards political representatives: Explaining the role of good governance practices. Planning Malaysia: Journal of the Malaysian Institute of Planners, 21(6), 440–455.
Mungiu-Pippidi, A. (2015). The quest for good governance: How societies develop control of corruption. Cambridge University Press.
Murshidi Baharon, B., Yap, C. S., Ashar, S. F. E., MohdHanafi, M. H., & Mohd Hazmi, M. S. R. (2017). Citizen satisfaction with e-government portals in Malaysia. *International Journal of Bio-Information*, *12*(3), 172-181. https://doi.org/10.6702/ijbi.2017.12.3.3
Nabatchi, Tina (2010), 'Addressing the citizenship and democratic deficits: The potential of deliberative democracy for public administration', American Review of Public Administration, 40 (4), 376-399.
Nguyen, T. T., Phan, D. M., Le, A. H., & Nguyen, L. T. N. (2020). The determinants of citizens' satisfaction of e-government: An empirical study in Vietnam. *Journal of Asian Finance, Economics and Business, 7*(8), 519–531. https://doi.org/10.13106/jafeb.2020.vol7.no8.519
Nik Ahmad Kamal Nik Mahmod, 2013, GOOD GOVERNANCE AND THE RULE OF LAW,

OECD. (2020). The Digitalisation of Government: How the Use of Technology is Enhancing Citizen Participation. OECD Publishing.
OHCHR. (2022). Human rights and good governance. United Nations Office of the High Commissioner for Human Rights.
O'Leary, Rosemary and Lisa B. Bingham (eds) (2009), The Collaborative Public Manager:
Oliver, R. (2004). What is tansparency? The McGraw-Hill Companies. Retrieved from http://net.educause.edu/ir/library/pdf/ERS1207/ers1207.pdf
Oliver, R. L. (1980). A Cognitive Model of the Antecedents and Consequences of Satisfaction Decisions. Journal of Marketing Research, 17(4), 460-469.
Organisation for Economic Co-operation and Development (OECD). (2015). OECD Principles of Public Governance. OECD Publishing.
Ovens, M., 2007. Analyzing and Assessing Accountability: A Conceptual Framework.
Ozawa, Connie P. (2012), 'Planning resilient communities: Insights from experiences with risky technologies', in Bruce Evan Goldstein (ed.), Collaborative Resilience: Moving through Crisis to Opportunity, Cambridge, MA: MIT Press, pp.<ts>19-38.
Paschke A. Dimancesco D. Vian T. et al. Increasing transparency and accountability in national pharmaceutical systems. Bull World Health Organ. 2018:96:782-791.IPMC free article] [PubMed) [Google Scholarl From https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/
Paschke A. Dimancesco D. Vian T. et al. Increasing transparency and accountability in national pharmaceutical systems. Bull World Health Organ. 2018:96:782-791. IPMC free article] [PubMed) [Google Scholarl from https://www.ncbi.nlm.nih.gov/pmc/articles/PMC7170369/
Pateman, C. (2012). Participatory democracy revisited. Perspectives on Politics, 10(1), 7-19.
Piotrowski, S. J., & Van Ryzin, G. G. (2007). Citizen Attitudes Toward Transparency in Local Government. The American Review of Public Administration, 37(3), 306-323.
Piron, L.-H. (2004). Rights-Based Approaches to Social Protection. Development Policy Review, 22(5), 637-652.
Regulation & Regulatory Governance by David Levi-Faur, Hebrew University of Jerusalem, Article December 2010, https://search.app/sbW4bABfRa9EQksB6 [07-sep-24]
Reich, Robert B. (ed.) (1990), The Power of Public Ideas, Boston, MA: Harvard University Press.
Renn, Ortwin, Thomas Webler, Horst Rakel, Peter Dienel and Branden Johnson (1993),'Public participation in decision making: A three-step procedure', Policy Sciences, 26 (3), 189-214.
Report of the Commission on Global Governance, Our Global Neighborhood, 1995
RHODES, R. (1996): The new governance: governing without government. Political Studies 44.
Roberts, Nancy (2004), 'Public deliberation in an age of direct citizen participation', American Review of Public Administration, 34 (4), 315-353.
Rotberg, R. I. (2014). Good Governance Means Performance and Results. Governance, 27(3), 511-518.
Rothstein, B., & Teorell, J. (2008). What is quality of government? A theory of impartial government institutions. Governance, 21(2), 165-190.
Rothstein, B., & Teorell, J. (2012). Defining and measuring quality of government. In Good Government: The Relevance of Political Science, Edward Elgar Publishing.

Rowley, J. (2012). Professional development needs of teachers to identify and cater for gifted students.... ResearchGate. https://www.researchgate.net/publication/258049515_Rowley_J_2012_Professional_development_needs_of_teachers_to_identify_and_cater_for_gifted_students_Australasian_Journal_of_Gifted_Education_212_75-80

SALAMON, L. M. (ED.) (2002): The Tool of Government. A Guide to the New

Saw Khine Thet Tun, Grichawat Lowatcharin, Peerasit Kamnuansilpa, Charles David Crumpton June 2021 Considering the Responsiveness, Accountability and Transparency Implications of Hybrid Organization in Local Governance: A Comparison of Public Service Provision Approaches in Myanmar and Thailand

See United Nations Development Programme, Issue Brief - Rule of Law and the Post-2015 Development Agenda, available at https://www.worldwewant2015.org/es/file/341332/down load/371036 , accessed 24 August 2015 , from Christopher Boom, The Importance of the Thin Conception of the Rule of Law for International Development: A Decision-Theoretic Account, Article in The Law and Development Review December 2015, https://search.app/7aQj3XEm9XoR9q2T7 Sida2845en-good-governance.pdf, A summary of the four methods reports, Digging Deeper, was published in 2003, p.2, https://cdn.sida.se/publications/files/sida2845en-good-governance.pdf

Simonsen, William and Mark D. Robbins (2000), Citizen Participation in Resource Allocation, Boulder, CO: Westview Press.

Sinha, M., Mehta, A. K., Langer, R., & Sudan, S. K. (2021). District Good Governance Index 2.0, J&K Report 2021-22(p. 1). Government of Jammu & Kashmir. Retrieved from https://ecostatjk.nic.in/pdf/dggi/annual/DGGI2.pdf

Smith, J., Johnson, M., & Lee, R. (2024). Digital Transformation and Responsiveness in Governance. Technology in Governance Journal.

Taryn Vian University of San Francisco. 2130 Fulton Street, San Francisco. CA 94117, USA

THE EUROPEAN COMMISSION (2007): Communication on Governance and Development, COM 03 615, 2003 URL: http://europa.eu.int/eurlex/en/com/cnc/2003/com2003_0615en01.pdf , [2007-07-03 by Petr Vymětal Governance: defining the concept Article October 2007]

Theory, Boston, MA: Harvard University Press. Pateman, Carole (1970), Participation and Democratic Theory, Cambridge: Cambridge

Toward Participatory and Transparent Governance: Report on the Sixth Global Forum on Reinventing Government: by Pan Suk Kim, John Halligan, Namshin Cho, Cheol H. Oh November 2005 Public Administration Review 65(6):646-654

TRAN THI ĐAM 2016. UNIVERSITY OF TAMPERE - The public administration's service quality, transparency and citizen satisfaction: A study in Ho Chi Minh City.

Transparency and Open Government, MEMORANDUM FOR THE HEADS OF EXECUTIVE DEPARTMENTS AND AGENCIES, the WHITE HOUSE, https://obamawhitehouse.archives.gov/realitycheck/the_press_office/Transparency_and_Open_Government

Transparency in Government: A Review on the Failures of Corruption Prevention in Indonesia by Siti Ngatikoh, Wahyudi Kumorotomo, Nunuk Dwi Retnandari , Jan 01 2020 https://www.researchgate.net/publication/339822339_Transparency_in_Government_A_Review_on_the_Failures_of_Corruption_Prevention_in_Indonesia

Un, K., & Hughes, C. (2015). The political economy of Cambodian development. Asian Affairs, 46(2), 220-240.
UNDP (1998): Governance: Experiences and Lessons Learned, Lessons Learned Series No.1, URL: http://magnet.undp.org/docs/gov/Lessons1.htm
UNDP. (1997). Governance for Sustainable Human Development. UNDP Policy Document.
UNDP. (2019). Good Governance Principles. United Nations Development Programme.
UNDP. (2020). The Next Frontier: Human Development and the Anthropocene. United Nations Development Programme.
UNESCAP 2009 (United Nations Economic and Social Commission for Asia and the Pacific), What is Good Governance? https://www.unescap.org/sites/default/files/good-governance.pdf
UN-Habitat. (2016). The Global Campaign on Urban Governance: Concept Paper. Nairobi: UN-Habitat.
United Nations Development Programme (UNDP). (1997). Governance for sustainable human development. UNDP Policy Paper.
United Nations Economic and Social Commission for Asia and the Pacific, ESCAP https://www.unescap.org/sites/default/files/good-governance.pdf
United Nations. (2021). Human rights and democracy. United Nations.
USCIB, Good Governance & the Rule of Law, January 2015, (SDGs=Sustainable Development Goals) https://www.uscib.org/docs/Governance%20and%20the%20Rule%20of%20Law.pdf
Uslaner, E. M. (2013). Corruption, inequality, and the rule of law: The bulging pocket makes the easy life. Cambridge University Press.
Van de Walle, S., & Bouckaert, G. (2007). Perceptions of Governance and Public Services in Africa: Linking Governance and Citizen Satisfaction. Routledge.
Van Ryzin, G. G. (2004). The Measurement of Overall Citizen Satisfaction. Public Performance & Management Review, 27(3), 9-28.
Vian T. Exploring the construction of transparency: an analysis of health managers' narratives. Global Health Governance. 2012:V:1-24. [Google Scholarl,
Vigoda-Gadot, E. (2007). Citizens' perceptions of politics and ethics in public administration: A five-year national study of their relationship to satisfaction with services, trust in governance, and voice orientations. Journal of Public Administration Research and Theory, 17(2), 285-305.
Vymětal, P. (2007). Governance: Defining the concept. OAI. Retrieved from https://search.app/AJoG9fDBpiVq2DjK8
Walker, R. M., James, O., & Brewer, G. A. (2017). Replication, experiments and knowledge in public management research. Public Management Review, 19(9), 1181-1193.
Warren, M. E. (2010). Accountability and democracy: The pitfalls of accountability. Oxford University Press.
What is Good Governance about?: The roots and the key elements of the concept, January 2008 by Petr Vymětal, Prague University of Economics and Business, https://www.researchgate.net/publication/283044746_What_is_Good_Governance_about_The_roots_and_the_key_elements_of_the_concept
Williams, H. (2024). Bureaucratic Efficiency and Governance Responsiveness. Administrative Science Quarterly.

World Bank, Governance Matters 2007:The Worldwide Governance Indicators) / WORLD BANK (1997): World Development Report 1997: The Stat in Changing World. Washington D.C.: World Bank.
World Bank. (1992). Governance and Development. Washington, DC: World Bank.
World Bank. (2017). World Development Report: Governance and the Law. World Bank.
World Bank. (2020). World Development Report: Governance and the Law. World Bank.
ការគ្រប់គ្រងរដ្ឋបាលក្រុង, ខែកុម្ភៈ ឆ្នាំ២០២០, សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ, https://search.app/4vUuspJyNMNozcJ49
ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥, https://search.app/4qpWydHYt11NRtbY9
ក្រសួងផែនការ, សេចក្តីណែនាំសម្រាប់ការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ (ផ.យ.អ.ជ. ២០១៩-២០២៣), ឧសភា ឆ្នាំ២០១៨, https://search.app/TJtaLdkZtwHHcRxH6
ក្រសួងមហាផ្ទៃ, អភិបាលកិច្ចល្អ បោះពុម្ពលើកទី២ ខែតុលា ឆ្នាំ២០១០, http://ticambodia.org/library/wpcontent/files_mf/1448899431GoodGovernance.pdf
គ.ជ.អ.ប គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NCDD(គ.ជ.អ.ប.), ផែនការសកម្មភាព និងថវិកាឆ្នាំ២០២៤ របស់ គ.ជ.អ.ប. ខែមករា ឆ្នាំ២០២៤, https://search.app/a6A6H21pvAwdfT667
រាជរដ្ឋាភិបាលកម្ពុជា, គោលនយោបាយ រដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ "កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់ គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ" រៀបចំដោយ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ខែមករា ឆ្នាំ ២០២២, https://search.app/y3dRSC6CLtLF3tWW9
រាជរដ្ឋាភិបាលកម្ពុជា, សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣, ដើម្បីកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០, (ខែកក្កដា ឆ្នាំ២០១៩) https://search.app/hcJA9K6tnAPrVbPe6
លោករដ្ឋលេខាធិការ ងី ចន្ទ្រថុល, មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ៖ កំណែទម្រង់អភិបាលកិច្ចល្អ ជាកិច្ចការចម្បង ដែលរាជរដ្ឋាភិបាលកំពុងផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង, 24-02-2020 03:04pm, https://search.app/XcniHuT1hvDuy4bj9
សម្តេចធិបតី ហ៊ុន ម៉ាណែត៖ ស្នូលនៃ គោលនយោបាយនៃយុទ្ធសាស្ត្របញ្ចកោណ គឺការ ពង្រឹងអភិបាលកិច្ច ទី 10 ខែមិថុនា ឆ្នាំ 2024, https://search.app/LE7ApiCruu3SZCsY7
ស្ថិតិប្រជាពលរដ្ឋ(ឃុំបវេល 2023) ពីលោក ផល ជួន (អនុភូមិបវេល១)
អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយ បែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងបរិបទប្រទេសកម្ពុជា, ហេង សីហា គឹម សេតារា និង សូ សុខប៊ុនធឿន ឆ្នាំ ២០១១ លេខ ១៤, https://cdri.org.kh/storage/pdf/PB2011-14K_1617207188.pdf
អភិបាលកិច្ចប្រព័ន្ធគាំពារសង្គម, https://search.app/ixsxQSAvFV5izBpk9

ឧបសម្ព័ន្ធ

កម្រងសំណួរស្រាវជ្រាវស្តីអំពីៈ
ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាន
នៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង

សូមគោរពជម្រាបសួរដល់ លោក/លោកស្រី អ្នកនាង កញ្ញាទាំងអស់គ្នាជាទីគោរពរាប់ អានទាំងអស់។ នាងខ្ញុំជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ ក្នុងឱកាសនេះខ្ញុំសូមអនុញ្ញាតពី លោក/លោកស្រី អ្នកនាង កញ្ញា ក្នុងការផ្តល់វត្តមានចំណាយពេលវេលាដ៏មានតម្លៃ សម្រាប់ការផ្តល់បទសម្ភាសន៍លើកម្រងសំណួររបស់ខ្ញុំដើម្បីជាទិន្នន័យវាស់ស្ទង់មតិពីសំណាក់ប្រជាពលរដ្ឋនៅមូលដ្ឋានផ្ទាល់ យកមកដាក់បញ្ចូលនៅក្នុងអត្ថបទស្រាវជ្រាវសម្រាប់បញ្ចប់ការសិក្សានេះ។ សូមថ្លែងអំណរគុណសម្រាប់រាល់ការចូលរួមសហការ និងយល់ព្រមឆ្លើយតបទៅនឹងសំណួរស្តីពី ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ ទៅលើអភិបាលកិច្ចរបស់អាជ្ញាធរមូលដ្ឋាននៅ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ សូមលោកអ្នកឆ្លើយតបតាមភាពពិតជាក់ស្តែង ដោយស្មោះត្រង់ និងយកចិត្តទុកដាក់ ពីព្រោះថាទិន្នន័យដែលទទួលបានពីអស់លោកអ្នក នៅក្នុងកម្រងសំណួរនេះមានសារៈសំខាន់ដែលនឹងត្រូវយកមកវិភាគ ដូច្នេះទាល់តែជាប្រភេទទិន្នន័យដែលមានភាពត្រឹមត្រូវ ដែលគួរឱ្យទុកចិត្តបាន ។

សូមមេត្តាអញ្ជើញបំពេញការឆ្លើយតបនូវកម្រងសំណួរដែរមានខ្លឹមសារដូចខាងក្រោម៖

I. ព័ត៌មានផ្ទាល់ខ្លួនទូទៅរបស់ប្រជាពលរដ្ឋ (Personal Information)

- សូមលោកអ្នកគូសសញ្ញាគ្រីស (☑) ក្នុងប្រអប់ចម្លើយខាងក្រោមនេះ៖
  (Please tick the sign (☑) in the information box below):

A. ភេទ (Gender)

- ☐ 1. ស្រី (Female)
- ☐ 2. ប្រុស (Male)

B. អាយុ (Age)

- ☐ 1. ពី ១៨-២៥ឆ្នាំ (18-25yo.)
- ☐ 2. ពី ២៦-៣៥ឆ្នាំ (26-35yo.)
- ☐ 3. ពី ៣៦-៤៥ឆ្នាំ (36-45yo.)
- ☐ 4. ពី ៤៦-៥៥ឆ្នាំ (46-55yo.)
- ☐ 5. ពី ៥៦ឆ្នាំ ឡើងទៅ (56yo. or up)

C. កម្រិតវប្បធម៌ (Level of Education)

- ☐ 1. បឋមសិក្សា (Primary School)
- ☐ 2. អនុវិទ្យាល័យ (Secondary School)
- ☐ 3. វិទ្យាល័យ (High School)
- ☐ 4. បរិញ្ញាបត្រ (Bachelor's Degree)
- ☐ 5. បរិញ្ញាបត្រជាន់ខ្ពស់ (Master's Degree)
- ☐ 6. បណ្ឌិត (Doctor)
- ☐ 7. មិនបានសិក្សា (Unschooled)

D. មុខរបរ (Occupation)

- ☐ 1. អាជីវករ (Businessperson)
- ☐ 2. កសិករ (Farmer)
- ☐ 3. មន្ត្រីរាជការ (Civil Servant)
- ☐ 4. បុគ្គលិកឯកជន (Private Staff)
- ☐ 5. មេផ្ទះ (Housewife)
- ☐ 6. ផ្សេងៗ (Other) ៖.....

E. អាស័យដ្ឋានបច្ចុប្បន្ន (Address)

- ☐ 1.ភូមិបវេល១
- ☐ 2.ភូមិដាច់ព្រ័ត្រ
- ☐ 3.ភូមិសង្កែវារ
- ☐ 4.ភូមិពាម
- ☐ 5.ភូមិកំពង់ភ្នៅ
- ☐ 6.ភូមិស្ទឹងដាច់
- ☐ 7.ភូមិស្ពានកណ្តោល
- ☐ 8.ភូមិសាំងរាំង
- ☐ 9.ភូមិស្វាយជ្រុំ
- ☐ 10.ភូមិដូនអារ
- ☐ 11.ភូមិសំរោងជ័យ
- ☐ 12.ភូមិព្រៃតាឡូញ

II. ការវាយតម្លៃរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន
(Measuring of citizens satisfaction on the local governance process)

- សូមអ្នកគូសរង្វង់(①,②,...)ជុំវិញចម្លើយដែលសមស្របបំផុតក្នុងតារាងខាងក្រោម៖
(Please circle (①,②,...) to select the appropriate answer in table below):

សម្គាល់៖ ① = មិនយល់ស្របខ្លាំង (Strongly Disagree)
② = មិនយល់ស្រប (Disagree)
③ = ធម្មតា (Neutral)
④ = យល់ស្រប (Agree)
⑤ = យល់ស្របខ្លាំង (Strongly Agree)

1. នីតិរដ្ឋ

ល.រ. H1	1. នីតិរដ្ឋ (Rule of Law)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
RLQ 1	សកម្មភាពអនុវត្តការងារអភិបាលកិច្ចមូលដ្ឋាន ស្របទៅតាមទម្រង់ច្បាប់ ដោយបម្រើនូវផលប្រយោជន៍ជូនសាធារណជនជារួម។	1	2	3	4	5
RLQ 2	អាជ្ញាធរផ្តល់ប្រព័ន្ធការពារសិទ្ធិមនុស្ស ចំពោះរាល់គ្រប់ពលរដ្ឋដោយគ្មានការរើសអើង។	1	2	3	4	5
RLQ 3	អាជ្ញាធរអនុវត្តច្បាប់ ជូនពលរដ្ឋដោយយុត្តិធម៌ មិនលំអៀង និងគ្មានអំពើពុករលួយ។	1	2	3	4	5
RLQ 4	មន្ត្រីអនុវត្តការងារ គោរពតាមតួនាទីស្របច្បាប់ សមហេតុផលជូនពលរដ្ឋ។	1	2	3	4	5

2. តម្លាភាព

ល.រ. H2	2.តម្លាភាព (Transparency)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
TQ1	អាជ្ញាធរតែងសម្រេចបង្កើតព័ត៌មាន លក្ខខណ្ឌ ឬសេចក្តីសម្រេចថ្មីណាមួយ ដោយទូទៅ និងមានប្រយោជន៍រួមចំពោះប្រជាពលរដ្ឋ។	1	2	3	4	5
TQ2	អាជ្ញារធរជូននូវដំណឹង ព័ត៌មាន ឬសេចក្តីសម្រេចស្របច្បាប់នានា ដោយបើកចំហដល់ប្រជាពលរដ្ឋឲ្យបានយល់ដឹង។	1	2	3	4	5
TQ3	អាជ្ញាធរបើកចំហរាល់សកម្មភាព អាចឱ្យប្រជាជនយល់ច្បាស់ពីអ្វីដែលគាត់កំពុងធ្វើ រួមទាំងរបៀបធ្វើ និងផ្តល់មូលហេតុដែលសកម្មភាពនោះកើតឡើង។	1	2	3	4	5

TQ4	មន្ត្រីមិនប្រើអំណាចគាបសង្កត់ តែងផ្តល់សិទ្ធិ និងដោះស្រាយបញ្ហាជូនពលរដ្ឋគ្រប់រូប។	1	2	3	4	5

3. គណនេយ្យភាព

ល.រ. H3	3.គណនេយ្យភាព (Accountability)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
AQ1	អាជ្ញាធរមូលដ្ឋានមានទំនួលខុសត្រូវការងារ ឬសកម្មភាពនានាតាមតួនាទី និងឆ្លើយតបជាមួយពលរដ្ឋ ។	1	2	3	4	5
AQ2	អាជ្ញាធរតែងផ្សព្វផ្សាយដំណឹង ព័ត៌មានទូទៅ និងមានបណ្តាញទាក់ទងសម្រាប់ប្រជាពលរដ្ឋបញ្ចេញមតិ ឬកង្វល់ ដែលងាយដល់មន្ត្រីក្នុងការដោះស្រាយជូន។	1	2	3	4	5
AQ3	អាជ្ញាធរតែងទទួលខុសត្រូវរួមទៅលើសេចក្តីសម្រេចចិត្ត និងបម្រើការងារជូនប្រពលរដ្ឋ។	1	2	3	4	5
AQ4	អាជ្ញាធរតែងបង្ហាញរបាយការណ៍ ឬផ្តល់ដំណឹងនូវរាល់សកម្មភាព និងទិដ្ឋភាពនានាដែលកើតមានឡើងក្នុងមូលដ្ឋាន ឱ្យប្រជាពលរដ្ឋបានជ្រាប។	1	2	3	4	5

4. ការឆ្លើយតប

ល.រ. H4	4.ការឆ្លើយតប (Responsiveness)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
RQ1	អាជ្ញាធរតែងតែឆ្លើយតបគ្រប់បញ្ហា ឬតម្រូវការចាំបាច់ជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលបានស្នើសុំ។	1	2	3	4	5
RQ2	អាជ្ញាធរផ្តល់ជូនសេវាកម្មសាធារណៈប្រកបដោយប្រសិទ្ធភាព មានគុណ ភាពល្អ និងទំនុកចិត្តខ្ពស់ដល់ប្រជាពលរដ្ឋ។	1	2	3	4	5
RQ3	អាជ្ញាធរតែងមានការត្រៀមលក្ខណៈជាមុន សម្រាប់ដោះស្រាយបញ្ហាកើតឡើងភ្លាមៗ ជូនប្រជាពលរដ្ឋដោយមិនទុកបញ្ហាចោល។	1	2	3	4	5

RQ4	អាជ្ញាធរមានភាពសកម្ម ក្នុងការកែសម្រួល និងដោះស្រាយបញ្ហា ឬការលំបាកនានាជូនប្រជាពលរដ្ឋ។	1	2	3	4	5

5. ការចូលរួម

ល.រ. H5	5.ការចូលរួម (Participation)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
PQ1	អាជ្ញាធរតែងតែប្រមូលព័ត៌មាន យល់ពីតម្រូវការពិតក្នុងមូលដ្ឋាន និងគិតគូដោះស្រាយជូនរបស់ប្រជាពលរដ្ឋ។	1	2	3	4	5
PQ2	អាជ្ញាធរ និងប្រជាពលរដ្ឋតែងមានសកម្មភាពអនុវត្តរួមគ្នាលើដំណើរការកសាងមូលដ្ឋានរបស់ខ្លួន។	1	2	3	4	5
PQ3	អាជ្ញាធរតែងលើកទឹកចិត្តដល់ប្រជាពលរដ្ឋឱ្យចូលរួម លើកិច្ចការសាធារណៈ ដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ពួកគាត់។	1	2	3	4	5
PQ4	អាជ្ញាធរតែងតែផ្សព្វផ្សាយ ឱ្យប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់នៃការចូលរួមរបស់ពួកគាត់លើការអភិវឌ្ឍមូលដ្ឋាន។	1	2	3	4	5

6. ភាពពេញចិត្តរបស់ប្រជាពលរដ្ឋលើដំណើរការអភិបាលកិច្ចមូលដ្ឋាន

ល.រ. DV	6. ភាពពេញចិត្តរបស់ប្រជាពលរដ្ឋ (Citizens Satisfaction)	មិនយល់ស្របខ្លាំង	មិនយល់ស្រប	ធម្មតា	យល់ស្រប	យល់ស្របខ្លាំង
CSQ 1	អាជ្ញាធរមូលដ្ឋានមានទំនួលខុសត្រូវ ស្មោះត្រង់ មានក្រមសីលធម៌ល្អ ក្នុងការបម្រើសេវាកម្មជូនប្រជាពលរដ្ឋ ។	1	2	3	4	5
CSQ 2	មន្ត្រីមានសមត្ថភាព ក្នុងការបំពេញសេវាកម្ម ដោះស្រាយបញ្ហា និងឆ្លើយតបសំណើតាមតម្រូវការប្រជាពលរដ្ឋ។	1	2	3	4	5
CSQ 3	ប្រជាពលរដ្ឋតែងមានសិទ្ធិចូលរួមសកម្មភាពចាំបាច់ក្នុងសង្គម និងអាចបញ្ចេញមតិវាយតម្លៃភាពពេញចិត្តទៅលើអភិបាលកិច្ចរបស់អាជ្ញាធរ។	1	2	3	4	5

CSQ 4	អាជ្ញាធរមូលដ្ឋានផ្តល់ទំនុកចិត្ត មានទំនាក់ទំនងល្អ និង មានភាពស្និទ្ធស្នាលជាមួយប្រជាពលរដ្ឋ។	1	2	3	4	5
CSQ 5	អាជ្ញាធរលើកស្ទួយសមធម៌ និងយកចិត្តទុកដាក់ទៅលើ តម្រូវការខុសៗគ្នារបស់ប្រជាពលដ្ឋ។	1	2	3	4	5

ជាចុងបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់អស់លោកអ្នក ដើម្បីចូលរួមឆ្លើយតបនូវកម្រងសំណួរដោយក្តីអនុគ្រោះ។

សូមជូនពរសំណាងល្អ សុខភាពល្អ!